ប្រលោមលោកខ្នាតខ្លី

រឿង

# ដប់បីឆ្នាំ

ដោយ

ស. សូត្រ



# មាតិកា

ទំព័រ

មាតិកា .......................................................... ១

ការបដិសេធន៍ទទួលខុសត្រូវ នឹងសេចក្តីជម្រាបរបស់អ្នកនិពន្ធ .......................................... ២

វគ្គ ១៖ គ្រាបែក .......................................................... ៤

វគ្គ ២៖ ជំនួបថៃដន្យ .......................................................... ៧

វគ្គ ៣៖ បរិញ្ញា .......................................................... ១៣

វគ្គ ៤៖ គ្រាជួប .......................................................... ១៧

វគ្គ ៥៖ អនុស្សាវរិយ៍ .......................................................... ២២

វគ្គ ៦៖ ជំរឿសដ៏លំបាក .......................................................... ៣៧

វគ្គ ៧៖ រឿងស្នេហ៍ .......................................................... ៤១

វគ្គ ៨៖ រឿងរៀន .......................................................... ៤៦

វគ្គ ៩៖ សៀមរាប .......................................................... ៤៩

វគ្គ ១០៖ ឆងា .......................................................... ៥៧

វគ្គ ១១៖ បំណងម្តាយ .......................................................... ៦១

វគ្គ ១២៖ មែលប៊ិន .......................................................... ៦៤

## ការបដិសេធន៍ទទួលខុសត្រូវ នឹងសេចក្ដីជម្រាបរបស់អ្នកនិពន្ធ

លោកអ្នកអានជាទីមេត្រី៖

សាច់រឿងដូចតទៅគឺគ្រាន់តែជាការប្រឌិតប៉ុណ្ណោះ ។ តួអង្គទាំងអស់ក្នុងផ្ទៃរឿង ក៏សុទ្ធតែជាការប្រឌិតដែរ ។ តួអង្គណា ឬ ផ្ទៃរឿងអ្វីដែលដូច ឬ ស្រដៀងទៅនឹងបុគ្គលណាមិនថាមានជីវិតនៅឡើយឬស្លាប់បង់ហើយក៏ដោយ គឺជាការចៃដន្យទាំងស្រុង ។ ទោះជាយ៉ាងនេះក៏ដោយ ទីកន្លែងនឹងជំនួញមួយចំនួនក្នុងរឿងនេះគឺអាចមានពិត ហើយត្រូវបានយកមកប្រើក្នុងគោលបំណងបន្ថែមតថភាពអោយផ្ទៃរឿងតែប៉ុណ្ណោះ ។ លើកលែងតែមានការបញ្ជាក់ដោយខ្ញុំបាទជាអ្នកនិពន្ធ ខ្ញុំសូមជម្រាបថាខ្ញុំបាទមិនត្រូវបានអ្នកគ្រប់គ្រងទីកន្លែងនឹងជំនួញទាំងនេះឧបត្ថម្ភមិនថាក្នុងមធ្យោបាយណាក៏ទេដែរ ។ ដូចគ្នាដែរ អ្វីក៏ដោយដែលបរិយាយពីទីកន្លែងនឹងជំនួញទាំងនេះគឺគ្រាន់តែជាការប្រឌិតទាំងអស់ ។ ការប្រឌិតនេះមិនមានបំណងបង្អាប់បង្ខូចទីកន្លែងនឹងជំនួញទាំងនេះ មិនថាក្នុងមធ្យោបាយណាមួយ ទោះដោយចេតនា ឬអចេតនាក្ដី ។

ជាមួយគ្នានេះដែរ ខ្ញុំបាទក៏សូមជម្រាបលោកអ្នកអានថា នេះជាស្នាដៃនិពន្ធដំបូងរបស់ខ្ញុំបាទ ជាបុគ្គលដែលមិនមានជំនាញក្នុងការនិពន្ធ ឬ មានឯកទេសក្នុងខេមរះភាសាមិនថាក្នុងវិធីណាក៏ទេដែរ ។

ខ្ញុំបាទគ្រាន់តែមានចំណូលចិត្តអនេកក្នុងរឿងប្រលោមលោកនានាហើយមានបំណងចង់លើកដម្កើងវិស័យនេះក៏ដូចជាការអានភាសាខ្មែរដែរ ។ ដូច្នេះបើលោកអ្នកអានប្រទះឃើញការខុសឆ្គងយ៉ាងណា មិនថាជាសាច់រឿងក៏ដូចជាអក្ខរាវិរុទ្ធ ក៏សូមអធ្យាស្រ័យ ។ បើលោកអ្នកអានមានយោបល់រិះគន់ក្នុងន័យស្ថាបនាផ្សេងៗ ខ្ញុំបាទសូមស្វាគមន៍ដោយបិតិសោមនស្ស ។ លោកអ្នកអាចផ្ញើរយោបល់ទាំងឡាយនោះមកខ្ញុំបាទបាន តាមរយះអ៊ីម៉ែលរបស់ខ្ញុំបាទ s.soth@outlook.com ។ ខ្ញុំបាទរងចាំទទួលដោយសេចក្ដីរីករាយ ។

ជាមួយគ្នានេះ ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនមាតាខ្ញុំ ប៊ុំង សួន ព្រមទាំងប្អូនប្រុសស្រីទាំងបី នឹងភរិយារបស់ខ្ញុំ ទៀង វណ្ណា កូន សមិទ្ធិ នឹងកូន វិគទ័រ ។ គឺអ្នកទាំងអស់ហើយជាកម្លាំងបណ្ដាលចិត្ត នឹងជាទីស្រឡាញ់ជាអលង្ការរបស់ខ្ញុំ ។

សូមអរគុណ ។

ឧសភា ២០១៣
ធានីមែលប៊ិន
ស.សូត្រ

មួយក្បាលនេះជូនបងសីដា កញ្ញាវិម៉ាឡា នឹងលោកចន្ទរឿនសំរាប់ការវាយតម្លៃរបស់លោកអ្នក

Dob Bey Chnam
A Novella By S.Soth

© 2013, S.Soth

Self publishing
(s.soth@outlook.com)

ALL RIGHTS RESERVED. This book contains material protected under International and Federal Copyright Laws and Treaties. Any unauthorized reprint or use of this material is prohibited. No part of this book may be reproduced or transmitted in any form or by any means, electronic or mechanical, including photocopying, recording, or by any information storage and retrieval system without express written permission from the author.

# គ្រាបែក

«ម៉ាក់មិនឲ្យកូនស្រឡាញ់វាទេ»

លោកជំទាវផលនិយាយម៉ាត់ៗ ហើយដើរចុះដើរឡើងចំពោះមុខបុត្រលោកដោយក្តៅចិត្ត ។ ដៃលោកក្តាប់ណែន ។ បេះដូងលោកលោតញាប់បាញ់ឈាមច្រាលពេញសារពាង្គកាយ ។ លោកឈរសម្លក់ទៅបុត្រលោកដោយកំហឹង ។ លោកខាំធ្មេញដោយគ្រឹតខ្ចាញ់នឹងការរឹងទទឹងរបស់បុត្រលោក ។

នរិនអង្គុយអោនមុខជ្រប់លើសាឡុងក្នុងបន្ទប់ទទួលភ្ញៀវ ។ ដៃអ្នកទាំងទ្វេរស្រាក់គ្នាណែន ។ ទ្រូងអ្នកស្ទើរផ្ទុះបែក ។

«គ្រួសារវាក្រ ។ ម៉ែឪវាចាស់ខ្ញុំហើយ ។ ហើយវាមានបងប្អូនច្រើនទៀត ។ ម៉ាក់មិនចង់អោយកូនម៉ាក់ទៅរ៉ាប់រងបន្ទុកច្រើនម្លឹងទេ ។»

«តែ...»

នរិនហើបមាត់បំណងបំភ្លឺម្តាយ តែលោកហាក់យល់វាជាការតវ៉ា ។

«គ្មានតែ គ្មានស្អីទេ ។»

លោកជំទាវនិយាយកាត់ ។ លោកសម្លក់នរិនត្លែរ ។

«ស្តាប់ម៉ាក់ នរិន ។ កូននៅក្មេង ។ កូនឃើញសេចក្តីស្នេហាអិញ្ចឹងឯង ។ វ័យនេះណា គេគិតថាអោយតែមានការស្រឡាញ់គឺគ្រប់គ្រាន់ហើយ ។ តែជីវិតពិតវាមិនអិញ្ចឹងទេ ។ វាមិនដូចចំរៀងទេ ។ ស្នេហាស្មោះ ផឹកទឹកទន្លេបានយូរប៉ុន្មាន?»

លោកសួរដោយសំឡេងមុតស្រួច ។ លោកស្ងាត់មួយស្របក់ហាក់ចង់អោយសំណួរលោកជ្រាបចូលគំនិតនរិនអោយជ្រៅ ។ លោកចង់អោយអោយ៉នរិនគិតថែមអោយបានច្បាស់បន្តិចទៀត ។

បន្តិចក្រោយមក លោកដើរមកទម្លាក់ខ្លួនអង្គុយចុះក្បែរបុត្រទោលរបស់លោក ។

«នរិន ជឿម៉ាក់ទៅ ។ ឈប់ទាក់ទងវាទៀតទៅកូន ។ ម៉ាក់អង្វរហើយអង្វរទៀត ។ ដើម្បីម៉ាក់នឹងគ្រួសារយើងណាកូន ។»

លោកជំទាវបន្ទន់សំឡេងបន្តិចមកវិញ ។ ដៃលោកកាន់ដើមដៃនរិន ។

«ម៉ាក់...»

នរិនងើបមុខឡើងសម្លឹងអ្នកមានគុណរបស់ខ្លួន ។ ភ្នែកអ្នករលីងរលោង ។ សំឡេងអ្នកមានសភាពអួលដើមកនឹងអណ្តើតអណ្តក់ ។

«មិនមែនស្នេហាអាច ឬ ធ្វើអោយខ្ញុំភ្លេចម៉ាក់នឹងគ្រួសារទេ ។»

អ្នកប្រឹងនិយាយអោយបានច្បាស់ពីសេចក្តីក្នុងចិត្តអ្នក៉ ។

«ខ្ញុំគ្រាន់តែសុំចិត្តម៉ាក់ក្នុងបំណងរាប់អាន ឆដា ដើម្បីអោយយើងបានមើលចិត្តគ្នាតទៅទៀតទេតើ ។ ពួកយើងដឹងថាយើងនៅក្មេង ហើយមិនមែនយើងចង់រៀបការឆាប់ៗនេះឯណា ។ ព្រោះតែគោរពម៉ាក់នឹងដើម្បីគ្រួសារហ្នឹងហើយ ទើបខ្ញុំមិនចង់លួចលាក់ទាក់ទងគ្នាបន្ទាប់ពីយើងដឹងថាអារម្មណ៍ដែលយើងមានចំពោះគ្នាគឺជាអារម្មណ៍បែបណា ។ ពួកយើងសូមត្រឹមអោយម៉ាក់ចំហរចិត្តទទួលស្គាល់ថាយើងរាប់អានមើលចិត្តគ្នាប៉ុណ្ណោះ ។ អនាគតយ៉ាងណានោះ យើងមិនអាចដឹងទេ ។»

អ្នករៀបរាប់វែងឆ្ងាយ ។ ហើយអ្នកបន្ថែម

«ម៉ាក់, បើយើងមិនមែនគូនឹងគ្នា យើងគង់ចប់គ្នាមិនខាន ម៉ាក់ក៏គង់នឹងសមចិត្តតាមនោះដែរ ។»

ថាហើយអ្នកក៏ហាក់ស្តាយក្រោយចំពោះមួយឃ្លាក្រោយគេដែលទើបនឹងពោលផុតទៅ ។

«មិនបាន ។»

លោកជំទាវ ងើបក្រេះឡើង ហើយតម្លើងសម្លេង ក ម្តងទៀត ។

នរិនអោនមុខជាថ្មី ។ ទឹកភ្នែកអ្នករមៀលចុះ ហើយស្រក់តក់ទៅលើកម្រាលព្រំដ៏ប្រណិត ។

«បើនរិនលែងស្តាប់ម៉ាក់ហើយ...»

លោកជំទាវបន្តទាំងសង្កៀតធ្មេញ ។

«តាមចិត្តកូនចុះ ។ ម៉ាក់គ្មាននិស្ស័យជាមួយនាងក្តាហ្នឹងទេ ។ ម៉ាក់តាមកូនមិនបានទេ ។»

ហើយលោកដើរតម្រង់ទៅមាត់ទ្វារ ។ នរិននៅអោនមុខដដែល ។

«ណ្ហើយ! ចឹង កូនទៅចុះ! ។ តាមចិត្តកូនចុះ ។ ចាត់ទុកថាកូនល្អរបស់ម៉ាក់វាស្លាប់បាត់ទៅហើយចុះ ។»

«ពុទ្ធោ ម៉ាក់»

នរិខទាន ហើយលុតជង្គង់ចុះសំពះបាតជើងម្តាយពីចម្ងាយដល់កម្រាល ។ លោកជំទាវផលបើកទ្វារឡើង ។ នរិនងើបមុខដែលមានទឹកភ្នែករហាមើលម្តាយអ្នកដោយខ្សែភ្នែកអង្វរករ ។

«កុំអីញ្ចឹងម៉ាក់ ។ កូនសូមអង្វរ ។»

ហើយទឹកភ្នែកអ្នកដណ្តើមគ្នាស្រក់ច្រាវកាត់ផែនថ្ពាល់ទាំងគូ ។ មិនអាចទប់បាន អ្នកបណ្តោយខ្លួនអោយយំយ៉ាងសសឹក ។

ជំទាវផលក៏យំដែរ តែលោកខាំមាត់ហើយដើរចេញពីបន្ទប់ទទួលភ្ញៀវទៅដោយកំហឹង ។ ដៃលោកទាំងពីរញ័រទទ្រើក ។ លោកបិទទ្វារលាន់ខ្លាំង ចុះជណ្តើរញាប់ជើងស្ទេរ ចេញទៅក្រៅ ហើយឡើងរថយន្តបង្គាប់ណប់ដែលជាសូហ្វ័រអោយបើកចេញទៅបាត់ ។

នរិននៅលុតជង្គង់ដដែល ។ អ្នកយំសសឹកហើយសសឹកទៀត ។ អ្នកបង្ហូរទឹកភ្នែកយ៉ាងជូរចត់ ។ អ្នកស្តាយដែលធ្វើអោយម្តាយច្រឡោតដល់ម្លឹង ។ ២៥ ឆ្នាំហើយអ្នកមិនដែលឃើញលោកខឹងយ៉ាងនេះទេ ។ អ្នកដឹងម៉ាក់អ្នកស្រឡាញ់អ្នកណាស់ ហើយតាមចិត្តអ្នកសឹងគ្រប់យ៉ាង ។ តែពេលនេះលោកមិនតាមចិត្តអ្នកទេ ។ លោកមិនសូម្បីតែស្តាប់ការពន្យល់របស់អ្នក ។ គិតដល់នេះអ្នកសង្វេគចិត្តណាស់ ។

ពេលគិតដល់ឆដា អ្នកក៏រឹតតែស្តាយនឹងឈឺចាប់ណាស់ទៅទៀត ។ ខិ តើអ្នកនឹងទម្លាយរឿងនេះអោយនាងជ្រាបដូចម្តេចទៅ ។ នារីទន់ភ្លន់ណាស់ ។ នាងមុខតែឈឺចាប់ នឹងតូចចិត្តស្លាប់ហើយ ។  កម្មអ្វីហ្នឹកំណាចដល់ម្លេះ ។

នឹកត្រឹមហ្នឹងនរិនកាន់តែសសឹកទៅទៀត ។

អ្នកយំដូចក្មេង លែងខ្មាស់អៀនអ្វីទាំងអស់ ។ អ្នកអណ្តឹកអណ្តក់ រហេមរហាមដោយទឹកភ្នែកទឹកសំបោរ ។

នៅខាងក្រៅ មុខបន្ទប់ឯជ្រុងម្ខាង ម៉ែដោះឡា ដែលធ្លាប់មើលថែរយុរកម្លោះតាំងពីតូចក្រូចឆ្មារមកក៏យំដែរអាណិតកូនចិញ្ចឹមរបស់គាត់ដែរ ។

ខិ ប្រសិនបើទឹកភ្នែកអាចជួយដោះស្រាយបញ្ហានានាបាន គង់ល្អមិនល្មមទេ ។

តែមានឯណា ទឹកភ្នែកបើអាចជួយបានគង់ជួយសម្រាលទុក្ខក្នុងទ្រូងតែមួយគ្រាប៉ុណ្ណោះ ។ នរិនយំគ្រានេះអ្នកដឹងថាទឹកភ្នែកមិនអាចជួយអ្វីបានទេ តែអ្នកទ្រាំមិនយំមិនបាន ។ បើអ្នកណាមិនដឹងរឿង នរិន គេគង់យល់ថាបុរសជាមនុស្សប្រុសកំសោយ ងាយយំ ។ តែភាពពិតមិនយ៉ាងនោះទេ ។

អ្នកនិពន្ធ ចូសេ អិន ហារីស បានសរសេរថា «ទឹកភ្នែកដែលបង្ហូរដើម្បីមនុស្សម្នាក់មិនមែនជាសញ្ញាស្តែងពីភាពទន់ខ្សោយរបស់បុគ្គលអ្នកយំនោះទេ ។ តាមពិតវាស្តែងអោយឃើញពីបេះដូងបរិសុទ្ធរបស់អ្នកនោះទៅវិញទេ ។»

***

# ជំនួបថ្ងៃដន្យ

«ខ្ញុំមិនស្មានថាបានជួបឆដាទៀតសោះ»

នរិនពោលទៅមិត្តចាស់អ្នកចំពោះមុខ បន្ទាប់ពីងាកទៅទទួលកាហ្វេពីធីតារត់តុ ទាំងមិនភ្លេចពោលអរគុណនាងផង ។ ឆដាមិនទាន់ឆ្លើយមិត្តនាងទេ ។ នាងងើបមុខទៅញញឹមដាក់អ្នកបំរើតុ ហើយពោលអរគុណដូចគ្នា ។

«កូនចៅប៉ុន្មានហើយ?»

នរិនសួរដោយញញឹមពព្រាយបន្ទាប់ពីធីតារត់តុដើរចេញទៅ ។ អ្នកសប្បាយចិត្តយ៉ាងចម្លែក ។ អ្នកខានមានអារម្មណ៍បែបនេះយូរណាស់ហើយ ។

«ធ្វើការអីដែរ? សព្វថ្ងៃនៅឯណាដែរ, នៅភ្នំពេញនេះ ឬនៅកំពតដដែលទេ? លោកអុំប្រុស ស្រីសុខជាទេ? បងឆពុំបានចេញទៅអាមេរិកជុំស្វាមីគាត់ហើយមែនទេ? មានដឹងដូងតុកកែយើងដាំជាមួយគ្នានោះយ៉ាងម៉េចហើយទេ? ផ្លែហើយនៅ? ផ្លែច្រើនទេ? ចំការធុរេនដែលយើងទៅមើលនោះ យ៉ាងម៉េចហើយ? អ្នកណាទិញវាទៅ?»

នរិនសួរដង្ហួញ រកតែឆដាឆ្លៀតឱកាសឆ្លើយមិនបាន ។

តែឆដា នៅតែជាឆដា ។ នឹងធឹង ហើយអត់ធ្មត់ ។ នាងគ្រាន់តែញញឹមមិនទាន់មាត់ក ទុកអោយអឌិតមិត្តចាស់ចោទអោយអស់សំណួរក្នុងចិត្តរបស់គេ ។ នារីយល់ចិត្តនាយ ។ ធីតាលើកពែងតែក្តៅរបស់ខ្លួនមកផ្លុំតិចៗ លុះត្រាហាក់គ្រជាក់ល្មមហើយទើបនាងក្រេបបន្តិច មុននឹងដាក់វាចុះ ទៅលើចានទ្រ ហើយបន្តចាំស្តាប់សំណួររបស់នរិនដោយកិរិយាអត់ធ្មត់ នឹងដោយញញឹម តទៅទៀត។

«ឧស្សាហ៍មកកាហ្វេហ្នឹងទេ?»

នរិនបន្តសួរ ។

«មានប្រើហ្វេសប៊ុគទេ? ខ្ញុំព្យាយាមស៊ើចដើម្បីរអេតដ៏ឆដាដែរតែ រកអ្នកប្រើឈ្មោះ ឆដា មិនឃើញសោះ ។»

ឃើញឆដាញឹមៗមិនមាត់ មាំណពហាក់ភ្ញាក់ខ្លួនពីការដេញដោលដំសង្ស៊ើញរបស់ខ្លួន ។

«អ៊ុំ សូមទោស ។ សួរច្រើនពេកហើយ ។ ឃើ ចំមែន ខ្ញុំនេះ ។»

នរិនបន្ទោសខ្លួនឯង ហើយសើចអេះអុញ ដោយអៀនខ្មាស់ ។

«សុំទោសណា ។ ខ្ញុំរំភើបចិត្តនឹងចង់ដឹងពេកទើបភ្លេចខ្លួនអញ្ចឹង ។»

នាយដកដង្ហើមធំ តែនៅតែញញឹម ។

«គ្មានទោសពៃអីទេ ។»

ឆដាតបមិត្តនាងវិញ ។

«តែទាល់តែបងនរិនសួរជាថ្មីបានបាន ព្រោះមិញហ្នឹងច្រើនពេក ខ្ញុំភ្លេចសំណួរបងអស់ហើយ ។»

មិត្តចាស់ទាំងពីរផ្ទុះសំណើចក្អាកក្អាយព្រមគ្នា ។

សំណាងហើយពេលនោះជាពេលថ្ងៃត្រង់មិនសូវមានអតិថិជន កុំអីផ្អើលគេមិនខាន ។

ខាងក្រៅហាង ម៉ូតូ នឹង រថយន្តមួយៗ បរទៅមក ។ ព្រះទិនករក្នុងខែមករាបញ្ចេញកម្ដៅពេញកម្លាំង ។ តែខាងក្នុងកាហ្វេ ឌីឡៃត៍ ម៉ាស៊ីនត្រជាក់កែវប្រែសីតុណ្ហភាពអោយល្មមជាទីរមនា ។

មិត្តទាំងពីរ ក្រេបភេសជ្ជៈខ្លួនរៀងខ្លួន ហើយសម្លឹងមុខគ្នាដោយទឹកមុខរីករាយ ។ ជួនកាលវាចាមិនប្រាកដថាស្មើរការមើលមុខគ្នាដោយយល់ចិត្តនោះទេ ។ តែទោះបីបែបហ្នឹងមែនក៏ដោយ នរិនចង់ឮវាចាជាងក្នុងកាលៈទេសៈនេះ ។ អ្នកដាក់កែវអ៊ិចប្រេស្សូរបស់ខ្លួនចុះ ហើយដណ្ដើងសួរជាថ្មី ។

«កូនចៅប៉ុន្មានហើយ ឆដា?»

«ម៉េចបងដឹងថាខ្ញុំមានគ្រួសារហើយ?»

ឆដាមិនឆ្លើយ តែចោទបកម៉កវិញ ។

«មិនអោយសួរបកទេ ។ ខ្ញុំសួរមុន ។ ចាំហើយសឹមឆដាសួរជាក្រោយ ។»

នរិនជំនះ ។

«នៅវិង្វរសងដែល ។»

ឆដារអ៊ូលេងបន្តិចមែន ។

«១៣ ឆ្នាំមកនេះបងមិនប្រែអីសោះទោះបន្តិច ។ នៅតាមចិត្តខ្លួនជាធំដដែល ។»

នរិនភ្ញាក់ព្រើតនឹងពេលវេលាដែលកន្លងទៅដែលឆដាទើបនឹងពោលដល់ ។ អ្នកធ្វើមិនចាប់អារម្មណ៍ ។

«អូយ កុំវែងឆ្ងាយពេក ។ សួរអីឆ្លើយហ្នឹងមកម្ចាស់ថ្លៃហើយ ។»

នរិនធ្វើមុខស្លូយ ។

«ចាស ខ្ញុំមានកូនពីរនាក់ហើយ តែមិនទាន់មានចៅនៅឡើយទេ ។»

ឆដានិយាយទាំងញញឹមខ្ចីបបែបលែងបន្តិចផង ។ នាងបន្តថា៖

«មិនទាន់មានចៅព្រោះកូនបងទើបអាយុ ប្រាំមួយឆ្នាំ នឹងកូនប្អូនទើបបួនឆ្នាំប៉ុណ្ណោះ ។»

ទាំងពីរនាក់សើចព្រមគ្នាឮខ្លាំងទៀត ។ លើកនេះភ្ញៀវតុជិតខាងពីរនាក់ដែលតាមមើលសម្លៀកបំពាក់ទំនងជាពាណិជ្ជករសម្លឹងមក ។

ទាំងពីរនាក់បែរទៅហើយអោនក្បាលបន្តិចជាលក្ខណៈសុំអភ័យទោស ។

ភ្ញៀវទាំងពីរនោះញញឹមតប ហើយបែរទៅសន្ទនាគ្នាវិញដូចពីមុន ។

«ប្រុសមួយ ស្រីមួយមែនទេ?»

«ប៉េ៎ ម៉េចបងដឹង?»

ឆដាធ្វើជាភ្ញាក់ផ្អើល ។ នាងបើកភ្នែកធំៗ ភ្នែកមូលខ្មៅដែលមានរោមភ្នែកវែង ង ដែលនរិន នៅតែចូលចិត្តគន់មិនណាយ ។ បេះដូងអ្នកចាប់ផ្ដើមទន់ជ្រាយជាថ្មី ។

«ទាយទេ ។»

នរិនតប ហើយផ្អែកខ្លួនទៅលើបង្អែកកៅអី សណ្ដូកជើងទៅមុខបន្តិច ។

«អូ៎ ទៅស្រុកគេប៉ុន្មានឆ្នាំហ្នឹងទៅរៀនទាយទេ?»

ឆដាចំអន់ ហើយក្រេបតែនាងមួយក្អឹកទៀត ។ នរិនញញឹម ។ អ្នកមិនដែលដេញដើងឆដាទាន់ទេ ។ ដូចមុនដដែល ជាញយដងមាណពតែងតែចាញ់សម្ដីយុវនាថមិនលែងឡើយ ។

«ម៉េចបានដឹងថាខ្ញុំទៅស្រុកគេ?»

នរិនសួរដោយឆ្ងល់ នឹងលាយភាពភ្ញាក់ផ្អើលផង ។

«រៀនចប់ អនុបណ្ឌិត ហើយតយកបណ្ឌិតភ្លាមៗដែរ ។ ពេលរៀនចប់ បងរកបានការងារនៅក្រុមហ៊ុនតែមួយដែលចុះទៅហាត់ការហ្នឹង ។ ក្រោយមកបង អាប់ផ្លាយ យកសញ្ជាតិគេ ហើយបានជោគជ័យដូចបំណង ។ បងមកលែងស្រុករាល់ សាំមើហូលីដេយ៍ បន្ទាប់ពី ប្អូនឆ្នាំដំបូង ។ ហើយលើកនេះមកបានពីរអាទិត្យហើយ ។»

ឆដា មិនឆ្លើយតែបែជាលាតត្រដាងរឿងរ៉ាវផ្ទាល់ខ្លួនរបស់នរិនយ៉ាងក្បោះក្បាយ ។

នរិនមើលមុខនាង ចំហរមាត់ធ្លូង ។

«ម៉េចដឹងរឿងគេច្រើន ហើយច្បាស់ម្លេះ? ជាពួក ហោគយើ ទេដឹងនៀក? ។»

ហើយអ្នកញញឹម ។

«មិនមែន ហោគយើ អីទេ តែគេមិនដូចបងទេ ។ បងឃ្លាតកាយ ហើយហាក់ណាយចិត្តព្រមតែម្តង ។»

គ្មានពាក្យតវ៉ា ណាមួយមិនចង់រំលឹករឿងចាស់ដែលធ្លាប់ធ្វើអោយរកាំចិត្តផង នរិនបង្វែរសាច់រឿង ។

«លោកអ៊ុំប្រុស លោកអ៊ុំស្រីសុខជាទេ? លោកនៅឯណាដែរបច្ចុប្បន្ន?»

«ពុកសុខទេ តែម៉ែមិនសូវមាំទាំប៉ុន្មានទេ ជាពិសេសប៉ុន្មានឆ្នាំមកនេះ ។ លោកលើសឈាមហើយទឹកនោមផ្អែមផង ។ លោកឧស្សាហ៍វិលមុខ ។ សំណាងហើយដែលពុកនៅមាំទាំ គ្រាន់ជាទីពឹងរបស់ម៉ែបានពេលយប់ព្រលប់អី ។ ពួកលោកនៅកំពតដដែលទេ ។ បងរិទ្ធឧស្សាហ៍ចុះឡើងមកមើលលោកព្រោះគាត់នៅជិតជាងគេ ។ ខ្ញុំប្តូរមករស់នៅភ្នំពេញហើយ ហើយតែងតែបបួលគាត់អោយមកនៅជុំគ្នានៅភ្នំពេញហ្នឹងដែរគ្រាន់ជិតពេទ្យល្អពេលអាសន្នអី ។ តែបងដឹងស្រាប់ហើយ អ្នកចំការចាស់ទុំដូចពួកគាត់ ចោលច្បារដំណាំដីកេរ្តិ៍អាករគាត់មិនបានយូរទេ ។»

ឆដាឆ្លើយហូរហែរ ។

នាងផាត់សក់ខ្មៅរលើបប្រាស់ស្មាររបស់នាង ទៅក្រោយ ហើយក្រេបតែមួយក្អឹកទៀត ។ មុខនាងម៉ដ្ឋរលោង ។ ឆដាមានសាច់ជាងមុនបន្តិចតែមិនដល់ធាត់ទេ ។ សម្បុររបស់នាងស្រអែមជ្រះជាងមុនឆ្ងាយណាស់ ។ មើលទៅក៏ដឹងថានាងយកចិត្តទុកដាក់រូបសំរស់នាងបានយ៉ាងល្អ ។

«ចុះបងឆពុំ?»

«បងគាត់ទៅអាមេរិកជុំគ្រួសារគាត់តាំងពីរបងទៅអូស្ត្រាលីមិនទាន់បានប៉ុន្មានម្លេះ ។»

នារីតបមិត្តនាង ។

«បងគាត់មានកូនពីរដែរ ស្រីទាំងពីរ ជំទង់ៗអស់ហើយ ។ គាត់នឹងគ្រួសារ មកលេងស្រុកខ្មែរបានបីបួនដងហើយតាំងពីទៅ ។ ក្រោយគេហ្នឹងទើបឆ្នាំទៅមិញនេះឯង ។ បងពុំគាត់ទិញចំការធុរេននៅកំពតតាមផ្លូវទៅទឹកឈូរជាងប្រាំហិចតាងណោះ ។ គាត់អោយបងរិទ្ធនឹងគ្រួសារជាអ្នកមើលខុសត្រូវ ព្រោះគាត់ដុនដាបជាងគេ ។ ផលធុរេនគាត់ បងរិទ្ធលក់រាល់ឆ្នាំ ។ បងរិទ្ធគាត់កាត់ ១៥ ភាគរយអោយបងឆពុំ ក្រៅពីនោះគាត់យកទាំងអស់ ។ គាត់នឹងគ្រួសារខំណាស់ ព្រោះបងឆពុំថាបើមិនខំគាត់គ្មានអីជួយអោយលើសហ្នឹងទេ ។ គាត់ថាលុយពិបាករកណាស់ ទោះនៅស្រុកគេក៏ដោយ ។ គាត់ថាគាត់មិនអោយលុយចាយទទេរៗទេ ។ ពួកយើងសុទ្ធតែជាអ្នកធ្លាប់អត់ យើងដឹងច្បាស់ពីទុរគតភាព ។ យើងសុទ្ធតែខំ ហើយត្បិតត្បៀតណាស់ ។»

ធីតាផ្អាក ក្រេបតែផ្សើមកបន្តិច ។

«ថ្ងៃណាទំនេរបងអាចទៅមើលចំការគាត់ ហើយទៅលេងបងរិទ្ធ នឹងពុកម៉ែផង បើបងមិនខ្លាច ។»

ហើយឆដាញឹមៗ ។ នរិនដឹងថាឆដាចង់មានន័យយ៉ាងម៉េច តែអ្នកមិនតវ៉ាទេ ។

«ល្អតើ ។»

អ្នកពោលខ្លីៗ ហើយសញ្ជឹងគិត ។

ឆដាញញឹមស្ងួតមិនចេញស្តី ។

បរិយាកាសប្រែជាស្ងប់ស្ងាត់ ។ ចំរៀង «ស្នេហ៍ឃឹតពេល» របស់តារាចំរៀងសំនៀងផ្អែម មាស សុខសោភា ដែលហាងកាហ្វេចាក់ឮពិរោះរងំ ។

អ្នកទាំងពីរមើលមុខគ្នា ក្រេបភេសជ្ជៈរបស់ខ្លួនរៀងខ្លួន ហើយសម្ងំស្តាប់ចំរៀងដោយស្ងៀមស្ងាត់ ។ តែ នឹងកាហ្វេសល់កន្លះពែង ត្រជាក់ហាក់លែងឆ្ងាញ់អស់ហើយ ។

ខាងក្រៅហាងមើលទៅក្តៅហែង ហើយស្ងប់ខ្យល់ឈឹង ។ ដើមឆ័ត្រប៉ុន្មានដើមខាងក្រៅហាងឈរធ្មឹង យូរស្លឹកហាក់ញ័មកម្តងៗ ។ តាមផ្លូវក៏ស្ងាត់ ស្ងាត់ម៉ូតូ ឡានមួយក៏គ្មានរត់ដែរពេលនេះ ។

ពេលជួបមុខម្តងៗ ខំប្រឹងសម្តែង
ធ្វើដូចខ្លួនឯងគ្មានចិត្តស្នេហា
ពេលបងទៅបាត់ទឹកភ្នែកស្រោចក្រោ
ស្រឡាញ់បងប៉ុណ្ណា រៀមរ៉ាមិនបានយល់ទេ ។

ខំគេចពីនេត្រាខ្លាចជីវ៉ាឃើញចិត្ត
មិនអោយបងអាណិតស្នេហ៍អូនភ្លេចគេ
សុំអោយអូនឈឺចាប់ ឈឺម្នាក់ឯងបានទេ
អូនមិនអាចទ្រាំមើលគេឈឺម្នាក់ទៀតឡើយ ។

សម្លឹងបងពីឆ្ងាយ អូនយំស្តាយបងមិនដឹង
ខ្លួនអស់ក្តីសង្ឃឹមប្រឹងទប់ចិត្តទន់ខ្សោយ
ចង់អោយបងទៅឆាប់ ភាពឈឺចាប់ក្រែងថយ
ចិត្តអើយស្តាយដល់ណា ។

ទោះចិត្តស្នេហ៍ពីចម្ងាយ ក៏ដឹងថាចិត្តកាយគ្មានសិទ្ធ
ត្រូវតែខិតខំកាត់ចិត្ត បំភ្លេចរាល់អនុស្សា
ព្រោះក្តីស្រឡាញ់មួយនេះ ឃើញច្បាស់មានតែបញ្ហា
ស្នេហាឃឹតពេល ៕

អត្ថន័យបទចំរៀងបណ្តាលអោយអ្នកទាំងពីរមានដង្ហើមធំព្រមគ្នា ។

អនុស្សាវរិយ៍ចាស់ដណ្តើមគ្នាប្រសាចរស់ឡើងវិញក្នុងមនោរម្មណ៍អ្នកទាំងពីរតែរៀងខ្លួន ។ អនុស្សាវរីយ៍ដែលមានទាំងផ្អែមល្ហែមនឹងជូរចត់ ។

នរិនបន្លូដង្ហើមម្តងទៀត ។ នាយមានរឿងច្រើនទៀតដែលចង់សួរ ។ អ្នកចង់ដឹងថាស្វាមីរបស់ឆដាជាអ្នកណាដែរ អ្នកស្រុកណា គេធ្វើការអីទៅ គេស្គាល់ឆដាដំបូងពេលណា របៀបណា គេល្អចំពោះនាងទេ នាងស្រឡាញ់គេទេ ។

អ្នកឆ្ងល់ ហេតុអីបានជាឆដាដឹងរឿងគេទាំងអស់ ទោះទាំងដែលគេខំទៅឆ្ងាយ ហើយផ្តាច់អស់ទំនាក់ទំនងអស់ជាមួយអ្នកស្រុកខ្មែរ លើកលែងតែអ្នកម៉ាក់នឹងមិត្តភក្តិស្និទស្នាល មិនប៉ុន្មាននាក់នោះ ។ មិនអាចថាឆដាដឹងពីជីវិតគេតាមមិត្តទាំងនោះទេ ។ នរិនស្គាល់មិត្តខ្លួនច្បាស់ណាស់ ។

នៅមានសំណួរច្រើនទៀត ប៉ុន្តែអ្នកមិនហ៊ានសួរ ។

ប៉ុន្មាននាទីកន្លងទៅដោយស្ងប់ស្ងាត់ ។

លុះចប់ចំរៀងមួយបទទៀត នរិនទម្លុះភាពស្ងៀមស្ងាត់ដ៏ឆ្គងនោះ ។

«ពេលណាហ្នឹងអាចទៅលេងបាន?»

«ទៅ...?»
ឆដាសួរបង្អួសសំលេង ព្រោះមិនដឹងថានិរនចង់និយាយពីអីអោយប្រាកដ ។
«...កំពត ។ ចង់ទៅជំរាបសួរលោកអ៊ុំទាំងពីរ បងរិទ្ធ នឹងទៅមើលចំការបងឆពុំផង ។ ឆដាមានដឹងថាចំការដែលយើងធ្លាប់ទៅមើលជុំគ្នា បំរុងនឹងទិញពេលណាយើងបាន...»
«រៀបការជាមួយគ្នា?»
ឆដាសួរកាត់ ។ សំឡេងនាងស្ទើរផេង ។
និរនមុខក្រហម ។ ក្នុងទ្រូងអ្នកធូន់ពៀបដោយវិប្បដិសារីយ៍ ។
«មានដឹងថាវាទៅជាយ៉ាងណាទៅហើយទេ?»
នាយមិនឆ្លើយ តែបញ្ចប់សំនួររបស់ខ្លួនដោយរំលងពាក្យដែលឆដានិយាយកាត់ ។
«បងដែលទៅលេងកំពតទេ តាំងពីបងទៅរៀននៅអូស្ត្រាលី?»
ឆដាមិនឆ្លើយ តែសួរបកមកវិញ ។
«អត់ទេ ។ មិនមានភាពក្លាហានគ្រប់គ្រាន់និងជាន់ដីកំពតទៀតទេ ។»
«បងខ្លាចអី? ។ កំពតប្លែកច្រើនណាស់ ១៣ ឆ្នាំមកនេះ ។ ស្ពានយោលទឹកឈូរ ទំនប់វារីអគ្គីសនី ស្ពានថ្មកាត់ក្រុង បូកគោ ជ្រោះទឹកធ្លាក់ពពកវិល នឹងផ្លូវថ្នល់ សុទ្ធតែប្រែប្រួល ។ ទាំងអស់ហ្នឹងនឹងធ្វើអោយបងចំលែកភ្នែកខ្លាំងមិនខាន ។»
«សង្ឃឹមថាមិនមែនអ្វីៗសុទ្ធតែប្រែប្រួលទាំងអស់ទេ»
និរននិយាយ ហាក់បង្កប់ន័យអ្វីម្យ៉ាង ។
ឆដាធ្វើមិនឮ ។
«ពុកនឹងម៉ែនឹងបងរិទ្ធតែងសួរអំពីបងជានិច្ច ពេលណាឱកាសហុចអោយ ។ ទោះហ្នឹងដឹងពីបង ហ្នឹងមិនដែលប្រាប់គាត់ថាបងយ៉ាងណាៗទេ ។ គ្រាន់តែប្រាប់ថាបងទៅនៅស្រុកគេហើយ ។»
«ចុះ...»
មិនទាំងចប់សំណួរផង ទូរស័ព្ទរបស់និរនរោទ៍ឡើង ។
«សុំទោស»
និយាយបណ្តើរ នាយទាញវាពីក្នុងហោប៉ៅខោមកមើលបណ្តើរ ។
ឆដាញញឹម មិនចេញស្តី ។
ឃើញឈ្មោះអ្នកហៅមកហើយ អ្នកចុចទទួលភ្លាម ។
«ហេឡូម៉ាក់ ... កំពុងញ៉ាំកាហ្វេជាមួយមិត្តភ័ក្រនៅម្តុំបឹងកេងកង ... អត់មានទេម៉ាក់ យ៉ាងម៉េចដែរ? ... បាន, ល្អតើម៉ាក់ ... បាទ ម៉ោង ៦ គត់ចឹងហ៎ម៉ាក់ ។ ... បាទ ... បាទ ។»
ពេលនាយញាត់ទូរស័ព្ទចូលហោប៉ៅវិញ ធីតាសួរ ។
«អ៊ុំស្រីសុខសប្បាយទេ?»
«ម៉ាក់សុខទេ ។ អរគុណ ។»
ហើយនាយបង្វែរសាច់រឿង ។ «និយាយចឹង ឆដានៅម្តុំណាដែរ ឧស្សាហ៍មកញ៉ាំកាហ្វេនៅទីនេះទេ?»
«ខ្ញុំនៅម្តុំទួលគោកឯណោះ ខ្ញុំឧស្សាហ៍មកតើ សឹងតែរាល់ថ្ងៃហ្នឹង ។»
ពោលហើយនាងមើលម៉ោងលើកដៃឆ្វេងរបស់នាង ។
«ខ្ញុំសុំទោសណា ខ្ញុំមានការបន្តិចម៉ោងពីរហ្នឹង ។ ខ្ញុំត្រូវទៅហើយ ។»
ហើយនារីក្រោកឡើង ។
និរនក្រោកដែរ ។

«អត់អីទេ ។ អឺ... និយាយចឹង ខ្ញុំអាចសូមលេខទូរស័ព្ទឆដាបានទេ គ្រាន់ស្រលទាក់ទងគ្នាថ្ងៃក្រោយ ។»

ឆដាញញឹមមិនស្តី នាងទាញប៊ិចមក ហើយយកវិក័យប័ត្រកាហ្វេរបស់មាណពម៉ាកសរសេរលើរួចបត់ជាពីរ ហើយហុចអោយនរិន ។ នាយទទួលយកដោយមិនទាំងបើកមើលផង ។

«ខ្ញុំលាហើយ ។ ចាំថ្ងៃក្រោយជួបគ្នាទៀត ។ ទាល់តែដាច់ខែហ្នឹងបានបងទៅមែលប៊ិនវិញមែនទេ?»

«មែនហើយ ។ សង្ឃឹមថាបានជួបគ្នាថ្ងៃក្រោយទៀត ។ មានអីច្រើនដែលខ្ញុំចង់ដឹងពីឆដា ។»

«ខ្ញុំទៅសិនហើយបង ។»

នារីលាម្តងទៀត ។

ពេលដើរកាត់តុកុម្ម៉ង់ នាងងាកទៅនិយាយជាមួយអ្នកលក់ទាំងពីរនាក់ ។

«ណាវ៉ា មុំ បងទៅហើយណា ។»

«បាទបង»

អ្នកលក់ទាំងពីរឆ្លើយព្រមគ្នាដោយលំទោន ។

ហើយនាងបើកទ្វារកញ្ចក់ចេញទៅ ។ សំពត់ស្វៃរខ្មៅ ឆែកលើជង្គង់ អមដោយកែងចោទខ្ពស់ លើករាងរៅនារីអោយសង្ហានឹងថ្លៃថ្នូរអោយគោរព ។

នរិនជូនដំណើរនាងដោយក្រសែរភ្នែកពីក្នុងហាងទៅ ។

ឆដាដើរសំដៅរថយន្ត ឡេនរ៉ូវ័រ ថ្មីថែសខ្មៅមួយគ្រឿង ចុចបើកសោរពីចម្ងាយដោយតេឡេបញ្ជា បើកទ្វារហើយបរចេញទៅ ទាំងមិនភ្លេចគ្រវីដៃតាមបង្អួចផង ។

រថយន្តបទៅឆ្ងាយហើយ តែនរិននៅឈរភាំងនៅឡើយទេ ។

ឆដាមិនមែននារីខេត្ត ក្រក្រីដូចមុនទេ ។ តែនាងនៅទន់ភ្លន់ដដែល ។ តាមមើលសម្លៀកបំពាក់និងសម្ភារះប្រើប្រាស់ ក៏ដូចជាអកប្បកិរិយារបស់នាង នាងប្លែកណាស់ ។ នាងមានទំនុកចិត្តខ្លួនឯងខ្ពស់ណាស់ ហើយហាក់មានអំណាចយ៉ាងចំលែក ជាពិសេសលើអ្នកលក់ទាំងពីរនាក់ ។

នាយដើរមកកៅអីរបស់ខ្លួនវិញ ដាក់គូថអង្គុយចុះហើយយកក្រដាសលេខទូរស័ព្ទដែលឆដាកត់អោយមកលាមើល ។

មិនមានលេខទូរស័ព្ទទេ ។ ឆដាកត់អ៊ីម៉ែលរបស់នាងអោយអ្នកវិញទេ ។

នរិនបត់ក្រដាសដាក់ក្នុងហោប៉ៅអាវហើយដើរចេញទៅតម្រង់រថយន្តរបស់ខ្លួន ។ ចម្ងល់រាប់រយផុសចេញប្រសាចក្នុងខួររបស់នាយ ។

***

# បរិញ្ញា

«ជូនម៉ាក់»

នរិនដើរចុះពីវេទិកា តម្រង់ទីខ្លួនអង្គុយជាមួយមាតា ។ ពេលទៅដល់លោក អ្នកហុចបរិញ្ញាប័ត្រដែលទើបទទួលបានជូនម្តាយ ។

«អបអរសាទរ កូន ។»

លោកជំទាវទទួលយកហើយអង្អែលក្បាលកូនជាទីស្រឡាញ់របស់លោក ។ លោកមានការពេញចិត្តបុត្រលោកជាអនេក ។ នរិនមិនដែលធ្វើអោយលោកលំបាកចិត្តទេ ។ អ្នករៀនពូកែរហើយ មិនអាងអំណាចម៉ែឪ ឬ ទឹកលុយទៅប៉ៅឡែឬ សេពគប់មិត្តភ័ក្តបាញ់បោះសេរី បង្ករឿងម្តងណាឡើយ ។ អ្នកចូលចិត្តអានសៀវភៅ ហើយពេលទំនេរក្រៅពីហ្នឹងតែងមកក្រុមហ៊ុនលោកហាត់ការ និងជួយការងារគ្រប់យ៉ាងតាមលទ្ធភាពគេ ។

«ប៉ាកូនមិនដឹងជាសប្បាយចិត្តយ៉ាងណាទេ បើលោកនៅវិញ»

លោកជំទាវពោលពេលមាណពដាក់ខ្លួនអង្គុយក្បែរលោក ។

«ច្បាប់ពាណិជ្ជកម្មគឺអ្វីដែលប៉ាកូនចង់ឃើញកូនមានឯកទេសណាស់ ។ កន្លងកូនបានសំរេចដូចបំណងលោកហើយ ស្តាយណាស់ដែលលោកមិនបាននៅយល់ជោគជ័យរបស់កូន ។»

«កូននិងមិនធ្វើអោយវិញ្ញាណខ័ន្ធលោកប៉ាខកចិត្តទេ ។»

នរិនពោល ។

«ចុះម៉ាក់?»

«ម៉ាក់ កូនរិតតែមិនហ៊ានអោយខកចិត្តទៀតទៅហើយ ។ ម៉ាក់ស្រឡាញ់កូនយ៉ាងណានោះកូនដឹងច្បាស់ណាស់ ។ កូនគ្មានអីតបស្នងម៉ាក់ទេ មានតែការធ្វើអោយម៉ាក់សប្បាយចិត្ត និងមានមោទនភាពដោយសារកូនទេ ។ យើងមានតែពីរនាក់ទេ ។ កូនធ្វើបានតែប៉ុណ្ណឹងឯង ។»

«ប៉ុណ្ណេះគ្រប់គ្រាន់ណាស់ទៅហើយ ។»

លោកជំទាវពោលទាំងចិត្តថ្លើមរីកណែនទ្រូង ។ ពិធីប្រគល់សញ្ញាប័ត្រប្រព្រឹត្តទៅលុះចប់ ហើយនិស្សិតទាំងអស់នាំគ្នាថតរូបជុំគ្នាដោយរីករាយ ។

***

ក្រោយពិធីទទួលសញ្ញាប័ត្រ នរិនហៅមិត្តភ័ក្រស្និទ្ធស្នាលប៉ុន្មាននាក់មកមកជប់លៀងនាពេលល្ងាចនៅភោជនីយដ្ឋានប៊ូហ្វេទន្លេ ដ៏ទំនើបមួយនៅម្តុំវត្តឧណ្ណាលោម ។ ម្តាយអ្នកមិនមកចូលរួមទេព្រោះលោកចង់អោយក្មេងៗសប្បាយ

តាមទំនើងរបស់គេ ។ ក្រោយប៊ូហ្វេគេនាំគ្នាទៅច្រៀងខារ៉ាអូខេ លុះយប់ជ្រៅបន្តិចគេនាំគ្នាទៅតនៅរង្គសាល រ៉ុកស្តា នៅម្តុំបឹងត្របែក ។ គេរាំលេងសប្បាយរហូតយប់ជ្រៅទើបបញ្ចប់កម្មវិធី ។

«អោយគ្នាបើកឡានវិញព្រោះពួកឯងស្រវឹងអស់ហើយ ។»

នរិននិយាយទៅកាន់មិត្តភ័ក្រទាំងប្រាំ ។

«ប្រជ្រៀតគ្នាបន្តិចទៅ ។ វាសនា វិរៈ ឧត្តម និង ប្រណិត ឯងអង្គុយក្រោយទៅ ។ តារា ឯងអង្គុយមុខ ជាមួយគ្នា ។»

«គ្នាមិនស្រវឹងទេ នរិន ។»

ប្រណិតប្រកែក ។

«មនុស្សស្រវឹងមិនដែលថាខ្លួនស្រវឹងទេ ។ នេះជាអាការៈដំបូងរបស់ការស្រវឹង ។»

នរិនតប ។

«ចុះឡានយើង?»

វិរៈសួរ ។

«ក្រែងយើងមកឡានពីរហ៎ស?»

«មិនអីទេ ចាំទៅដល់ផ្ទះចាំអោយស្វហ្វ័រវិរៈឯងជិះម៉ូតូឌុបមកយកក៏បានដែរ ។ ធ្វើអ៊ីញ្ចឹងសុវត្ថិភាពជាង ។ គ្នាមិនចង់អោយថ្ងៃសប្បាយចប់ទៅដោយការស្តាយក្រោយទេ ។ មានរឿងអីទៅ កាសែតចុះថាពួកយើងទំនើងប្រណាំងឡាន យប់ព្រលប់ មិនចេះគិតគូរជនរួមផ្លូវដទៃទៀត ។»

មិត្តទាំងអស់ព្រមតាមយោបល់នរិន ។

ទម្រាំដាក់មិត្តភ័ក្តតាមផ្ទះអស់ ម៉ោងជាងមួយទៅហើយពេលវិលមកដល់ផ្ទះខ្លួនវិញ ។ ម៉ាក់អ្នកចូលសម្រានត្តស្ងាត់ហើយ ។ នរិនចូលទៅងូតទឹកហើយទម្លាក់ខ្លួនលើគ្រែលង់លក់យ៉ាងរហ័ស ។

***

ស្អែកឡើងថ្ងៃអាទិត្យ ។ នរិនភ្ញាក់និងសំលេងគោះទ្វារស្រាលៗ ។ អ្នកស្រវ៉ាយកទូរស័ព្ទណូគៀរបស់អ្នកមកមើលម៉ោង ឃើញម៉ោងប្រាំបួនទៅហើយ ។ ទូរស័ព្ទជិតអស់ថ្មទៀតព្រោះមិនបានសាកកាលពីយប់ ។

«អ្នកណាហ្នឹង?»

អ្នកសួរទាំងមិនទាន់ស្វាងងងុយនៅឡើយ ។ អ្នករាវរកខ្សែសាកយកមកដោតទូរស័ព្ទ ។

«គឺមីងណ៎ ។»

ម៉ែដោះឡា និយាយ ។

«លោកស្រីអោយមកតាមក្លួយទៅទទួលទានអាហារពេលព្រឹកជុំគ្នា ។ លោកមិនទាន់ពិសារទេ កំពុងពិសារតែរង់ចាំក្លួយ ។»

នរិនស្ទុះស្ទារក្រោកឡើង ។ អ្នកស្រែកឮៗថាៈ

«ប្រាប់ម៉ាក់ថាខ្ញុំសុំ ប្រាំនាទីលុបមុខមាត់នឹងស្លៀកពាក់បន្តិច ។»

ថាហើយនាយដើរប្រយុយចូលបន្ទប់ទឹក ។

ម៉ែដោះឡា ឆ្លើយទទួលហើយដើរចេញបាត់ទៅ ។

«ម៉ាក់»

នរិនស្វាគមន៍ម្ដាយខ្លួន ដោយហៅលោកតាមទម្លាប់ ។
«សុំទោស អោយម៉ាក់ចាំយូរ»
«មិនអីទេកូន ។»
លោកស្រីឆ្លើយ ហើយធ្វើដៃអោយតីដួសអាហារដាក់ចាន ។
«យប់មិញម៉ោងប៉ុន្មានមកផ្ទះ?»
«ម៉ោងមួយជាងឆណោះ ព្រោះត្រូវជូនពួកហ្នឹងទៅផ្ទះវារាងខ្លួន ។ វាស្រវឹងគួរសម ។ កូនមិនសូវស្រវឹងជាអ្នកអាសារជូនគេទៅ ។»
នរិនអង្គុយចុះមុខម្ដាយ ។ តុធំវែងធ្វើពីឈើក្រញូងរលោងស្រិលខ័ណ្ឌអ្នកទាំងពីរ ។ នរិនអង្គុយស្រលប្លួលហើយទទួលចានបបរពីតី ។ នៅកណ្ដាលតុ ខត្រីរស់ ជ្រក់ស្ពៃ ខ្ទឹមជ្រក់លាយបង្គារក្រៀម នឹងត្រីងៀតត្រីរស់អាំងហើយដំយ៉ាងទក់ចេញសរសៃដែលអ្នកចូលចិត្តកំពុងហុយ ចោលក្លិនឈ្ងុយគួរអោយចង់ទទួលទាន ។
«ស្រវឹងកុំបើកបរណាកូន ។»
លោកជំទាវដាស់តឿន ។
«សប្បាយត្រូវគិតពីខ្លួនឯងនឹងអ្នកជុំវិញខ្លួនផង ។ កុំអោយមានវិប្បដិសារិយ៍បើមានអពមង្គលអីទៅ ។ បើស្រវឹងខ្លាំងហៅ ណ័ប់ អោយទៅយកទៅ ។»
ណប់ជាសូហ្វ័រប្រចាំគ្រួសាររបស់នរិន ។ ណប់នៅជាមួយគេយូរណាស់ហើយ តាំងពីឆ្នាំ ១៩៩៣ មកម្ល៉េះ ។ គឺតាំងពីគេរំសាយពីយោធាម៉ិក ។ ណប់ចំណាប់អោយគួរអោយទុកចិត្តបានណាស់ ទោះបីជាអាយុជិតហាសិបហើយក៏នៅមាំទាំដូចសាមសិបអញ្ចឹង ។
«បាទ ម៉ាក់ ។ ខ្ញុំដឹងតើ ។ តែខ្ញុំនៅគ្រងស្មារតីខ្លួនឯងបាន ទើបមិនរំខានពូ យប់ព្រលប់អញ្ចឹង ។»
« ញ៉ាំទៅកូន»
«បាទ ម៉ាក់»
ហើយអ្នកងាកទៅ អ្នកនៅជាមួយដែលឈរនៅជ្រុងបន្ទប់រងចាំក្រែងមានអ្វីខ្វះខាត ឬអាចជួយបាន ។
«បងតី ជួយឆុងតែក្ដៅចត់អោយមួយពែងមក ។ សុំយកពែងស្កមកផង ព្រោះខ្ញុំស្រេកអីផ្អែមៗ»
នាយចាប់ផ្ដើមកូរបបរអោយត្រជាក់បន្តិច ។
«ចាស» តីឆ្លើយទទួល ហើយរួសរាន់ទៅ ។ មួយសន្ទុះក៏យកអ្វីដែលនរិនត្រូវការមកតាមបំណង ។ នរិនងាកទៅអរគុណតី ហើយ ពីរនាក់ម៉ែកូនបន្តទទួលទានបបរដោយស្ងាត់ស្ងៀម ។

លុះអាហារពេលព្រឹកហើយ លោកស្រីសួរបុត្ររបស់លោកថា៖
«ធ្វើអីទៀតចប់បរិញ្ញាហើយ?»
«មិនដឹងដែរម៉ាក់ ។ មិនទាន់គិតថាយ៉ាងណាអោយច្បាស់នៅឡើយផង ។»
«ចង់រៀនតភ្លាម ឬធ្វើការមួយរយៈសិន?»
«ចង់សំរាក ដើរលេងបន្តិច ហើយធ្វើការមួយរយៈសិន សឹមរៀនទៀត ។ អោយវាស្រឡះខួបន្តិច ។»
«ដើរលេង? គិតចង់ដើរលេងយ៉ាងម៉េចហ្នឹង? ក្នុងស្រុកឬបរទេស?»
«លើកនេះចង់ដើរលេងក្នុងស្រុកជាង ព្រោះចង់ស្គាល់ស្រុកយើងអោយច្បាស់មុនពេលទៅរៀនស្រុកគេ ។»
«កូនចង់ទៅខាងណា?»
«កំពត កែបអីខាងហ្នឹងណាម៉ាក់ ។ ខ្ញុំមិនសូវបានស្គាល់ខាងហ្នឹងច្បាស់សោះ ។ ចង់ទៅលេងជ្រោះពពកវិលនឹងកោះទន្សាយផង ។»

«ម៉ាក់មានមិត្តភ័ក្តម្នាក់នៅកំពត ។ កាលមុនគេជាអ្នកជំនួញធំមួយនៅភ្នំពេញនេះ តែក្រោយមកដល់វ័យចូលនិវត្តន៍ទៅ លោកប្រគល់ជំនួញទាំងអស់ទៅកូនច្បងរបស់លោកម្នាក់ឈ្មោះ វិទ្យា ។ លុះវិទូកូនពៅលោករៀនចប់កសិកម្មនៅចំការដូងហើយក៏លែងចង់ទៅរៀនឯណាទៀត បែជាចង់ធ្វើចំការវិញ លោកក៏ទិញចំការម្រេចមួយធំណាស់នៅកំពត ហើយទៅធ្វើផ្ទះនៅទីនោះជាមួយភរិយានិងបុត្រពៅលោក ។ តាមម៉ាក់ដឹង វិទូរមានអាយុដំណាលកូនដែរ ។ កូនទៅនៅលេងនឹងស្នាក់នៅជាមួយលោកមួយរយៈទៅ ។ លោកធ្លាប់អញ្ជើញម៉ាក់ទៅលេងច្រើនដងណាស់ តែម៉ាក់មិនដែលមានពេលសោះ ។ ម៉ាក់គិតថាលោលមិនយល់ទាស់អីទេបើកូនទៅក្នុងនាមម៉ាក់ ។ កូនដើរអស់ចិត្តហើយចាំមកជួយការងារម៉ាក់ ឬរកការងារខ្លួនឯងធ្វើក៏បាន ។»

លោកស្រីរៀបរាប់ក្បោះក្បាយ ហើយស្នើរយោបល់អោយបុត្ររបស់លោកព្រោះដឹងចិត្តបុត្រលោកថាចូលចិត្តធម្មជាតិ នឹងដំណើរកំសាន្តបែបផ្សងព្រេង ។

«ល្អណាស់ម៉ាក់ ។ ម៉ាក់មេត្តាជួយរៀបចំផងទៅចឹង ។ បើអាចខ្ញុំទៅស្អែកហ្នឹងហ្មង ។»

«មានអី ។»

«អរគុណម៉ាក់»

***

# ត្រាជួប

ចំការវិទូធំណាស់ ហើយរៀបចំយ៉ាងទំនើបទាន់សម័យ ។ ដីជាងដប់ប្រាំហិចតាតាមផ្លូវទៅទីក្រុងកែប លាតសន្ធឹងទៅជាប់និងជើងភ្នំ ។ វិឡាតឿមួយសង់កណ្ដាលចំការដ៏ល្វឹងល្វើយនេះ ។ ផ្លូវចាក់បេតុងទំទឹងប្រហែលបីម៉ែត្រភ្ជាប់វិឡានេះទៅនឹងថ្នល់ជាតិ ។ វិទូមានម៉ូតូកង់បួនមួយគ្រឿងសំរាប់ជិះក្នុងចំការ មើលកម្មករ ។

តាំងពីនរិនមកស្នាក់នៅប៉ុន្មានថ្ងៃមកហើយ ទាំងពីរនាក់តែងទៅមើលចំការជាមួយគ្នា ។ នរិនសុំស្ម័គ្រខ្លួនបើកម៉ូតូដែលមានកង់ធំៗនោះ ។ ព្រឹកមួយថ្ងៃពុធពីរថ្ងៃបន្ទាប់នរិនមកដល់ អ្នកទាំងពីរមកមើលកម្មកររៀបចំពង្រីករងម្រេចដូចសព្វដង ។ នរិនបើកម៉ូតូ ដោយមានវិទូអង្គុយពីក្រោយ ។ ម៉ោងប្រហែល ៩ កន្លះហើយ ។

«វិទូ ចំការឯងម៉េចស្ងាត់ត្រង់នេះអញ្ចឹង?»

នរិនអត់សួរមិនបានពេលមកដល់ដីរួមតូចខណ្ឌដោយរបស់ឈើគ្រាក់ចាស់ៗ ដែលម្ខាងរបងឯណោះក៏ជាដំណាំម្រេចខ្លះដែរ ។

«ម៉េចឯងមិនទិញយកចំការនេះដែរពង្រីកដីអោយធំស្មើរទៅ?»

ទាំងពីរនាក់ចុះពីម៉ូតូកង់បួន ពន្លត់ម៉ាស៊ីន ហើយដើរមើលជន្លង់ម្រេចដែលរត់ជាជួរត្រង់ភ្លឹងដាច់កន្ទុយភ្នែក ។

«ខ្ញុំធ្លាប់គិតថាមានលុយអាចទិញ គ្រប់យ៉ាងបាន ។»

វិទូឆ្លើយបណ្ដើរ ដើរបណ្ដើរ ទន្ទឹមនរិន ។

«ខ្ញុំពិតជានៅស្មើរសេចក្ដីណាស់កាលគិតអញ្ចឹងនោះ ។ ដីមួយឡូត៍នេះជារបស់លោកអ៊ុំ ឆវ៉ា នឹងភរិយាគាត់សុភី ។ ថ្វីបើគ្រួសារគាត់មិនសូវជាធូធារមែន គាត់មិនមើលលុយដែលពួកយើងស្នើរទិញពីគាត់ទេ មិនថាយើងហ៊ានដល់ថ្លៃហើយក៏ដោយចុះ ។ គាត់ថាគាត់ទុកចែកកូនៗគាត់ដែលគ្នាមិនមានលទ្ធភាពបានរៀនជ្រៅជ្រះ ។ គាត់ថាពួកគេចេះតែចំការមួយមុខទេ ។»

«គាត់មានកូនប៉ុន្មាននាក់ដែរ?»

នរិនសួរ ដៃទាញ ត្រួយម្រេចមួយទងដែលលូតខុសជន្លង់មករ័ន្ធជាមួយដើមវាវិញ ។

«ប្រាំនាក់ បើតាម៉ខ្ញុំដឹងពីពួកកម្មករ ។ ខ្ញុំមិនដែលឃើញពួកគេទាំងអស់គ្នាទេ ឧស្សាហ៍ឃើញតែកូនប្រុសគាត់ម្នាក់ឈ្មោះរិទ្ធដែលមកកាប់ឆ្ការនិងថែទាំស្មៅរងម្រេចនឹងដាំដំណាំវាយរងផ្សេងៗ ។ គាត់ជាមនុស្សល្អណាស់ ។ មិនសូវចេះនិយាយលេងទេ ។ សួរអីឆ្លើយហ្នឹង ។ យើងអាចជួបគាត់ថ្ងៃនេះផងក៏មិនដឹង ។»

ហើយគេដើរវាងគ្នាទៅម្ខាងរងម្រេចម្នាក់ទៅ ។ វិទូរបន្តរៀបរាប់ថា៖

«ឮថាលោកអ៊ុំឆរ៉ាមានកូនស្រីគាត់ម្នាក់ជាកូនទីបីធ្វើការនៅសណ្ឋាគារភ្នំខៀវឯទីរួមខេត្តឯណោះ ។ ខ្ញុំមិនដែលឃើញនាងទេ ។ កូនពៅគាត់ពីរនាក់ប្រុសៗឮថាទៅរៀនមហាវិទ្យាល័យនៅភ្នំពេញ ។ ពួកគេស្នាក់នៅវត្តលង្កា បើតាមគេប្រាបខ្ញុំ ។ ខ្ញុំដឹងតែប៉ុណ្ណឹងឯង ។ ខ្ញុំមិនពូកែខាងរាប់ញាតិទេ ។»

ដើរបណ្តើនិយាយបណ្តើរពួកគេមកដល់ទីដែលកម្មករជាង ១០ នាក់កំពង់លើករង នឹងរៀបចំជន្លង់ ។ ម្នាក់កំពុងរៀបតម្ប៉ូទ័រ ស្រោច បូមទឹកពីត្រពាំងមួយធំគួរសម ដែលវិទូអោយគេជីកខាងក្រោយចំការ ។ ទាំងពីរឃើញហើយចុះទៅជួយមួយដៃមួយជើង ។

ប្រហែលមួយម៉ោងក្រោយមក នរិនដែលមិនទម្លាប់ការងារហាលថ្ងៃបែកញើសស្រាក់ ដង្ហក់គឃ្លូរ ។ អ្នកសម្រាក ហើយដើរមករកធុងទឹកដែលមានដបទឹកក្លាសេ ។ អ្នកបើកយកមួយដបមកទទួលទានហើយស្រែកទៅវិទូ ។

«វិទូ គ្នាដើរលេងទៅក្រោយចំការបន្តិចហើយណា ។»

«ទៅចុះបង»

វិទូស្រែកមកវិញ ។ នរិនដើរលេងៗបត់ចុះបត់ឡើងក៏ស្រាប់តែមកដល់ព្រំចំការរបស់លោកអ៊ុំឆរ៉ាល្មម ។ នាយឮស្នូរកាប់ដីគិបៗក៏ដើរតម្រង់ទៅ សង្ឃឹមថានឹងជួបម្ចាស់ចំការ ។ បុរសវ័យកណ្តាលម្នាក់កំពុងកាប់រណ្តៅមួយធំល្មម ។ គាត់មានមាឌតូចទេ កាត់សក់ខ្លី នឹងមានសម្បុរខ្មៅស្រគាំដោយត្រូវថ្ងៃ ។ កូនចេកប៉ុន្មានដើមដេករៀងគ្នាក្បែររណ្តៅនោះ ។

«ជំរាបសួរបង»

នរិនដើរទៅឈរក្បែរបងហើយស្រែកសួរពីចម្ងាយ ។

«អូ បាទ ជំរាបសួរ ។ ស្មានតែវិទូទេតើ ។»

បុរសអ្នកចំការងើបមុខហើយឆ្លើយតបវិញ ។

«មិនមែនទេ ។ ខ្ញុំនរិន ។ ម្តាយខ្ញុំនឹងឪពុកម្តាយវិទូជាមិត្តភ័ក្រ្កគ្នា ។ ខ្ញុំមកលេងកំពត ហើយស្នាក់នៅជាមួយគ្រួសារវិទូ មួយរយៈ»

«អូ ចឹងហ៎ ។»

«បងឈ្មោះវិទ្ធមែនទេ?»

«បាទ»

វិទ្ធស្ងាត់មាត់ហើយបន្តការងាររបស់គាត់ដូចដើម ។

ដូចវិទូថាមែន ។ វិទ្ធមិនសូវនិយាយច្រើនទេ ។

«ដាំចេកអីដែរហ្នឹងបង?»

«ចេកពងមាន់ ។»

ហើយវិទ្ធយកកូនចេកទម្លាក់រណ្តៅដែលកាប់ហើយ ហើយយកជើងកាយដីលប់វិញ ។

មាណពរៀបនឹងសួរទៀតទៅហើយស្រាប់តែ ...

«បងវិទ្ធៗ»

សំឡេងស្រួយស្រេះមួយបន្លឺពីម្ខាងចំការរបស់វិទ្ធមមក ។ នរិនងាកទៅរកប្រភពសំឡេង ស្តាប់វាចាបន្តរបស់ម្ចាស់វាៈ

«រ៉ឺម៉កចេកមកដល់ទៀតហើយ គេទម្លាក់នៅមុខផ្ទះឯណោះ ។ បងអោយខ្ញុំជួយជញ្ជូនមកក្រោយនេះឬក៏ទុកនៅមុខផ្ទះហ្នឹងទេ? មានដីដាំអស់ទេបងខាងក្រោយហ្នឹង»

នរិនយល់នារីក្មេងម្នាក់ក្នុងវ័យប្រហែល ២០ ឆ្នាំ មានសក់ខ្មៅរលោងវែងគ្រប់ខ្នង ។ មុខនាងមូលទ្រវែង ចង្ការស្រួចបន្តិច ។ ច្រមុះមានខ្ពង់តូចល្មមសមភ្នែកអ្នកមើល ។ នាងមានសម្បុរស្រអែមជ្រះ គ្រងដោយអាវដៃខ្លីពណ៌ផ្ទៃមេឃ នឹងខោខ្មៅរបាងត្រឹមស្មងជើង ។

«ទុកនៅហ្នឹងហើយ ឆដា ។» វិទូស្រែកតប ។

នារីដើរមកដល់ល្មម ។

«ឆដា នេះនរិន ជាមិត្តភ័ក្ររបស់វិទូ ។ នរិននេះឆដាប្អូនស្រីខ្ញុំ ។»

នរិនញញឹមអោនក្បាលបន្តិចសំម្តែងការគួរសម ។ នារីញញឹមតប បង្ហាញធ្មេញសស្អុះ នឹងខួចថ្ពាល់ខាងស្តាំបន្តិចផង ។ នរិនភ្លឹកនឹងសម្រស់បុប្ផាចំការម្រេចម្នាក់នេះ ។ បបូរមាត់មិនស្តើងមិនក្រាស់របស់នាងជួយអោយនាងញញឹមស្រស់ណាស់ ។ រង្វង់មុខពងក្រពើររបស់នាងធ្វើអោយនាយលួចមើលនាងហើយមើលទៀត ។ វិទូងាកទៅដាំចេកគាត់បង្ហើយទុកអោយយុវជនទាំងពីរនាក់ជជែកគ្នាលេង ។

«ឮវិទូប្រាប់ថា ឆដាធ្វើការនៅសណ្ឋាគារភ្នំខៀវឯទីរួមខេត្តឯណោះមែនទេ?»

នរិនសួរ ។

«ចាសបង»

«អត់ធ្វើការទេថ្ងៃហ្នឹង?»

«ថ្ងៃពុធ និងថ្ងៃអាទិត្យជាវេនខ្ញុំសំរាក ។ បងអ្នកភ្នំពេញមែនទេ?»

ឆដាសួរ ខណៈជួយយកដើមចេកអោយវិទូ ។

«បាទ ។ ខ្ញុំមកលេងកំពតលើកនេះ មានបំណងចង់ទៅលេងភ្នំបូកគោ នឹងជ្រោះពពកវិលនៅថ្ងៃអាទិត្យនេះតែវិទូថាគ្នាតិចទៅមិនសូវសប្បាយទេ ។ វិទូគេបបួលបានមិត្តភ័ក្តគេពីរនាក់ទៅដែរ ហើយខ្ញុំចង់អញ្ជើញបងវិទូ នឹងឆដាទៅដែរ ។ បើអ៊ុំប្រុស អ៊ុំស្រីមិនយល់ទាល់ទេខ្ញុំក៏ចង់អញ្ជើញពួកគាត់ទៅដែរ គ្រាន់បានស្គាល់គ្នាម្តង ព្រោះឮថាតាំងពីវិទូរៀនចប់ មកនៅជួយប៉ាម៉ាក់គេដែលទិញដីធ្វើចំការនៅទីនេះ វិទូមិនទាន់មានឱកាសរាប់អានអ្នកជិតខាងណាអោយបានល្អទេ ។ ចំការធំពេកចឹងឯង ។»

«មិនដឹងទេ បងសួរបងវិទូទៅ ។ ថ្វីបើខ្ញុំជាអ្នកកំពត ខ្ញុំមិនដែលទៅលេងភ្នំបូកគោទេ ។ គេថាផ្លូវពិបាកទាល់តែមានឡានខ្លាំងទើបទៅបាន ។»

«ម៉េចដែរបងវិទូ?»

នរិនងាកទៅសួរវិទូដែលកំពុងបង្ហើយការ ។

«បងចាប់អារម្មណ៍តើ តែចាំបងទៅពីគ្រោះជាមួយពុកម៉ែសិន ប្រហែលជាលោកចង់ទៅដែរដឹងព្រោះធ្លាប់ឮថានឹក ខានទៅលេងបូកគោយូរហើយ ។ គាត់ធ្លាប់ទៅតាំងពីសង្គមម្ល៉េះ ។ តោះបងរួចដែល្មម ប្អូននរិនចូលមក ទៅលេងផ្ទះបង ហើយជំរាបសួរពុកម៉ែអោយបានស្គាល់គ្នាទៅ បំណាច់មកហើយ ។»

«ល្អតើបង»

នរិនតប ហើយមុជក្រោមរបងលួសបន្លាចូលទៅចំការរបស់វិទូ ។ ឆដាដើរទៅមុន នាំផ្លូវ ។

«ដីបងប៉ុន្មានហិចតាដែរ?»

នរិនសួរវិទូដែលដើរទន្ទឹមខ្លួន ។

«តែពីរហិចតាទេប្អូន»

«បងដាំម្រេចទាំងអស់មែនទេ?»

«អត់ទេ ។ ម្រេចពិបាកថែណាស់ ហើយអោយផលមិនទៀងទៀត ។ បងដាំដំណាំតាមរដូវខ្លះ គ្រាន់លក់ចិញ្ចឹមឆ្នាំង ប្រចាំថ្ងៃ។ ខាងណោះមានត្រាវ នឹងដំឡូង ។ មានពោតខ្លះ នឹងមានសណ្តែកកួរខ្លះ ខាងណោះត្រប់វែង នឹងពុតញង ។ ចេះតែផ្សុំគ្នាទៅ ប្អូនអើយ»

ភ្លែចៗខ្លួនទាំងបីនាក់មកដល់ផ្ទះឈើពីរខ្នងផុតពីដីមួយ ដែលមានចំណាស់គួរសមដែរហើយមើលទៅ ។ ផ្ទះជញ្ជាំងក្តា ម៉ានដំបូលស័ង្កសី មានប្រៃសស៊ីដោយកន្លែង ។

ក្រោមផ្ទះមានគ្រែឫស្សីធំមួយ នឹងមានអង្រឹងពីរ មួយៗចងពីរសរសរមួយទៅសរសរមួយទៀត ។

វិទ្ធដាក់ចបចុះ អញ្ជើញនរិនអោយអង្គុយលេងឯគ្រែ ហើយទៅលាងដៃលាងជើងឯពាងធំមួយដែលចាំទទួលទឹកពីទរ ពេលណាមានភ្លៀង ។ ក្បែរពាង អំពៅក្រឡាន់មួយគុម្ពជាងដប់ដើម កំពស់លិចក្បាល មួយដើមៗធំប៉ុនកជើង ។

«ខ្ញុំទៅហៅពុកនឹងម៉ែអោយ ។ លោកប្រហែលកំពុងស្តាប់ធម៌ទេសនាតាមវិទ្យុលើផ្ទះហើយព្រោះជាថ្ងៃសីលផង»

ឆដានិយាយហើយឡើងទៅលើផ្ទះបាត់ ។ វិទ្ធហើយដៃ ដើរទៅក្រោយយកកង្វារមកខ្វារដូងមួយធ្លាយមកកាប់ទទួលភ្ញៀវ ។

នរិន ក្រឡេក មើលការរៀបចំជុំវិញផ្ទះឃើញថាសាមញ្ញហើយមានរបៀបណាស់ ។ ក្បែរផ្ទះ ម្ទេសជាជួរផ្លែពេញដើមមានក្រហមមានបៃតង ចង្អុលមេឃព្រោងព្រាត ។

«ណេះប្អូនញ៉ាំដូងទៅ»

វិទ្ធហុចដូងទើបកាប់ថ្មីអោយមាណព ។

«អរគុណបង»

ហើយអ្នកលើកវាក្រេបបន្តិច ។

«យី ផ្អែមណាស់បងដូងនេះ»

«ដូងភ្លើង ។ ជាទូទៅផ្អែមគួរសម ។»

លុះនរិនឮស្គរជើងចុះជណ្តើរ នាយក៏ងាកទៅឃើញបុរសចំណាស់ម្នាក់អាយុប្រហែលហុកសិបឆ្នាំប្លាយកំពុងចុះជណ្តើរមកដោយប្រយ័ត្នប្រយ៉ែង ។ តាមពីក្រោយគាត់គឺស្ត្រីចំណាស់ម្នាក់វ័យស្របាលគ្នា ។ អ្នកទាំងពីរមើលទៅមាំទាំគួរសម ។

នរិនងើបឈរឡើង លុះលោកទាំងពីរចុះរួចរាល់ហើយ នាយសំពះសម្តែងការគួរសម ។

«ជំរាបសួរអ៊ុំប្រុស អ៊ុំស្រី»

«ថ្វាយព្រះក្មួយ ។»

បុរសចំណាស់និយាយ ។

«អញ្ជើញអង្គុយទៅ ក្មួយ ។»

ហើយលោកងើយទៅលើផ្ទះរួចឧទានខ្លាំងៗថា ៖

«ឆដា យកតែពុកនឹងពែងបីបួនពីក្នុងទូមកក្រោមមកកូន ។»

«ចា៎ស ពុក»

«ក្មួយទៅណាមកណាដែរ»

ស្រីចំណាស់សួរបន្ទាប់ពីក្រាលកន្ទេលកក់លើគ្រែឫស្សី ហើយទំលាក់ខ្លួនអង្គុយចុះ ទាំងមិនភ្លេចវាដៃអោយភ្ញៀវក្មេងអង្គុយដែរ ។

«ខ្ញុំមកពីភ្នំពេញ មកលេងកំពតហ្នឹង ហើយស្នាក់នៅជាមួយវិទូ ។»

នរិនតបបន្ទាប់ពីទម្លាក់ខ្លួនអង្គុយគែមគ្រែសំយ៉ុងជើងចុះក្រោម ។

«ព្រឹកមិញនេះដើរកាត់ចំការឃើញបងវិទ្ធកំពុងដាំចេកហើយក៏សួរនាំគាត់លេងអោយបានស្គាល់គ្នា ។ និយាយចឹង ថ្ងៃអាទិត្យនេះវិទូ នឹងខ្ញុំមានគំរោងទៅលេងបូកគោជាមួយវិទូនឹងមិត្តភ័ក្តិពីរបីនាក់ ។ វិទូគេថាគ្នាតិចមិនសូវសប្បាយទេ ។ ខ្ញុំក៏មានបំណងចង់អញ្ជើញលោកអ៊ុំទាំងពីរ នឹងគ្រួសារទៅគ្រាន់បានជាគ្នា នឹងដើម្បីរាប់អានគ្នាស្គាល់គ្នាផង ។ ណាមួយឮបងវិទ្ធថាលោកអ៊ុំធ្លាប់ទៅលេងបូកគោកាលពីសង្គម ខ្ញុំក៏ចាប់អារម្មណ៍ក្រែងបានអ៊ុំដំណាលប្រាប់ពីអតីតកាលរបស់បូកគោខ្លះអោយដឹង ។ ឮថាពីសង្គមទីនោះសប្បាយណាស់ ។»

ចាស់ៗទាំងពីរមើលមុខគ្នាញញឹមៗ ហើយ អ៊ុំប្រុសនិយាយថា ៖

«ត្រូវម៉ាច់ក្មួយ អ៊ុំកំពុងចង់ទៅលេងម្ដងទៀតផង ។ មុនស្លាប់ទៅចង់ទៅអោយបានស្គាល់ទីដ៏មនោរម្យនេះម្ដងទៀត ។ ម៉េចដែរម៉ែវ៉ា? ។»

«មានអីឪវ៉ា ខ្ញុំតាមតែឯងទេ ។»

ឆដាលើកតែមួយប៉ាន់មកល្មម ។ តែក្ដៅៗ នឹងពែងបួន ។

ចាក់តែបណ្ដើរ អ៊ុំប្រុសបន្តបណ្ដើរហាក់ពីគ្រោះជាមួយភរិយាគាត់ថា៖

«អោយឆពុំមកចាំផ្ទះទៅ អោយរិទ្ធនឹងឆដាទៅជាមួយយើងដែរ ។ ចឹងបួននាក់ទាំងអស់ ។»

ហើយគាត់ងាកមកនរិន ។

«មានកន្លែងជិះគ្រប់សំរាប់បួននាក់ទេក្មួយ?»

«បាទមាន ។ រិទ្ធគេយកឡង់គ្រីស័ររបស់ប៉ាគេទៅ ។ ខ្ញុំមានរថយន្តរបស់ខ្ញុំដែរ ពីរគ្រឿងគ្រប់ល្មម ។

បន្ទាប់ពីហ្នឹង ការសំណេះសំណាលក៏ចេះតែមានហូរហែរទៅ ។ នរិនពូកែចូលចំណោមមនុស្សចាស់ណាស់ ។ ចរិកចង់ដឹង នឹងពូកែស្ដាប់របស់នាយ គួរជាទីចូលចិត្តរបស់ចាស់ៗណាស់មិនថាក្រុងឬស្រែចំការទេ ។ គួបផ្សំចរិកនាយចូលចិត្តផ្សងព្រេងនឹងមានបទពិសោធន៍ដើរហើរច្រើនផង នាយដឹងរឿងច្រើនល្មមដោះដូរមិនអោយបរិយាកាសស្ងប់ស្ងាត់បាន ។

ឆដាវិញអង្គុយស្ដាប់ការសន្ទនាដោយស្ងាត់ស្ងៀម ។ យូរៗនារីលូកមាត់ម្ដង ។

ពេលនាងនិយាយ នរិនស្ដាប់ នឹងមើលមុខនាងជាប់ជាពិសេសពេលអ៊ុំប្រុស អ៊ុំស្រីប្រហែស ។ ដល់ញយទៅធីតាដឹង នាងអៀនមុខឡើងក្រហម លើកសម្រស់នាងកាន់តែស្រស់មួយកំរិតទៀត។

លោកអ៊ុំឆវ៉ាឃាត់អោយនរិននៅញុំាបាយផ្ទះគាត់មួយពេល តែនរិន ប្រកែកព្រោះមិនបានប្រាប់អ្នកផ្ទះរបស់រិទ្ធជាមុន ។ គេសន្យាថ្ងៃក្រោយពេលមកពីបូកគោ និងមុនទៅភ្នំពេញវិញគេសុំមកផ្ញើរពោះមួយពេលផង ។

ពេលរិទ្ធ ទូរស័ព្ទរកគេ គេក៏ជំរាបលា ហើយដើរបកទៅក្រោយចំការវិញ ។

គេប្រាប់គ្រប់យ៉ាងដល់រិទ្ធពេលជិះម៉ូតូទៅផ្ទះធំកណ្ដាលចំការ ។

«បងនរិនពូកែរាប់ញាតិមែន ។ មកមិនទាន់បានប៉ុន្មានថ្ងៃផង ស្គាល់អ្នកជិតខាងមុនខ្ញុំនឹងគ្រួសារដែលនៅទីនេះរាប់ឆ្នាំទៅទៀត ។»

នរិនមិនស្ដី ។

អ្នកនឹកតែពីរង្វង់មុខដ៏ស្រទន់របស់ឆដា ថ្ពាល់ក្រពុំ នឹងស្នាមខ្ទួចដ៏ទាក់ទាញ ។

យី ចិត្តអ្នកម៉េចអិញ្ចេះ អ្នកដណ្ដឹងសួរខ្លួនឯង ។

***

# អនុស្សាវរីយ៍

ឆ្លងស្ពានកន្ទួ ជាស្ពានថ្មចាស់ជំនាន់បារាំងដែលសណ្តូកខ្លួនកាត់ទទឹងព្រែកកំពតបន្តិចមក រថយន្តទាំងពីរគ្រឿងបោលលឿនស្លេវតាមផ្លូវជាតិលេខបីដែលសន្ធឹងខ្លួនពីកំពត់ទៅទីរួមខេត្តកំពង់សោម ឬ ក្រុងព្រះសីហនុ ។

ម៉ោងទើបប្រាំមួយទៃ ព្រះអាទិត្យខែតុលា ចែងចាំងរស្មីចិញ្ចែង ។ ផ្លូវស្ងាត់មនុស្ស មានតែអ្នកលក់បន្លែដឹកបន្លែតាមកង់ខ្លះ ម៉ូតូខ្លះចូលទៅក្រុងកំពតវិញ ។ យូរម្តងមានតាក់ស៊ីមួយៗដែលមានដឹងអីវ៉ាន់សំពីងសំពោងបោលលឿនដូចព្យុះចេញពីទីរួមខេត្តកំពត់ ទៅក្រុងព្រះសីហនុ ។ ផ្លូវជាតិលេខបីឆ្នាំ ២០០០ នៅគ្រួសក្រហមខ្លះ នឹងកៅស៊ូខ្លះ ជាអន្លើដែលសេសសល់តាំងពីសង្គមម៉ក ។

ផ្ទះអ្នកស្រុករប៉េះរប៉ោះដង្ហែរតាមផ្លូវ ។ ជួនគេឃើញក្មេងតូចៗរត់លេងក្រោមដើមស្វាយមុខផ្ទះខ្លះ ខ្លះលែងខ្លួនទទេរ មិនមានអាវទេ ខ្លះមិនមានមានទាំងខោតែម្តង ។

ភ្នំបូកគោដែលមានកំពស់ ១០៧៥ ម៉ែត្រ មានចំងាយតែ សែសិបពីរគីឡូម៉ែត្រប៉ុណ្ណោះពីទីរួមខេត្ត ។ ចម្ងាយនេះបើគិតត្រង់តាមរបៀបសត្វហើរ មិនរាប់ពីផ្លូវវាងកាច់កុងគឺតែប្រហែល ២០ គីឡូម៉ែត្រប៉ុណ្ណោះ ។ បូកគោគឺជាកំពូលមួយរបស់ភ្នំដំរី ឋិតក្នុងឧទ្យានជាតិព្រះមុន្នីវង្ស ។ កាលជំនាន់ព្រះបាទស៊ីសុវត្តិ ក្នុងឆ្នាំ ១៩២១ អាណាព្យាបាលបារាំងសេសបានរៀបចំតំបន់នេះឡើងជាតំបន់កំសាន្តរបស់គេ កាលណាគេធុញថប់នឹងអាកាសធាតុក្តៅស្អុះស្អាប់ ។ លើកំពូលភ្នំមានអាកាសត្រជាក់ជាទីរមនាណាស់ ហើយមានទស្សនីយភាពធម្មជាតិ នឹងសមុទ្រស្រស់គ្មានពីរទៀតផង។ អាណាព្យាបាលបារាំងបានសង់ ដំណាក់ស្តេច សណ្ឋាគារ ហាងលក់ដូរ បុស្តិ៍ប្រៃសណីយ៍ ព្រះវិហារសាសនាគ្រីស្ទ នឹងមានអាគាកាស៊ីណូមួយផង ។

ហួស បឹងទូក មុននឹងដល់វល្លស រថយន្តទាំងពីរបត់ស្តាំតាមផ្លូវលេខ ៣២ ដែលជាផ្លូវដីខ្លះ កៅស៊ូខ្លះ ។ មិនមានផ្ទះអ្នកស្រុកអមសងខាងផ្លូវទៀតទេ ។ រថយន្តបោលលឿនលែងបានហើយ ព្រោះសំម្បូរ ដង្ហុកណាស់ ជួនធំជួនតូច ហើយមានសុទ្ធតែទឹកដក់ផងព្រោះជារដូវភ្លៀង ។

វិទូ បើកមុខនាំផ្លូវ ។ ក្នុងរថយន្តគេមានមិត្តគេពីរនាក់ សុគន្ធ និង ចិត្រា ព្រមទាំង វិទូ បងប្រុសរបស់ឆដា ។ ក្នុងរថយន្តមួយទៀតដែលនិរិនបើក មាន លោកអ៊ុំឆរ៉ា អ៊ុំស្រីសុភី និងឆដា ។ ឆដាពាក់អាវយឺតដៃខ្លីពណ៌ផ្កាឈូកខ្ចីរបំរាងហើយមានអាវដៃវែងមួយទៀតពាក់ពីលើ តែមិនបិទឡេវទេ ។ នាងស្លៀកខោខូវបោយយឺតត្រឹមជង្គង់ ។ នាងចងសក់ទៅក្រោយយ៉ាងសាមញ្ញ ។ ធីតាអង្គុយក្បែរមាណព ចំណែកឪពុកម្តាយនាងអង្គុយកៅអីខាងក្រោយ ។

តាមផ្លូវលោកអ៊ុំឆរ៉ារៀបរាប់ហ្វូរហែរ ពីសភាពផ្លូវនឹងជីវភាពរស់នៅរបស់តំបន់នោះកាលពីសង្គមចាស់ ។ នរិនស្តាប់បណ្តើរស្ទួរដេញដោលមួយៗបណ្តើរ នឹងកាច់ចង្កូតវាងកន្លូកតូចធំបណ្តើរមិនអោយយន្តរលាក់ពេក ។ ឆដា នឹងម្តាយនាងស្តាប់ដោយស្ងាត់ស្ងៀម មើលទេសភាពសងខាងផ្លូវដោយជក់ចិត្ត ។

ពេលផុតផ្លូវស្មើរ គេមកដល់ផ្លូវដែលត្រូវកាច់កុង ហើយឡើងចំណោតផង ។ លោកអ៊ុំស្ងាត់មាត់ទុកអោយនរិនផ្តោតអារម្មណ៏របស់ខ្លួនលើការបើកបរ ។

កំដរបរិកាសដែលស្ងប់ស្ងាត់ នរិនយកថាសចំរៀងសម័យទំនើបចំដែលនាយជ្រើសរើសយកសុទ្ធតែបទដែលអ្នកចូលចិត្តមកបញ្ចូលម៉ាស៊ីនភ្លេងរបស់រថយន្តហើយបើកសំឡេងល្មមពិរោះរងំមិនថ្លង់ពេក ។

អង្គុយខាងមុខ ឆដាផ្អែកខ្នងទៅនឹងកៅអីរថ ។ នាងចោលភ្នែកមើលផ្លូវផង ទេសភាពផង នឹងការបើកបរដ៏ប៉ិនប្រសប់របស់នរិនផង ។ ជួននាយត្រូវដូរលេខដាក់អោយកង់ទាំងបួនមានកម្លាំងទាញដូចគ្នាដើម្បីឡើងចំណោទចោទហើយមានថ្មរអិល ។ ជួននាយត្រូវឈប់បន្តិចដើម្បីគិតសម្រេចរកផ្លូវដែលមិនពិបាកខ្លាំង ។យូរម្តងគេមើលមុខគ្នា ។ ពេលភ្នែកក្នុងភ្នែក នរិនតែងញញឹមយ៉ាងស្រស់អោយធីតា ហើយនាងញញឹមតបវិញយ៉ាងខ្លីហើយតែងងាកមុខចេញដោយអៀនប្រៀន ។

យូរទៅ ដោយរលាក់ខ្លាំងហើយឧស្សាហ៍បត់ចុះបត់ឡើងពេក ម្តាយឆដាហាក់វិលមុខ រកកលពុលរថយន្ត ។ លោកស្នើរអោយនរិនបើកបង្អួចដើម្បីបានខ្យល់បរិសុទ្ធជំនួសវិញ ។ នរិនស្តាប់លោក ។ អ្នកបិទម៉ាស៊ីនត្រជាក់ហើយអ្នកបើកបង្អួចទាំងបួន ។ ខ្យល់ព្រៃភ្នំបរិសុទ្ធ នឹងត្រជាក់ស្រេបផាត់ចូលមក ។ លោកអ៊ុំស្រុភីយកប្រេងខ្យល់គាត់លាបសៀតផ្កា ញីច្រមុះ នឹងហិតបន្តិចមុនសម្ងំស្ងៀមផ្អែកកៅអីទៅក្រោយ ។ អ៊ុំឆវ៉ាមិនពុលទេ តែលោកផ្អែកនឹងបង្អែកកៅអីហើយចោលភ្នែកទៅក្រៅបង្ហើរអារម្មណ៍ហាក់រំលឹកពីយុវភាពដែលលោកធ្លាប់មកទីនេះមុនស្រុកខ្មែរប្រែប្រួលធ្លាក់ក្នុងសង្គ្រាមដ៏រាំរ៉ៃ ។

តាមផ្លូវជួនមានមែកឈើទន់ខ្លួនមកលើផ្លូវ តម្រូវអោយអ្នកបើកប្រយ័ត្នណាស់ក្រែងវាកៀរដំបូលរថ ។ ម្តងមួយកាលខ្យល់ភ្នំផាត់ចូលពីខាងបង្អួចដែលឆដាអង្គុយ ផាយផាត់សក់នាងអោយរេរាំតាមកំសួលវាតា ហើយនាំទាំងក្លិនក្រអូបប្រហើរពីខ្លួន នឹងកេសាធីតាផាត់ចូលនាសារនរិន ។ នាយលួចស្រូបខ្យល់ដែលមានក្លិនឈ្ងុយឈ្ងប់គួរឈ្លក់វង្វេងនេះបំពេញស្ងួតយ៉ាងវែង ហើយអត់ដង្ហើមបន្តិចហាក់មិនចង់បង់ក្លិនដ៏គួរត្រេកត្រអាលនេះតាមការបញ្ចេញដង្ហើមទេ ។ បានអញ្ចឹង អ្នកហាក់មានកម្លាំងព្រឹស បញ្ចូចង្កូតកាន់តែស្វាហាប់ ។ ពេលណាខ្យល់លែងបក់នាំពិដោរនេះ អ្នកលួចរអ៊ូក្នុងពោះតវ៉ានឹងព្រះពាយដែលលោកមិនយល់ចិត្ត ។

ឆដាមិនបានដឹងថាមានជនឆ្លៀតឱកាសលួចស្រូបស្រង់ក្លិនខ្លួននាងដោយគ្មានការអនុញ្ញាតិឡើយ ។

ឃើញស្ងាត់នរិនសួរឆដាពេលផ្លូវលែងសូវកាច់កុងហើយរលាក់ខ្លាំង ។

«ឆដាធ្វើការនៅសណ្ឋាគារភ្នំខៀវយូរហើយមែនទេ?»

«ចា៎ស ប្រហែលមួយឆ្នាំជាង ជិតពីរហើយបង ។ តាំងពីខ្ញុំជាប់បាក់ឌុបមក ។ ដោយសារខ្ញុំមានប្អូនប្រុសពីរនាក់ដែលត្រូវជាប់បាក់ឌុបឆ្នាំបន្ទាប់ដែរ ពុកម៉ែនឹងខ្ញុំសំរេចចិត្តថាខ្ញុំគួរចេញធ្វើការវិញ សន្សំលុយទុកជួយប្អូនៗជាប្រុសអោយបានទៅរៀននៅភ្នំពេញ ជ្រៅជ្រះនិងគេ លៃយ៉ាងម៉េចអោយបានមានអ្នករៀនខ្លះ អ្នកចំការខ្លះក្នុងគ្រួសារយើង ។ សំណាងហើយខ្ញុំរកបានការងារនៅខេត្តនេះ មិនបាច់ទៅរកឆណាឆ្ងាយ ។ តែប្រាក់ខែនៅខេត្តតិចណាស់មិនដូចទៅឆ្ងាយដូចជានៅភ្នំពេញទេ ។»

«ឆដាមានការលះបង់គួរអោយកោតសរសើរណាស់ ។»

នរិនតប ភ្នែកសម្លឹងផ្លូវ តែឆ្លៀតងាកមកញញឹមដាក់នាងបន្តិច ។ នាងញញឹមតប ហើយបន្ត ។

«យើងជាបងគេ ធ្វើអីបានធ្វើហ្នឹងទៅដើម្បីប្អូនៗនឹងគ្រួសារ ។»

«ខ្ញុំស្តាយណាស់ ខ្ញុំមិនមានសំណាងមិនថាបានធ្វើជាបងផ្តល់ក្តីករុណាអោយទៅប្អូនណា ឬជាប្អូនគេទទួលក្តីមេត្តាពីបង ដូចអ្វីដែលឆដាបានផ្តល់ទេ ។ ជាកូនទោល ខ្ញុំបានត្រឹមទទួលគ្រប់យ៉ាងតែពីម៉ាក់នឹងប៉ាទេ ។ កម្មខ្ញុំអ្វីក៏មិនដឹង ប៉ាត្រូវចែកឋានទៀតពេលខ្ញុំរៀបចូលរៀននៅមហាវិទ្យាល័យ ។»

«ខ្ញុំសូមចូលរួមសោកស្តាយផង ដែលបានឮដូចច្នេះ ។»

ធីតាតបដោយសំឡេងស្រទន់ ។ ហើយនាងបន្តថាៈ

«មានបងប្អូនច្រើនម៉្យាងដែរ គ្រួសារមិនដែលស្ងាត់ទេ ហើយមានការអើជួយគ្នាមួយដៃមួយជើងសប្បាយណាស់ ។»

«និយាយចឹង ប្អូនប្រុសទាំងពីររបស់ឆដារាល់ថ្ងៃរៀននៅភ្នំពេញហើយមែនទេ?»

នរិនសួរបញ្ជាក់លើអ្វីដែលអ្នកបានដឹងពីរិទ្ធ ។

«គេស្នាក់នៅឯណាដែរ?»

អ្នកថែមមួយសំណួរទៀត មុនឆដាឆ្លើយទាន់ ។

«សុធា និង វិសុទ្ធ ទើបជាប់មហាវិទ្យាល័យឆ្នាំនេះឯង ។ សុធាគេជាប់ខាងអាហាររូបករណ៍វេជ្ជមុខវិជ្ជាអក្សរសាស្ត្រខ្មែរ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ វិសុទ្ធវិញរៀនខាងទេសចរណ៍ ដូចនៅសាលាជាមួយគ្នាហ្នឹងដែរ ខ្ញុំមិនច្បាស់ទេ ។ ខ្ញុំមិនដែលស្គាល់ភ្នំពេញផង ។ ពួកគេស្នាក់នៅវត្តទេ ព្រោះពួកយើងគ្មានបងប្អូន សាច់ញាតិអីនៅភ្នំពេញទេ ។ ពេលវ៉ាកងទើបពួកគេមកលេងផ្ទះម្តង ។ រាល់ខែពុកនឹងម៉ែផ្ញើរលុយតាមអ្នករត់តាក់ស៊ីដែលស្គាល់គ្នាក្នុងភូមិទៅអោយពួកគេ ។ លុយមិនច្រើនទេ គេត្រូវត្បិតត្បៀតណាស់ ។»

«គេតស៊ូណាស់ ។ ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះការតស៊ូរៀនសូត្រយ៉ាងនេះរបស់ពួកគេ ។ ស្តាយណាស់កូនអ្នកមានភាគច្រើននៅភ្នំពេញគ្មានការតស៊ូរៀនយ៉ាងនេះទេ ។ គេដឹងតែពីដើរលេងចាយវាយសប្បាយបង្ហិនទាំងលុយកាក់នឹងពេលវេលា ។ គិតទៅអយុត្តិធម៌ណាស់ អ្នកមានលុយមិនចង់រៀន អ្នកចង់រៀន មិនមានលុយ ។»

«ជីវិតគឺយ៉ាងនេះឯងបង ។ ខ្ញុំកើតមករស់ក្នុងការខ្វះខាតចេះតែដណ្តឹងសួរខ្លួនឯងពីភាពមិនស្មើរគ្នានេះរបស់សង្គម ។ ពុកម៉ែថាជាវាសនា អោយទទួលទៅ ។»

«ខ្ញុំគិតថាមិនមែនជាវាសនាទាំងស្រុងទេ ។ ជាលទ្ធផលការដឹកនាំប្រទេសនឹងស្ថេរភាពសង្គមមួយផ្នែកធំ ។»

ពីនោះមកអ្នកទាំងពីរជជែកគ្នាហូរហែរ ពីនេះពីនោះទាំងសព្វ ។ ក្រោយមកឆដាក៏យកផ្លែឈើផ្សេងៗ មានដូចជាប៉ោម ត្របែក ស្វាយខ្ចិះ ដែលទិញមកទុកទទួលទានតាមផ្លូវមកបកពុះចែកមាតាបិតានាង និងនរិនញ៉ាំ ។ យូរទៅទាំងអស់គ្នា ជាពិសេសយុវជនទាំងទ្វេរកាន់មានអារម្មណ៍ជិតស្និទ្ធនិងយល់ចិត្តគ្នាហាក់ដូចជាមិត្តដែលស្គាល់គ្នាមកជាយូរហើយ ។

ពេលវេលាកន្លងទៅជាលំដាប់ ។ ជជែកគ្នាភ្លេចខ្លួន ទីបំផុតក៏អស់ចំណោទរលីង ។ ម៉ាស៊ីនរថយន្តលែងគ្រហឹមដោយប្រឹងខ្លាំងទៀតហើយ ។ ទាំងអស់គ្នាធូរទ្រូងខ្យាក់ ។ ក្រោយពីរត់ផ្លូវស្មើបន្តិច នរិនចង្អុលអោយឆដាមើលទៅចំហៀងខាងឆ្វេងដៃខាងមុខរថយន្ត ។ នៅខាងមុខរថយន្តរិទ្ធកំពុងរត់ត្រឹកៗជ្រែកស្មៅចំហាយទឹកស្តើងៗ ។ ឆដាងាកទៅរកអ្នកមានគុណនាង ហើយខទានដោយភ្ញាក់ផ្អើលនឹងត្រេកអរថាៈ

«ពុក ម៉ែ មើលហ្ន៎ ពពកទាបណាស់ ។ យើងបើកឡានទាល់តែកប់ពពកម៉ងហើយ ។»

ទាំងអស់គ្នាផ្ទុះសំណើចតិល ។

ឃើញភ្លើងហ្វ្រាំងឡានរបស់រិទ្ធឈប់ នរិនបង្អង់ល្បឿនហើយរកកន្លែងអែបឈប់ដែរ ។ ទាំងអស់គ្នាចេញប្រសាចមកពត់ខ្លួនពត់ចង្កេះដំរុះការស្ពឹកស្រពន់ព្រោះអចលនភាពមកប៉ុន្មានម៉ោងហើយ ។ រួចពីនោះគេនាំគ្នាលូកកាន់ស្បៃពពកលេង ។ ម៉ោងដប់បន្តិចទៅហើយ ។

«មានអ្នកណាឃ្លានហើយឬនៅ?»

រិទ្ធសួរ

«យើងញ៉ាំបាយនៅទីនេះសិនហើយសឹមទៅទៀតឬ ក៏ទៅញ៉ាំទៅទឹកធ្លាក់ម៉ង?»

«ទៅទឹកធ្លាក់ទៅល្អជាងទេហ្នឹងក្មួយ»

លោកអ៊ុំឆវ៉ាស្នើរយោបល់ ។

«ពួកក្មួយក្រោយពីញ៉ាំហើយអាចងូតទឹកលេងផង ។»

«យោបល់លោកអ៊ុំល្អណាស់ ។»

សុគន្ធ មិត្តរបស់វិទូយល់ស្រប ។

«ម៉ែចង់ដែរ វិទូ?»

ចិត្រា មិត្តម្នាក់ទៀតរបស់វិទូសួរយោបល់គ្នា ទាំងមើលមុខវិទូរផង ។

វិទូមើលមុខនរិន ។

«ម៉ែចង់ដែរបង?»

នរិនទើបនឹងមើលទូរស័ព្ទក្រែងមានសេវានឹងអាលគេប្រាប់ម្ដាយថាខ្លួនមកដល់ដល់លើភ្នំដោយសុខសប្បាយហើយ បង្ការក្រែងលោកបារម្ភ ។ តែមិនមានសេវាទេ ។ អ្នកញាត់វាទៅក្នុងហោប៉ៅវិញហើយឆ្លើយអារកាត់ ។

«ទៅទឹកធ្លាក់ហួងទៅចឹង ។»

«ចឹងតោះ បើកប្រហែល ២០ នាទីទៀតដល់ហើយ»

វិទូឆ្លើយ ។ ទាំងអស់គ្នារូតរះចូលរថវិញហើយរថលូនទៅលើផ្លូវថ្មដុំៗដែលសល់ពីសង្គម យឺតៗ ។ ខ្យល់កំពូលភ្នំត្រជាក់ស្រិបបក់ចូលមកក្នុងរថ ។

«យី ត្រជាក់ណាស់តើ!»

អ៊ុំសុភីដែលស្ងាត់មាត់យូរហើយមានប្រសាសន៍ ។ លោកស្ទាងពុលឡានល្មមបានសំរាកបន្តិច ។

«រងាតើ ម៉ែ ។ ម៉ែមានអាវក្រៅមួយទៀតទេ?»

ឆដាបារម្ភពីម្ដាយនាង ។

«មានកូន តែម៉ែដាក់នៅក្នុងកន្ត្រកខាងក្រោយឡានឯណោះ ។»

«ខ្ញុំអាចឈប់ឡានយកសិនក៏បាន ។»

នរិនពោលទាំងបន្ថយល្បឿន ហើយសម្លឹងកញ្ចក់មើលមកអ្នកជិះខាងក្រោយ ។

«មិនអី ទេ ។ អ៊ុំមានក្រមារបស់អ៊ុំហើយ ។ បិទកញ្ចក់ខាងអ៊ុំទៅល្មមហើយកូយ ។»

នរិនបិទកញ្ចក់ខាងអ្នកជិះខាងក្រោយទាំងពីរ ហើយបិទខាងខ្លួនឯងទុកបង្ហើបតែបន្តិចល្មមអោយខ្យល់កំពូលភ្នំដ៏បរិសុទ្ធផាត់ចូល ។

«ឆដាចង់បិទទេ?»

អ្នកសួរយោបល់នារី ដោយមើលមុខនាងផង ។ នារីញញឹមតបយ៉ាងទន់ភ្លន់ ៖

«អរគុណបង តែមិនបាច់ទេ ។»

ហើយនាងងាកទៅខាងបង្អួច ។

«ខ្ញុំចង់ចាប់ពពកលេងអោយអស់ចិត្ត ។ មិនដែលឃើញពពកទាបចឹងទេ!»

ថាហើយនាងលូកដៃសណ្ដូកទៅក្រៅរថ ប្រលែងលេងនឹងស្បៃពពក ។

នរិនញញឹម មិនស្ដី ។

ពេលរថយន្តបើកទៅត្រង់ហួសអាគារចំណាស់មួយជង់ខាងឆ្វេងដៃ លោកអ៊ុំឆវ៉ាចង្អុលទៅខាងឆ្វេងដៃរថ ទាំងពោលប្រាប់អ្នករួមដំណើរអោយដឹងថា ៖

«នោះគឺសណ្ឋាគារចាស់ ដែលគេនិយមហៅថាអាគារកាស៊ីណូកាលពីជំនាន់សម្ដេច!»

គ្រប់គ្នាក្រឡេកតាមដៃលោកឃើញអាគារធំស្កឹមមួយកំពស់បីជាន់ ។ ថ្នាំរបកអស់ហើយ ទឹកភ្លៀងដាមតាមជញ្ជាំងធ្វើអោយមានស្នាមខ្មៅប្រតាក លាយជាមួយពណ៌ច្រែសដោយអន្លើរ ។ កន្លែងខ្លះមានស្លែដុះយ៉ាងក្រាស់មើលឃើញយ៉ាងច្បាស់ពីចំងាយទៅ ។ ជុំវិញសំណង់ចាស់នឹងបាក់បែកនេះស្មៅជើងក្រាស់ដុះត្រឹមចង្កេះ វេរាំតាមជំនោរពើកពើនទៅមក មើលទៅគួរអោយព្រឺសំបុរ ដោយសារស្ងាត់មនុស្សផង ដោយមានអ័ព្ទធ្លាក់ដេរដាសផង ។

អ៊ុំឆវ៉ាអធិប្បាយបន្តទៀតថា៖

«តាមអ៊ុំដឹង កាលពីអាណាព្យាបាលបារាំងសេសសាងសង់តំបន់កំសាន្តរបស់គេនៅទីនេះដំបូង កម្មករជាង ប្រាំបួនរយនាក់ឯណោះបានស្លាប់បាត់បង់ជីវិតក្នុងឧបត្តិហេតុផ្សេងៗ ។ គេចំណាយពេលប្រហែលជា ប្រាំបួនខែទើបត្រូវត្រាយនឹងសាងសង់ហើយជាស្ថាពរ ។»

«យី មានយ៉ាងនេះផង?»

នរិនលាន់មាត់ ។

អ៊ុំឆវ៉ាបន្តទៀតថា ៖

«តាមយោបល់អ៊ុំ ទីនេះគួរមានតម្លៃប្រវត្តិសាស្រ្តសំខាន់ណាស់គួរយើងរក្សាទុកភាពដើមរបស់វាអោយបានច្រើនបំផុតតាមលទ្ធភាព ។ វាអាចអោយយើងដឹងបានពីរបៀបរស់នៅរបស់មន្ត្រីបារាំងសេសកាលពីគេគ្រប់គ្រងស្រុកយើង ។»

នរិនស្តាប់ហើយងក់ក្បាលយល់ស្រប ។ ចម្ងល់មួយផុសក្នុងគំនិតអ្នក ។

«ទីនេះត្រូវគេបោះបង់ចោលដំបូងនៅឆ្នាំណាដែរ លោកអ៊ុំ?»

«ទីកំសាន្តនេះត្រូវបានបារាំងបោះបង់ចោលនៅចុងកម្លុងទសវត្សរ៍ឆ្នាំ ១៩៤០ គឺក្នុងសង្រ្គាមកណ្តុចិនដំបូងដែលនាំអោយស្រុកទេសកាលណោះមានសភាពមិនស្រួល ។ ចលនាជាតិនិយមខ្មែរកស្សរៈដែលងើបឡើងប្រឆាំងបារាំងបានបង្ករអោយមានអសន្តិសុខសម្រាប់ពួកមន្ត្រីច្រម៉ុះស្រួចអស់នោះ ។ ក្រោយពេលស្រុកបានឯករាជ្យ អ៊ុំធ្លាប់បានមកលេងទីនេះម្តងជាមួយឪពុកម្តាយរបស់អ៊ុំកាលឆ្នាំ ១៩៧០ ឬ ៧១ អ៊ុំចាំមិនច្បាស់ទេ ។ តែអ៊ុំចាំថាមិនជាយូរណាស់ណាទេមុនស្រុកធ្លាក់ចូលក្នុងភាពចលាចល ។ គិតទៅកាលណោះហេងណាស់ព្រោះនៅឆ្នាំ ១៩៧២ ទីកំសាន្តដ៏ប្រណិតនេះក៏ត្រូវបានគេចោលម្តងទៀតដោយសាររបូតទៅក្នុងការគ្រប់គ្រងរបស់ទ័ពព្រៃខ្មែរក្រហម ។ មកដល់ឆ្នាំ ១៩៧៩ ទីនេះនៅតែជាតំបន់ឈរជើងរបស់ខ្មែរក្រហមដដែលនៅឡើយទេ ។ មកទល់ឆ្នាំ ១៩៩០ ទៅហើយ ខ្មែរក្រហមនៅតែឈរជើងបាននៅទីនេះមិនទៅណាទៀត ។ អ៊ុំក៏ដូចជាពួកក្មួយសំណាងណាស់ដែលខ្មែរក្រហមរលាយខ្លួនទៅហើយបានមកលេងទីនេះនឹងមកយល់ទីតាំងប្រវត្តិសាស្រ្តទាំងសម័យអាណានិគម សម័យសម្តេចឪ ក៏ដូចសម័យក្រោយៗមកទៀត ។»

«ខ្ញុំរិតតែសំណាងណាស់ទៅទៀតមានអ៊ុំមកជាមួយជួយប្រាប់អោយដឹង ។ កុំអីខ្ញុំមិនមានឱកាសបានដឹងទេ ។ អរគុណអ៊ុំណាស់ ។»

នរិនពោលដោយសម្លឹងមើលទៅកញ្ចក់មើលក្រោយមួយភ្លែតផង ។

«ពួកយើងអរគុណលោកក្មួយដូចគ្នា ។ មិនមានលោកក្មួយជូនមក មិនដឹងអង្កាល់ទេ ទើបមានសំណាងយល់ទីនេះតាមបំណងនោះ ។»

ហើយគ្រប់គ្នាក៏ស្ងាត់មាត់ទៅ ។

ហួសសណ្ឋាគា និងកាស៊ីណូបន្តិច គេមកដល់ផ្លូវបែកជាពីរ ម្ខាងទៅខាងឆ្វេង នឹងម្ខាងទៀតបត់កាច់បន្តិចទៅខាងស្តាំ ។

«បត់ស្តាំក្មួយ ទឹកធ្លាក់នៅខាងស្តាំ»

លោកអ៊ុំឆវ៉ាប្រាប់ ។

នរិនមើលទៅមុខឃើញរថរបស់វិទូឈប់ក៏អើតក្បាលតាមទ្វារហើយស្រែកអោយវិទូបត់ស្តាំ ។ ប្រហែលដប់នាទីជាង គេឃើញមានឡានកាមរីពីរគ្រឿងទំនងជាតាក់ស៊ីព្រោះមានលើកតួយ៉ាងខ្ពស់ចតខាងលើចិញ្ចើមផ្លូវខាងឆ្វេងដែដង្ហែរគ្នានៅឯនាយខាងមុខ ។

«មានគេមកលេងដែរតើ អ៊ុំ»

នរិនប្រាប់ឪពុកម្តាយឆដា ។

«ចឹងមិនស្ងូវខ្លាច»

អ៊ុំសុភីនិយាយ ។

«អ៊ុំប្រហែលគិតខ្លាចរហូតមកហើយទើបមិនសួរមាត់កតាំងពីឡើងភ្នំ»

នរិននិយាយលេងបន្លំមែនហើយសើចញឹមៗ ។

«ខ្លាចដែរហ្នឹងក្មួយ ជួបក្រុមអាពត អាពាងមកសម្លុតកំហែងយើងមានអីសង្ឃឹម ។ អ៊ុំបាក់ស្មាតហើយតាំងពីជំនាន់ស៊ីបបរហ្នឹងមក ៗ»

«កុំភ័យអីអ៊ុំ ។ សុគន្ធ នឹងចិត្រាជាកងរាជអាវុធហត្ថ ។ ក្នុងរថយន្តនោះមានបីនាក់មានអាវុធជាប់ខ្លួន ។ វិទូត្រូវប៉ារបស់គេអោយយកមួយដើមមកតាមឡានដើម្បីបង្ការអាសន្នអន់ភ័យ ។ កាំភ្លើងទាំងអស់សុទ្ធតែមានច្បាប់ទេ ហើយអ្នកកាន់វាក៏ជាមនុស្សមានសីលធម៌ នឹងការអប់រំគួរអោយទុកចិត្តបាន ។ បើមិនចាំបាច់ការពារខ្លួន ពួកគេមិនសម្ដែងវាឡើយ ។»

«យី មិនធម្មតាទេមិត្តភ័ក្តក្មួយនៀក!។»

អ៊ុំឆវ៉ាលាន់មាត់ ។ លោកពោលតថា ៖

«តែគួរអោយកោតសរសើរពួកក្មួយណាស់ ដែលមិនដូចក្មេងឈាមរាវភាគច្រើនសព្វថ្ងៃនេះទេ ។ ខ្លះអាងខ្លួនមានទ្រព្យនឹងអំណាច ឬមិនចឹងទេអាងម៉ានបក្សមានពួក តែងដើរបង្ករហេតុ ធ្វើព្យុះធ្វើភ្លៀងជាមួយអ្នកស្លូតត្រង់ គួរអោយស្អប់ នឹងខ្ពើមរអើមណាស់ ។ កម្ររកបានណាស់មនុស្សដូចគ្រួសារក្មួយវិទូ ។ ពួកគាត់មានលុយនឹងអំណាចមែនតែមិនប្រើវាមកគំរាមទិញដីពីអ្នកភូមិទេ ។ លោកសុទ្ធតែហ៊ានដំល់ថ្លៃខ្ពស់ណាស់ ហើយទិញតែពីអ្នកស្ម័គ្រចិត្តលក់ទេ ។ ដូចអ៊ុំមិនព្រមលក់ លោកក៏មិនប្រើល្បិចកលគំរាមកំហែងអីដែរ ។ រកបែបនេះសឹងមិនបានទេសម័យបច្ចុប្បន្ននេះ ។»

ឡានវិទូអែបខាងស្ដាំ រកកន្លែងចត ។

នរិនធ្វើដូចគ្នា ។ អ្នកពោលបណ្ដើរថា៖

«ស្ដាយណាស់អ៊ុំ អ្នកមានខ្លះបណ្ដោយកូន ហើយការពារកូនពេក ទោជាលែងដឹងខុសត្រូវទាំងចាស់ទាំងក្មេង បណ្ដោយអោយមានបញ្ហាដល់សង្គមមិនលោះសោះ ។ ស្រុកយើងតែយ៉ាងនេះ គង់មានសង្គ្រាម៉វណ្ណៈ នឹងអំណាចទៀតមិនខានឡើយ ។»

ហើយអ្នកចតឡានស្រេចល្មម ។ ម៉ោង ១០ នឹង ៤០ នាទីទៅហើយពេលនោះ ។ ទាំងអស់គ្នាចុះពីរថយន្តហើយផ្ទៀងស្ដាប់សូរទឹកធ្លាក់ ។

«នៅខាងណោះ»

នរិនចង្អុរទៅខាងឆ្វេងដៃផ្លូវដែលមានព្រៃស៊ប់ទ្រុប់ និងមានកូនអូរតូចមួយហូរកាត់ ។

«ដើរតាមទឹកហូរនឹងឃើញទឹកធ្លាក់មិនខាន»

សុគន្ធអោយយោបល់ ។

«យើងគិតទៅមើល រកកន្លែងញ៉ាំបាយក្បែរទឹកធ្លាក់ សឹមមកយកម្ហូបម្ហាទៅ ឬយកទៅហើយដើររកម៉ង?»

វិទូសួរយោបល់ ។

«ទៅរកមើលសិនទៅហើយចាំមកយកកវ៉ាន់ជាក្រោយល្អជាងទេដឹងក្មួយ?» អ៊ុំឆវ៉ាលើកឡើង ។

«តាមយោបល់អ៊ុំទៅចឹង ។»

នរិនលូកមាត់ មុនសួរបន្ត ។

«តែចង់ទៅទាំងអស់គ្នា ឬចង់មានអ្នកនៅចាំឡានខ្លះ? ។»

«អញ្ជេះចុះ ។»

វិទូអារកាត់ ។

«សុគន្ធ ចិត្រា និង នរិនទៅរកផ្លូវទៅ ខ្ញុំនៅចាំឡានជាមួយលោកអ៊ុំទាំងពីរ នឹងអ្នកនាងឆដា ។ កុំអោយអ៊ុំទៅមកៗអស់កម្លាំងពេក ។ ម៉េចដែរបងនរិន? ។»

«ម៉េចដែរអ៊ុំ?»

នរិនមិនឆ្លើយតែស្ទួរតទៅចាស់ទុំទាំងពីរនាក់ ។

«ល្អតើក្មួយ ។ សំរេចចឹងចុះ ។»

ទាំងបីនាក់ទៅបាត់មួយសន្ទុះ ទើបឃើញត្រឡប់មកវិញ ។

ម្នាក់ៗមើលទៅរាងហត់បន្តិចដែរ ។

«តោះ ផ្លូវចុះទឹកធ្លាក់នៅខាងនោះ ។»

នរិនចង្អុល ។ ប្រុសៗក្មេងៗទាំងបួននាក់ជួយគ្នាជញ្ជូនធុងទឹកកក ធុងបាយ ម្ហូបម្ហា ផ្លែឈើ នឹងកន្ទេកចានឆ្នាំងចេញពីឡាន ហើយដើរតម្រង់ផ្លូវទៅទឹកធ្លាក់ ។

ឆដាគ្រាម្ដាយនាងក្រែងលើកភ្លាត់ជើងដួល ។ ពួកគេធ្វើដំណើរដោយប្រយ័ត្នប្រយ៉ែង ។ ដើរកាច់កុងលើថ្មធំតូចចុះបន្តិចម្ដងៗមិនយូរប៉ុន្មានគេក៏មកដល់ទីក្បែរចំណោទទឹកធ្លាក់ល្អម ។ ទឹកហូរត្របាញ់ធ្លាក់ពីទីខ្ពស់ កំពស់ប្រមាណជា ៥ ទៅ ៦ ម៉ែត្រមកលើផ្លាថ្មរាបធេងមានផ្ទៃប្រហែលជា ១០ ទៅ ១៥ ម៉ែត្រការ៉េមុននឹងធ្លាក់ទៅមួយជាន់ទៀតហើយហូរបត់បែនលាន់សន្ធឹកឈូឆរ ។ ចំហាយទឹកចាំងពន្លឺព្រះសូរ្យចេញជាកន្ទន្ទូស្រពាលៗគួរអោយសប្បាយភ្នែកយ៉ាងក្រៃលែង ។

ក្រោយពីរកបានទីស្រឡះមួយមិនឆ្ងាយពីមាត់ទឹកល្អមក្រាលកន្ទេលកក់បានសំរាប់បរិភោគបាយ ប្រុសៗទម្លាក់គ្រឿងញ៉ាំចុះហើយដកដង្ហើមធំយូគ្រប់គ្នាព្រោះហត់នឹងធ្ងន់ ។

ភារៈបន្ទាប់គឺដល់វេនឆដានឹងម្ដាយនាងម្ដងជាអ្នករៀបចំចាន ស្លាបព្រា នឹងម្ហូបអាហារ ។

វិទូនឹងនរិនសុំជួយតែអ្នកទាំងពីរប្រកែក ។

«ក្មួយទាំងពីរបើកឡានហត់ ហើយជញ្ជូនមកហត់ទៀត ។ ទុកអោយអ៊ុំនិងអាដាធ្វើបានហើយ ។ មិនមានអីធ្ងន់ឬលំបាកទេប៉ុណ្ណឹង ។»

អ៊ុំសុភីលើកឡើង ។ លោកបន្តថា៖

«ក្មួយទាំងអស់ទៅលាងដៃលាងជើង ហើយលុបមុខអោយស្រឡះខ្លួនទៅ ។ មកវិញបាយរៀបរួចអាចញ៉ាំបានហើយ ។»

លោកបង្គាប់ ។ ទាំងអស់គ្នាស្ដាប់លោក ហើយដើរចេញទៅ ។

ឆដានឹងមាតាបិតានាងចាប់ផ្ដើមរៀបអាហារភ្លាមៗដែរ ។ ក្ដាមសេះស្ងោរ បង្គារ នឹងមឹក ស្រុះ នៅក្ដៅៗនៅឡើយពេលដកចេញពីកេសស្ដោរុំមាត់ជិតមក ។ ឆដាចាក់ទឹកត្រីកោះកុងដែលនាងបុកផ្ទាល់ដៃចូលក្នុងចានតូចតាមចំនួនមនុស្ស ហើយនាងដួសបាយតំរូវតាមហ្នឹងដែរ ។ លុះរួចរាល់ហើយ លោកអ៊ុំឆវ៉ាស្រែកហៅអ្នកទាំងបួនដែលកំពុងដើរលុយទឹកដ៏ត្រជាក់លេង ។ ជើងខោគេសុទ្ធតែម្ងូរលើជង្គង់អស់ ។

«រួចរាល់ហើយក្មួយៗ ។ មកញ៉ាំបានហើយ ។»

ទាំងអស់គ្នាដើរត្រសងមក ហើយអង្គុយចុះ ជារង្វង់ជុំវិញចានម្ហូបម្ហា ។

«មើលទៅគួរអោយឆ្ងាញ់ណាស់ទៀក»

សុគន្ធនិយាយ ។

«មានអ្នកណាចង់បានប៊ីយែទេ?»

ចិត្រាដែលអង្គុយនៅជិតធុងទឹកកកស្ទួរឡើង ។

«ខ្ញុំសុំមួយមក ។»

យុវជនទាំងបីអ្នកខទានព្រមគ្នា ។

ហុចទៅអោយមិត្តខ្លួនម្នាក់មួយកំប៉ុងបណ្តើរ ចិត្រាសួរទៅចាស់ទុំទាំងពីរនឹងឆដាបណ្តើរ ។

«លោកអ៊ុំនិងអ្នកមីនាងឆដាពិសារអីដែរ? យើងមានទឹកផ្លែឈើ ទឹកក្រូច នឹងទឹកសុទ្ធក្រៅពីប៊ីយែ ។»

«អោយអ៊ុំសុំទឹកផ្លែឈើម្នាក់មួយមកក្មួយ»

អ៊ុំឆវ៉ានិយាយ ។

«ខ្ញុំសុំទឹកក្រូចមួយមកបង!»

ឆដាពោល ។

«ខូក ឬ ហ្វែនតា ឬ ស្ព្រៃ?»

«ហ្វែនតា បង ។ អរគុណច្រើន ។»

ចិត្រាញញឹមតប មិនមាត់ ។

«និយាយអញ្ចឹងមិនដឹងអ្នកដំណើរតាមរថយន្តពីរគ្រឿងដែលមកដល់មុនយើងនោះគេទៅខាងណាទេហ្ន៎ ។ ចាំបាយហើយចាំដើរលេងៗមើលៗផងមើលក្រែងប្រទះ ។ ហេងស៊ីយអាចជាអ្នកស្គាល់គ្នាក៏មិនដឹង ។»

វិទូលើកឡើង ។

ទាំងអស់គ្នាយល់ស្រប ។ ហើយការស្រស់ស្រូបក៏ចាប់ផ្តើមឡើង ។

បាយមួយពេលនោះមានឱជារសឆ្ងាញ់ជាងពេលណាៗទាំងអស់ ។ មិនដឹងថាដោយសារតែទីកន្លែងដែលមនោរម្យ ឬម្ហូបដែលមានឱជារស ឬការជួបជុំគ្នាដោយមេត្រីភាព ឬភាពហត់នឿយដែលត្រូវធ្វើដំណើរវែងឆ្ងាយទេ ដែលធ្វើអោយម្នាក់ៗសុទ្ធតែបាយឆ្ងាញ់ហួសបរិយាយ ។ គេបរិភោគបណ្តើរនិយាយគ្នាលេងពីនេះពីនោះបណ្តើរ ។

បាយហើយគេនាំគ្នាសំរាកបន្តិច ហើយទើបចុះទៅលេងទឹកធ្លាក់ ។ ឆដានិងឪពុកម្តាយនាងងូតមួយកន្លែង ចំណែកឯប្រុសៗទាំងបួននាក់ដើររកកន្លែងមួយទៅក្រោមបន្តិចហើយងូតលេងយ៉ាងត្រជាក់ចិត្ត ។ មេឃនឹងអាកាសធាតុអំណោយផលល្អណាស់ ដែលមិនត្រឹមតែមិនភ្លៀងទេ ថែមទាំងបើកថ្ងៃល្អមអោយអារម្មណ៍ស្រស់ថ្លា ។

ក្រោយពីនោះគេនាំគ្នាជញ្ជូនកវ៉ាន់ទៅរថយន្តវិញហើយឆ្លៀតសម្លឹងរកមើលក្រែងជួបអ្នកដែលមកលេងដូចគ្នាដែរ តែមិនមានឃើញសោះ ។ លុះមកដល់ឡានបានដឹងថាគេទៅវិញបាត់ហើយព្រោះមិនឃើញមានឡានអ្នកទាំងនោះនៅចតទៀតទេ ។

គេចូលឡានហើយអ្នកបើកបត់ក្បាលរថបកក្រោយទៅមើលសណ្ឋាគារ អាគារកាស៊ីណូ និងអាគារជំនាន់បារាំងដទៃទៀត ដែលសុទ្ធតែចំណាស់ៗបាក់បែកគួរសមដែរអស់ទៅហើយ ។ បន្ទាប់មកគេទៅឈរមាត់ចម្រាក់ថ្មមើលទៅព្រៃស្រោងដែលនៅខាងក្រោមនឹងទីក្រុងកំពតក៏ដូចជាឈូងសមុទ្រដែលឋិតនៅឯនាយសន្លឹម ។

គេថតរូបជាអនុស្សាវរីយ៍ជាច្រើន ។ ពេលថតជុំគ្នា នរិនតែងរកឱកាសឈរថតក្បែរនារីដែលចិត្តខ្លួនប្រាថ្នាចង់ក្បែរ ហើយតែមានអារម្មណ៍សប្បាយប្លែកពេលបានកៀកស្និទ្ធឆោមយង់ ។ អ្នកចង់សុំអនុញ្ញាតិលោកអ៊ុំឆវ៉ា នឹងអ៊ុំសុភីក៏ដូចជាឆដាដើម្បីថតរូបតែពីរនាក់នឹងឆោមនិមលដែរតែចិត្តមួយរារែកមិនហ៊ានព្រោះក្រែងមិនសមរម្យ ។ អ្នកទើបស្គាល់ពួកគេមិនដល់មួយសប្តាហ៍ផងទេ ។

ថ្ងៃនោះរសៀលបន្តិចទើបគេនាំគ្នាត្រឡប់មកកំពតវិញ ។ ក្នុងចិត្តគេម្នាក់ពេញដោយសុភមង្គល ។ ក្នុងឡានលោកអ៊ុំទាំងពីរសម្ងំសំរាន្តទុកអោយនរិនបើករថយន្តដោយមានឆដាអង្គុយក្បែរនិយាយកំដរពីនេះពីនោះមិនដាច់ ។ ធីតាបកផ្លែឈើអោយនរះញាំុយ៉ាងឆ្ងាញ់ពិសារ ។ អ្នកបរិភោគឡើងផ្អែតស្កប់ស្កល់ព្រោះផ្លែដែលចិត្តដោយផ្ទាល់ដៃរបស់នារីដែលខ្លួនមានចំណូលចិត្តមានឱជារសផ្អែមឆ្ងាញ់លើសពេលណាទាំងអស់ ។ ចិត្តយុវជនទាំងពីររីកថ្លាដូចផ្កាត្រូវសន្សើម ។

ពាក្យចាស់ថាឃ្លានទើបឆ្ងាញ់ តែនេះមើលទៅដូចជាស្រឡាញ់ទើបឆ្ងាញ់ត្រូវជាង ។

***

ពីរថ្ងៃបន្ទាប់ពីត្រឡប់មកពីបូកគោ នរិន វិទូ សុគន្ធ នឹងចិត្រាជួលទូកយន្តមួយទៅកោះទន្សាយ ហើយបោះតង់ស្នាក់នៅទីនោះមួយយប់ ។

គេជួលខ្ទមស្លឹកម្នាក់មួយសម្រាប់ស្នាក់នៅតែមិនមានអ្នកណាចង់ទៅគេងនៅទីនោះឡើយ ។ ពេលយប់គេមកបោះតង់ឯឆ្នេរខ្សាច់ ។

ពេលថ្ងៃគេទៅស្ទូចត្រី នឹងជិះទូកលំហែឆ្វៃលកោះ ។ គេអោយទូករត់យឺតៗលើផ្ទៃគង្គាដែលពើតពើងខ្ពស់ទាបតាមកម្លាំងវាយោ នឹងរលក ។

ពេលគេទៅដល់ទីណាដែលមើលទៅទំនងមានត្រីច្រើនគេចតទូក បោះយុថ្កាហើយស្ទូចត្រីលេង ។ ស្ទូចបណ្តើរមិត្តទាំងបួនញាំប៊ីយែរជជែកគ្នាលេង នឹងស្តាប់តន្ត្រីពីម៉ាញ៉េប្រើអាគុយមួយធំគួរសមដែលវិទូយកពីផ្ទះនាយម៉ក ។

ពេលស្ទូចបានម្តងៗមិនថាត្រីតូចឬធំទេ មិត្តទាំងបួនហោកញ្ជៀវដោយសោមនស្ស ។ អ្នកស្ទូចសុទ្ធតែសប្បាយចិត្តតែត្រីដែលត្រូវគេស្ទូចបានប្រហែលមិនចឹងទេ ។ អស់ចិត្តហើយគេបន្តដំណើរទៅមុខទៀត ។ ដូចថ្ងៃមុនកាលទៅពពកវិលដែរ ថ្ងៃនេះមេឃស្រទុំល្មមមិនក្តៅពេក ។

ពេលដល់ទីណាទំនងមានផ្កាថ្មល្អៗគេក៏ចុះជ្រមុជស្គូបាមើលផ្កាថ្មនឹងហ្វូងត្រីតូចធំចម្រុះពណ៌គួរជាទីចេតនា ។

ពេលឃ្លាន ទាំងអស់គ្នាអាំងត្រីលើចង្រានធ្យូងមួយធំល្មមដែលរៀបចំម៉កជាស្រេច ។ ត្រីស្រស់ៗ ជាមួយទឹកអំពិលទុំ ជូរៗ ហិរៗ ឆ្ងាញ់ពិសារពេកណាស់ ។ គេអាំងត្រីដែលស្ទូចបានខ្លះ និងដែលទិញប៉ុរ៉ុងយកមកខ្លះ ។ គេដាក់ក្លាសេវាក្នុងធុងទឹកកកធំមួយលើទូក ។

ពេលសប្បាយអិញ្ចឹង វេលារំកិលខ្លួនទៅយ៉ាងឆាប់រហ័ស ។

ពេលព្រលប់មកដល់ គេចតទូក បោះតង់នៅលើឆ្នេរខ្សាច់ មាត់ទឹក ហើយបង្កាត់ភ្លើងភ្នក់អង្គុយជជែកគ្នាលេងនឹងញាំប៊ីយែបន្តទៀត ដោយគ្មានខ្វល់ពីអ្វីទាំងអស់ ។

លុះយប់បន្តិចម៉ោងប្រហែលប្រាំបួនជាងគេពន្លត់ភ្នក់ភ្លើង ហើយឡើងទូកទៅតាមអ្នកនេសាទមឹកម្នាក់ឈ្មោះឈុនដែលវិទូបានចាត់ចែងអោយមកយកទៅនេសាទមឹកជាមួយហើយជាស្រេច ។ ពួកគេព្រមព្រៀងគ្នាបង់តម្លៃដែលឈុននេសាទបានជាមធ្យមក្នុងមួយយប់ បូកជាមួយនឹងថ្លៃជួលទូក នឹងការណែនាំភ្ញៀវទាំងបួនអោយស្គាល់ពីរបៀបដងមឹកផង ។

គេព្រមព្រៀងគ្នាថា មឹកដែលឈុនចាប់បានទាំងប៉ុន្មានយប់នោះគឺជារបស់អ្នកទាំងបួនព្រោះគេម៉ៅពីឈុនផ្តាច់អស់ហើយ ។

ទៅដល់សមុទ្រក្រៅ គេឃើញមានទូកនេសាទបួនដប់មានចង្កៀងម៉ាំងសុងសំយ៉ុងពីក្បាលទូកប៉ប្រះផ្ទៃទឹក ជួនបាត់ជួនឃើញតាមកម្លាំងនឹងទំហុំរលក ។

លុះរកទីនេសាទបានហើយ ឈុនបោះយុថ្កា ហើយដុតចង្កៀងដាក់បំភ្លឺដូចគេដែរលើផ្ទៃទឹក ។

ពេលត្រៀមស្រេចហើយ ឈុនឈរលើក្បាលទូកកាន់ឈើមួយវែងប្រមាណពីរឬបីម៉ែត្រមានកន្ត្រងនៅចុងចាំប្រុងមើលមឹកដែលងើបមកលេងភ្លើង ។

ពេលគេឃើញគេដួសវាភ្លាមហើយវាត់មកលើទូកយ៉ាងរហ័សរហួននឹងស្វាហាប់ ។ ពេលណាមានហ្វូងមឹកឡើងមកលេងភ្លើង ឈុនវាត់យកៗយ៉ាងញាប់ដៃ ។ ដៃនឹងភ្នែកអ្នកនេសាទរាត្រីនេះរហ័សណាស់ ។

មើលឈុនធ្វើដូចស្រលកម្លោះទាំងបួន សុំសាកម្តង ។ តែគ្មានអ្នកណាមួយមានសំណាងទេ ក្រៅពីសំណាងដែលមិនមាននរណាធ្លាក់ពីទូកចូលទឹកនោះទេ ។

មិនស្រលទេ វលកបោកទូកអោយឃ្លីងឃ្លោង ផ្អៀងផ្អង តម្រូវអោយអ្នកឈរពួកែលំនឹងខ្លួនណាស់បានបាន ។ ម៉្យាងទៀត គេមើលឃើញមីកតែដួសមិនទាន់វាមុជទៅវិញទេ ។ សាកអស់ចិត្តហើយ ហើយណាមួយមើលទៅគ្មានសង្ឃឹម គេប្រគល់នាទីអោយឈុនវិញ ។

ម៉ោងពីរជាងទៅហើយគេបានមីកប្រហែលតែពីរទៅបីគីឡូប៉ុណ្ណោះ ។ ដោយសារអ្នកទាំងបួនអស់កម្លាំងព្រោះវរល់ដើរមួយថ្ងៃមកហើយ ពួកគេអោយឈុនឈប់ហើយជូនគេមកតង់វិញ ។

គេយកមីកពាក់កណ្តាល ហើយអោយឈុនពាក់កណ្តាល ។

ក្រោយដាក់មីកក្លាសេហើយ គ្រប់គ្នាចូលតង់សម្ងំសំរាកលង់លក់យ៉ាងស្កប់ស្កល់ ។

យប់នោះមិនថារលកឈូរឆរផ្ទប់ច្រាំងឮថ្លង់យ៉ាងណាទេ វាមិនអាចរំខានដំណេកអ្នកទាំងបួនបានឡើយ ។

***

នៅថ្ងៃសៅរ៍ចុងសប្តាហ៍នោះ នរិននឹងវិទូនាំគ្នាបើកឡានទៅលេងទឹកឈូរ ព្រែកត្នោត នឹងទៅមើលចំការធុរេនផង ។ ពេលបាយហើយគេចេញឡានទៅលេងកំពុងត្រាច ក្រោយមកទៅភ្នំសរសៀរទៀត ទៅមើលល្អាងថ្មនៅទីកំសាន្តទាំងនេះនឹងឆ្លៀតទៅថ្វាយបង្គំព្រះអង្គនៅទីនោះផង ។ អ្នកបួងសួងសុំអោយបំណងក្នុងចិត្តបានដឹងដល់នារីដែលខ្លួនលួចចាប់ចិត្ត ព្រោះអ្នកមានអារម្មណ៍ថាមិនដឹងនិងថ្លែងអោយនាងយល់យ៉ាងណាទេ ។ អ្នកផ្សងអោយព្រះអង្គបន្ទន់ចិត្តនាងអោយមានចិត្តដូចគ្នាចំពោះអ្នកវិញផង ។

អារម្មណ៍អ្នកពេលនោះចាប់ផ្តើមអន្លង់អន្លោចណាស់ ។ សំឡេងទឹកហូរ សូរសត្វយំឆ្លើយឆ្លង ស្លឹកឈើរវាំតាមកម្លាំងវាតាបោយបក់ នឹងសំណាត់ពពកតាមកម្លាំងខ្យល់ឯមេឃា ក៏សុទ្ធតែធ្វើអោយអ្នកអណ្តែតអណ្តូងបាន ។ ហើយជួនកាលអ្នកក៏មានអារម្មណ៍ព្រួយដោយមិនដឹងហេតុ ។ ដូចកំណាព្យមួយឃ្លាក្នុងសៀវភៅ យុវវ័យម៉ាយា របស់អ្នកនិពន្ធ យឹម កិច្ចសែ បរិយាមិនខុសមែន ៖

ជួបចូលខែនេះចេះតែផ្សា
ទេវតាលោកអើយព្រួយម៉្លេះ
ចង្អៀតចិត្តអីចង្អៀតតែម្តេះ
ទ្រូងស្មើរទ្បេះប្រេះគ្មានមុខ ។

ពេលនោះឯងដែលអ្នកនឹកដល់នឹងយល់ទំហំទុក្ខដែលលោក ស៊ីន ស៊ីសាមុតបកស្រាយក្នុងបទ លួចស្នេហ៍លួចទុក្ខ ។ ពេលនៅតែឯង អ្នកតែងស្តាប់បទនេះហើយស្តាប់ទៀត ហើយអារម្មណ៍អ្នកកាន់តែអណ្តែតអណ្តូង ស្រងេះស្រងោចណាស់ទៅទៀត ។

លួចស្នេហ៍លួចទុក្ខ

ដោយ

ស៊ីន ស៊ីសាមុត

គេងព្រួយតែឯងរកថ្លែងមិនរួច
ព្រោះស្នេហ៍លាក់លួចលបស្រឡាញ់គេ
លួចស្នេហ៍លួចទុក្ខ ព្រួយកតទំនេរ
តើអោយខ្ញុំរេ គិតរបៀបណា ។

ស្នេហ៍ខ្លាំងទុក្ខខ្លាំងភ័ន្តភាំងគំនិត
ក្ដីស្នេហ៍ធំពិត ធំជាងសង្ខា
ប្រាស់ខ្នង គងខ្នើយ កើយគេងកាលណា
ឃើញតែភ័ក្ត្រាច្បាស់នៅមុខបង ។

យល់មុខទុក្ខមកដូចជាគេដាក់
ធ្ងន់ឡើងកតស្រាកសោះឡើយនួនល្អង
ទុក្ខស្នេហ៍ទុក្ខស្និទ្ធទុក្ខធំកន្លង
ជាតិនេះស្គាល់ម្ដងឆ្លងមិនផុតឡើយ ។

តើធ្វើម្ដេចទៅទើបពៅយល់ចិត្ត
ថាប្រុសស្នេហ៍ស្និទ្ធកតប្រែកន្តើយ
រាល់ថ្ងៃរៀមសឹងដាច់ខ្យល់ស្លាប់ហើយ
អូនហើយ ប្រណីយល់ចិត្តបងផង ៕

អ្នកចង់ទៅលេងភ្នំលោកទៀត តែមិនមានពេលគ្រប់គ្រាន់ព្រោះថ្ងៃទាបណាស់ហើយ ។ អ្នកលើកគំរោងនោះទៅថ្ងៃបន្ទាប់វិញ ។

***

«ខ្ញុំមកជំរាបលាលោកអ៊ុំទៅភ្នំពេញវិញហើយ ។»

នរិនពោលបន្ទាប់ពីអង្គុយចុះក្រោមផ្ទះអ៊ុំឆវ៉ា នឹងទទួលពែងតែក្ដៅដែលអ៊ុំសុភីចាក់អោយ ។

គិតទៅអ្នកមកកំពតបានមួយអាទិត្យជាងហើយ ។ អ្នកមកដល់ថ្ងៃចន្ទ អាទិត្យមុន ហើយសំរេចចិត្តទៅវិញថ្ងៃពុធ គិតទៅប្រាំបួនថ្ងៃគត់ ។

«យីអឺឆាប់ទៅវិញម្លេះ ក្មួយ?»

អ៊ុំឆវ៉ាឧទាន ។

«មិនឆាប់ទេអ៊ុំ ។ ខ្ញុំមកជិតដប់ថ្ងៃហើយ ។»

«សូមអោយសុខសប្បាយតាមផ្លូវណាក្មួយ ។»

អ៊ុំសុភីមានប្រសាសន៍ ។

«អរគុណអ៊ុំ»
«ម៉េចដែរទៅលេងកោះទន្សាយថ្ងៃមុនសប្បាយទេ?»
អ៊ុំឆរ៉ាសួរ ។
«បាទ សប្បាយណាស់អ៊ុំ ។»
អ្នកឆ្លើយ ហើយសំរួលកិរិយាបទអង្គុយអោយស្រួលគួចបន្តិច ។
«ថ្ងៃណាឱកាសមាននឹងអញ្ជើញអ៊ុំនឹងគ្រួសារទៅលេងដែរ ។
«ពួកអ៊ុំចាស់ៗហើយ មិនចំណាប់ខាងជើងទឹកទេ ។»
អ៊ុំសុភីមានប្រសាសន៍ ។
«ណាមួយគ្មាននរណាម្នាក់ក្នុងគ្រួសារអ៊ុំចេះហែលទឹកទេ ។ ពួកយើងខ្លាចពុលរលកផង ខ្លាចទឹកផង ប្រហែលជានឹងប្រកែកហើយបើកូយបបួល ។»
ហើយលោកសើចហាក់លួងចិត្តមាណពកុំអោយអន់ចិត្ត ។
«មិនអីទេអ៊ុំ ។ នៅមានកន្លែងច្រើនទៀតអ៊ុំអាចទៅបាន ។»
«កួយចាំបន្តិចទៅ អុមអោយឆពុំ នឹង ឆដាទៅបេះម្រេចខ្ចីខ្លះយកទៅផ្ញើរអ្នកផ្ទះកួយ ។»
អ៊ុំឆរ៉ាមានប្រសាសន៍ ។
«នៅផ្ទះមានតែម្រេចចាស់ទេ ។ កួយយកទៅ មានខ្ចី មានចាស់ខ្លះគ្រាន់ប្រើការតាមចិត្តប្រថ្នា ។»
«អូ មិនយកទេអ៊ុំ ។» នរៈប្រកែក ។
«រិទ្ធអោយច្រើនណាស់ទៅហើយ ។ ខ្ញុំមានតែពីរនាក់នឹងម៉ាក់ទេ មិនមានមាត់ច្រើនទេ ។ យកទៅបានតែចែកញាតិនឹងមិត្តភ័ក្តទេ ។ អ៊ុំទុកប្រើ ឬលក់ចុះ ។»
«អញ្ជឹងយកដូងខ្ចីខ្លះទៅកួយ ។ កុំប្រកែកអី អ៊ុំគ្មានអីអោយទេ ។ មិនមានអីជូនកួយខ្លះមិនកើតទេ កួយចិត្តបាននឹងអ៊ុំខ្លាំងណាស់ ។»
«អញ្ជឹងក៏បាន ។ តែកុំច្រើនពេកអ៊ុំ ។»
សូរជើងចុះពីជណ្តើរលើផ្ទះមក ។ ទាំងអស់គ្នាក្រឡេកទៅយល់ ឆពុំ ក្នុងសំពត់ផ្កាពណ៌កំបោរខ្ចី នឹងអាវដៃកុតពណ៌ផ្ទៃមេឃ ។
«ជំរាបសួរបង ។»
នរិនងើបសំដែងការគួរសម ។
«ជំរាបសួរអូន ។ មកដល់យូរហើយ?»
«ទើបម៉ិញដែរទេ បង ។»
ពេលឆពុំដាក់គូថអង្គុយក្បែរមាតាបិតានាងហើយ លោកអ៊ុំឆរ៉ាសួរកូនគាត់ថា ៖
«បាយទឹកឆ្អិនហើយឬនៅ ពុំ?»
ហើយគាត់ងាកមកនរិនទាំងមិនចាំចម្លើយពីបុត្រីលោក ។
«ពួកយើងចង់អញ្ជើញកួយបាយជុំគ្នាជាមួយយើងមួយពេលហើយថ្ងៃនេះ ។ បាយហើយសឹមទៅភ្នំពេញវិញ ។ មុនថ្ងៃលិចទៅដល់ហើយ ។»
ឃើញមាណពអេះអុញ ឆពុំបន្ទរទាំងមុខពព្រាយ ។
«បាយផ្ទះបងមួយពេលទៅអូន បើអូនមិនប្រកាន់ម្ហូបស្រុកស្រែស្រុកចំការទេ ។»
មើលទៅមិនអាចប្រកែកបាន នឹងកុំអោយអ្នកទាំងនោះយល់ថាខ្លួនប្រកាន់ឬក្បផង នរិនតប ៖
«ចឹង សុំរំខានមួយពេលហើយ ។»

«រំខានអីក្អួយអើយ ។ តែមិនមានម្ហូបអីពិសេសទេ ។ ពួកអ៊ុំអ្នកចំការហូបតែបន្លែដាំជុំវិញផ្ទះស្លជាមួយតែត្រីឆ្អើរក្រៀមក្រោះហ្នឹងឯង ។»

ស្គរជើងមួយគូទៀត ចុះពីលើផ្ទះមក ។ គឺឆដា ។ នាងកាន់នំកូរវោយសណ្តែកខៀវលីងមួយៗ មួយចានចុះពីលើផ្ទះមកទទួលភ្ញៀវ ។

«អញ្ជើញពិសារពុក ម៉ែ បង»

លោកអ៊ុំប្រុសងាកទៅសួរនារី ។

«បានអីហូបបាយថ្ងៃនេះ ឆដា? ។ ក្អួយនរិនគេនៅហូបដែរ ។ ថ្ងៃនេះគេមកលាទៅភ្នំពេញវិញហើយ ។ សំណាងហើយគេមកចំថ្ងៃកូនមិនធ្វើការ ។ កុំអីគ្មានចុងភៅចំណាននៅធ្វើម្ហូបទេ ។»

«ចាស មានសម្លប្រហើរទំពាំង ខ្យងស្រែ លាយត្រីអណ្តែង នឹងត្រីអណ្តែងអាំង ជាមួយបុកអំពិល ពុក»

នារីតបហើយអញ្ជើញអ្នកទាំងអស់គ្នាអោយសាកនំកូរដែលនាងនឹងឆពុំធ្វើម្តងទៀត ។

«ងាប់ហើយ ។ ក្អួយមកបាយមួយពេល ចំឯងហូបខ្យងខ្មៅ ។ ខ្លាស់លោកក្អួយស្លាប់ហើយ ។ »

អ៊ុំសុភីមានប្រសាសន៍ ។

«កុំអញ្ចឹងអីអ៊ុំ ។ សូមចាត់ទុកខ្ញុំដូចកូនក្អួយបង្កើតចុះ ។ មានអីទៅអៀន ទៅខ្លាស់នឹងគ្នាឯងនោះ ។ ណាមួយខ្ញុំចូលចិត្តសម្លប្រហើរណាស់ ជាពិសេសជាមួយត្រីឆ្អើរ លាយស្លឹកបាស ទំពាំង ត្រួយម្រះ និងត្រួយម្ទេស ។ ខ្ញុំមិនដែលសាកជាមួយខ្យងទេ ហេងហើយបានមានឱកាសសាកម្តងនេះ ។»

«ខ្ញុំទាយថាបងនឹងចូលចិត្ត ។»

ឆដានិយាយដោយញញឹម ។

«បន្តិចទៀតដឹងហើយ ។ សង្ឃឹមថាខ្ញុំនឹងមិនញ៉ាមរហូតមករកទៀតមិនឈប់នោះទេ ។»

នរិនតបញ្ចឹមៗបញ្ជាក់ថាអ្នកនិយាយលេង ។

អ៊ុំប្រុសឆ្លើយរាក់ទាក់ថា៖

«បើចូលចិត្តពេលណាមកក៏បាន ។ ទីនេះស្វាគមន៍ក្អួយជានិច្ច ។»

ហើយលោកងាកទៅឆដា ។

«កូនទៅរកវិទ្ធអោយបេះដូងភ្លើងនិងដូងតុកកែពីរបីផ្លាយមកគ្រាន់យកមកផ្ញើរក្អួយ ។»

នារីឆ្លើយទទួលហើយដើរចេញទៅ ។

«ខ្ញុំទៅរៀបបាយហើយណាពុកចឹង?»

ឆពុំសួរយោបល់ឪពុកនាង ។

«ទៅចុះកូន ។»

ពេលបាយ នរិនអ្នកភ្ញាក់ផ្អើលមិនស្មើរនឹងថ្វីដៃរបស់ឆដា នឹងឆពុំ ។ សម្លរប្រហើរខ្យងឈ្ងុយខ្លាយ ហើយមានរសឆ្ងាញ់ណាស់ ខ្យងស្រែច្របុះៗ ហើយមិនអន្តាយដូចអ្នកគិតនោះទេ ។ ទំពាំងទៀតសោតក៏ខ្ចី ហើយបន្សាបបានល្អមិនមានជាតិហាងទាល់សោះ ។ ជាមួយនឹងបន្លែបៃតងស្រស់ៗជាច្រើនមុខទៀត ក្រោមថ្វីដៃក្រមុំអ្នកចំការពីរនាក់បងប្អូន នរិនអត់លាន់មាត់មិនបានថា៖

«ខ្ញុំមិនដែលញ៉ាំសម្លប្រហើរណាឆ្ងាញ់ដល់ម្លឹងទេ ។ មែនណា ។ ខ្ញុំនិយាយដោយស្មោះមិនបញ្ចើចបញ្ចើរយកបាយមួយពេលហ្នឹងទេ ។»

ហើយទាំងអស់គ្នាសើចក្អាកក្អាយឡើង ។

«អ៊ុំអរណាស់ដែលសម្លរត្រូវមាត់ក្អួយ ។ អ៊ុំបានកូនពីរនាក់ហ្នឹងចំណាប់ណាស់ ។ គេពូកែឆ្អែណាស់រឿងម្ហូបម្ហាអីហ្នឹង ។» អ៊ុំឆរ៉ាមានប្រសាសន៍ ។

«ទៅអ្នកតអីពុកអើយ យើងអ្នកចំការនោះ ធ្វើម៉េចនិងអាចធ្វើម្ហូបមកផ្ទឹមម្ហូបបែបក្រុងទៅ ។ ប្អូននរិនប្រហែលជាដើរញ៉ាំច្រើនហាង ច្រើនស្រុក ច្រើនប្រទេសណាស់ហើយ គង់ដឹងភាពខុសគ្នាច្បាស់ណាស់ ។ មិនដឹងយើងស្លរនេះស្គុយប្រហុកពេកឬយ៉ាងម៉េចផង ។»

ឆពុំនិយាយ ។

«បាទ ខ្ញុំដើរបានច្រើនគួរសម ហើយបទពិសោធន៍បញ្ជាក់ច្បាស់ថា ម្ហូបតាមតំបន់ ស្រុក ឬប្រទេសនិមួយៗមានលក្ខណះពីសេសរបស់គេរៀងខ្លួន ។ ហើយម្ហូបបងនេះគឺឆ្ងាញ់ពិសេសហើយជួយអោយអ្នកញ៉ាំមានសុខភាពល្អណាស់ព្រោះមិនមានសាច់ ឬខ្លាញ់ទេ សុទ្ធតែបន្លែគ្រប់មុខស្រស់ៗ ។ ហើយនិយាយដោយត្រង់ទៅមិនស្អុយប្រហុកអីទេ ។ ល្មមម៉ាឆ្ងាញ់ ។ ខ្ញុំនិយាយដោយស្មោះត្រង់មែនណា ។»

«បងអរណាស់ បានដឹងដូចច្នេះ ។»

វិទ្ធស្តាប់គេមិនមាត់មិនកដូចសព្វដង ។

គេទាំងអស់គ្នាក៏បន្តបរិភោគអាហារមួយពេលនោះយ៉ាងរីករាយ នឹងមានមេត្រីភាព ដរាបឆ្អែតស្កប់ស្កល់រៀងៗខ្លួន ។

ម៉ោងប្រហែលមួយ នរិនជំរាបលាអ្នកទាំងអស់ មុនទៅគោរពលាឪពុកម្តាយរបស់វិទ្ធនឹងវិទ្ធ ។ ហើយអ្នកចេញរថយន្តទៅភ្នំពេញដោយអារម្មណ៍រីករាយផងនឹងមានលាយភាពស្រពាប់ស្រពោនខ្លះផង ច្របូកច្របល់គ្នាយ៉ាងម៉េចមិនដឹងទេ ។

មានអ្វីច្រើននៅកំពតដែលធ្វើអោយនរិនមិនចង់ឃ្លាត ។ ហើយមានអីច្រើនទៀតដែលបណ្តាលចិត្តអ្នកអោយចង់វិលមកជួបវិញក្នុងពេលឆាប់ៗ ។

មានបុប្ផាចំការម្រេចមួយទងដ៏ទន់ភ្លន់ នឹងសោភា ដែលបេះដូងអ្នកទាមទាមិនចង់អោយបែក ឬបើបែកអោយវិលរកវិញឆាប់ ។

ស្តាយណាស់ឆដាមិនមានទូរស័ព្ទ ។

មកដល់ក្បែរផ្សាកំពតអ្នកបើកវិទ្យុស្តាប់ ។

ចំរៀងមួយបទរបស់លោក ស៊ីន ស៊ីសាមុតដែលបន្លឺចេញពីវិទ្យុ អេហ្វអឹមរបស់ក្រុងកំពតបន្តិចក្រោយមកធ្វើអោយអ្នកកាន់តែស្រណោះ ។

កំពតកំពូលដួងចិត្ត
ដោយ
ស៊ីន ស៊ីសាមុត

អូ អូ អូ អូ

ឱខេត្តកំពតកំពូលដួងចិត្ត
ខ្ញុំសែនអាណិតហើយពិតជាស្ម័គ្រ
សុភាពកំពត ស្លូតបូតរាក់ទាក់
ជំពាក់ចិត្តចង ប៉ងស្ម័គ្រគ្មានល្ហែ ។

អាកាសត្រជាក់ប្រៀបបានសម្តី

អង្អែលហរទ័យអោយកើតក្ដីស្នេហ៍
សម្ផស្សកំពតនៅកតកែរប្រែ
គន់យូរវិតតែអោយស្នេហ៍ជាប់ចិត្ត ។

បើឃ្លាត ឃ្លាតទាំងស្រម៉ៃ
នាំក្ដីអាល័យ ទុក្ខភ័យផ្ដេកផ្ដិត
ព្រោះជារឿងកម្មប្រចាំជីវិត
កំពតដួងចិត្តអាណិតខ្ញុំផង ។

កំពតពោរពេញ លលេញឡើងថ្មី
កេសរល្អខ្ចី គាប់ចិន្ដាបង
ថ្ងៃណានឹងបាន ប្រាណបីត្រកង
កំពតរៀមផ្សងប៉ងជានិរន្ដ៍ ។

អូ អូ អូ អូ

***

# ជំរើសដ៏លំបាក

«ស្អែកនេះម៉ាក់ត្រូវទៅសៀមរាបបីថ្ងៃ ។»

លោកជំទាវផលប្រាប់បុត្ររបស់លោកនាយប់នោះបន្ទាប់ពីមកពីបាយល្ងាចជាមួយលោកឧកញ្ញាឧត្តម ជំទាវរ៉ាឌី នឹងបុត្រីទោលរបស់លោកទាំងពីរ ឈ្មោះបញ្ញាវី ។

«កូនទៅជាមួយម៉ាក់ទេ? កូនអាចទៅក្នុងនាមការងារក៏បាន កូនទៅដើរលេងក៏បាន ។»

នរិនអេះអុញ ។ អ្នកមិនដឹងថាគួរប្រាប់ម្ដាយខ្លួនពីជំនួបរបស់អ្នកជាមួយឆដាកាលពីថ្ងៃឬក៏អត់ទេ ។ អ្នកមានបំណងទៅកាហ្វេឌីឡៃត៍ម្ដងទៀតក្រែងបានជួបឆ័ដាដោយផ្ទាល់ ព្រោះនាងថានាងមកទីនោះសឹងរាល់ថ្ងៃ ។ អ្នកមានរឿងច្រើនចង់ដឹងពីនារី ។

«កូនអាចមិនទៅបានទេ ម៉ាក់?»

នរិនសួរលោកទាំងអល់អែក ។ «ខ្ញុំចង់ទៅរកមិត្តភ័ក្តិម្នាក់ដែលមិនបានជួបប៉ុន្មានឆ្នាំមកហើយ ។»

អ្នកមិនហ៊ានកុហកមាតាទេ ហើយក៏មិនហ៊ាននិយាយការពិតទាំងស្រុងដែរ ជាពិសេសការពិតមួយនេះ ។

«តាមចិត្តកូន ។»

លោកជំទាវអង្គុយផ្អែកទៅលើសាឡុងស្បែកទន់ល្មើយ ។

«គ្រាន់តែថាមួយឆ្នាំកូនមកម្ដងម៉ាក់ចង់អោយកូននៅជិតម៉ាក់អោយបានច្រើនបំផុតតាមអាចធ្វើទៅបាន ។ ម៉ាក់នឹកកូន ដឹងទេ ។ ថ្វីបើកូនធំប៉ុណ្ណេះទៅហើយក៏ដោយ ក៏ចំពោះម៉ាក់កូននៅតែជាកូនសម្លាញ់ដូចដែលកូននៅតូចដែលម៉ាក់មិនចង់អោយឃ្លាតពីទ្រូងទេ ។ នេះបើមិនចាំបាច់ត្រូវទៅដោយផ្ទាល់ ម៉ាក់នឹងមិនទៅទេ ។»

«អ៎ំ ម៉ាក់និយាយអិញ្ចឹងទៅហើយ ខ្ញុំមិនទៅជាមួយម៉ាក់ដូចជាគ្មានចិត្ត នឹងអកត្តញ្ញូពេកហើយ ។»

មាណពសើច ហើយទៅអង្គុយក្បែរម្ដាយអ្នកលើសាឡុង ។

«កុំបង្ខំចិត្តខ្លួនណាកូន ។ មកតាមម៉ាក់បានក៏មកចុះ ។ មិនបានទេ ម៉ាក់ក៏យល់ ។»

«កូនទៅបានជាមួយម៉ាក់ ។ កូនខានទៅសៀមរាបយូរដែរហើយ ។»

«ល្អណាស់កូន ។ អោយម៉ែដោះឡា នឹងអាតីជួយរៀបកវ៉ាន់ទៅកូន ។ បានហើយទៅងូតទឹកងូតភក់គេងចុះ ។ ស្អែកម៉ោង ប្រាំបួនយើងចេញដំណើរ ។»

«បាទម៉ាក់ ។»

ហើយនាយដើរទៅបន្ទប់ខ្លួន ប្រមូលខោអាវនិងកវ៉ាន់ចាំបាច់គ្រប់សព្វហើយ អ្នកហៅម៉ែដោះ នឹងតីមកជួយរៀបចូលវ៉ាលីធ្វើដំណើរ ។ បន្ទាប់មក៏អ្នកទៅងូតទឹកហើយផ្លាស់ខោអាវគេង ។

ក្រោយពីទម្លាក់ខ្លួនសន្ធឹងសន្ធៃលើគ្រែពូកដ៏មានផាសុកភាព អ្នកយកដៃគងថ្ងាសសញ្ជប់សញ្ជឹង ។

ម៉ោងដប់កន្លះទៅហើយ ។ ថ្មើរណោះឆដាកំពុងធ្វើអីហ្ន៎? ។ ប្រហែលជានាងកំពុងមើលទូរទស្សន៍ ឬស្តាប់ភ្លេង ប្រឡែងលេងជាមួយស្វាមីនឹងបុត្រនាងទេហ្នឹង ។

គិតដល់ត្រង់នេះ ចិត្តអ្នកហាក់ច្រណែនព្រួច ។

ឬនាងកំពុងនៅផ្ទះរង់ចាំផ្លូវស្វាមីនាងដែលកំពុងញ៉ាំអាហារខាងក្រៅផ្ទះជាមួយមិត្តភ័ក្តិគេ? ។ ចិត្តអ្នកត្រង់នេះ ហាក់អាណិតនាងបើពិតយ៉ាងនេះមែន ។

ឬក៏នាងទៅដែរទេដឹង? ។

អ្នកគេងរសាប់រសល់ មិនសុខមិនសាប់ ។ អ្នកនឹកហើយគិតតែផ្តាស ។

អ្នកបើកចំរៀងស្តាប់ក្រែងលោរម្ងាប់អារម្មណ៍មិនស្ងប់នេះបានខ្លះ តែហាក់គ្មានប្រយោជន៍ ។ ទីបំផុតអ្នកងើបក្រោះ យកម៉ាក់ប៊ុកប្រូ ១៥ អ៊ីញ រេតទីណា របស់អ្នកមកបើក ហើយឆែកមើលហ្វេសប៊ុកបន្តិច នឹងអានហើយតបម៉េល ទាំងអស់នោះបន្តិច ។

ក្រោយបំផុតអ្នកក៏ដាច់ចិត្តថានឹងសរសេរ អ៊ីម៉េលមួយអោយទៅ ឆដា ។

អ្នកចុចបើក ម៉េលអេបភ្លីខេសិន ។ អ្នកទាញឃើសើទៅដាក់ត្រង់កន្លែងត្រូវសរសេរ ម៉េលថ្មីហើយ វាយ អ៊ីម៉េល អាដគ្រេសរបស់ឆដាចូលទៅ ។

ប្រធានបទ ... ប្រធានបទអីទៅ? ។

ហើយគួរចាប់ផ្តើមយ៉ាងណាល្អទៅហ្ន៎? គួរសរសេរក្នុងនាមអីដែរ មិត្តចាស់ ឬសង្សារចាស់ទេ ។ មិត្តចាស់ ដូច មិនមែនទេ ព្រោះវាយូរណាស់មកហើយ ។ គេឆ្លងផុតដំណាក់កាលមិត្តហើយ ។ សង្សារចាស់ក៏មិនដែរ ហើយដូច មិនទំនងសោះ ។

គិតចុះគិតឡើងអ្នកព្រួយព្រួច ។

តើអ្នកកំពុងធ្វើអីហ្នឹង ។ តិចលោអ្នកកំពុងផ្លុំរងើកភ្លើងចាស់អោយមានអណ្តាតឆេះវិញដឹង? ។

ទេ មិនមែនទេ ។

អ្នកគ្រាន់តែចង់បន្ទាន់សម័យអ្វីៗគ្រប់យ៉ាងជាមួយនាងទេតើ ។ តិចនាងយល់ច្រឡំទៅ ។ បើស្វាមីនាងដឹង គេនឹង គិតយ៉ាងណាទៅ? គេអាចនឹងច្រឡំដែរ ។

តើអ្នកបម្រុងនឹងនាំរឿងក្តៅក្រហាយអោយនាងនឹងគ្រួសារហើយមែនទេ? ។

ហើយបើត្រូវសរសេរ តើគួរតែសរសេរជាខ្មែរ ឬជាអង់គ្លេសហ្ន៎? ។

សរសេរជាខ្មែរ តិចធ្លោយពាក្យណាដែលមានន័យឌុប ឬបង្កប់យ៉ាងណាមួយដោយអចេតនាទៅអាចបណ្តាល អោយនាងយល់ខុសមកលើអ្នក ក្រែងមិនល្អទេដឹង ។

បើសរសេរជាអង់គ្លេស ក្រែងមិនគួរទាល់តែសោះ ព្រោះទាំងនាងទាំងអ្នកសុទ្ធតែជាខ្មែរ ។ តិចនាងថា អ្នកបរទេសនិយម ឈ្លក់ជាតិ ភាសាគេ ភ្លេចកំណើតជាតិសាសន៍ឯងទៅ ។

អ្នកកាន់តែគិតកាន់តែមិនដឹងថាត្រូវធ្វើយ៉ាងណា ។ យី ហ្ន៎ អីក៏ពិបាកអីពិបាកយ៉ាងនេះ ។

អ្នកបន្ធូរដង្ហើមធំ ។ ភ្នែកអ្នកមើលពិដានតែអារម្មណ៍មិននៅនឹងពិដានទេ ។

ឆដាម៉េចក៏ធ្វើអោយអ្នកទៅជាស្មុគស្មាញយ៉ាងនេះ? បើអោយតែលេខទូរស័ព្ទមកមានអី ។ ឱកាសល្អ ហៅទៅ ហើយនិយាយគ្នាផ្ទាល់មាត់តែម្តងទៅ វាស្រួលជាងឆ្ងាយណាស់ ។

គិតដល់ត្រឹមហ្នឹង អ្នកឆ្ងល់អនេកម្តេចឆ័ដាមិនអោយលេខទូរស័ព្ទរបស់នាងមកអ្នក ។ ម្តេចនាងមិនសួររក លេខទូរស័ព្ទអ្នកវិញ ។ ឬនាងដឹងលេខរបស់អ្នកដែរ ព្រោះនាងដឹងពីអ្នកច្រើនណាស់ ។

តែមិនអាចទេ ។ លេខអ្នកគឺប្តូរាល់ឆ្នាំតើ ព្រោះអ្នកប្រើលេខមួយតែរយះពេលមួយខែទេ គឺក្នុងកំឡុងពេលដែលអ្នកមកលេងស្រុកខ្មែរប៉ុណ្ណោះ ។

ឬនាងដឹងលេខអចិន្រៃ្តយ៍របស់អ្នកនៅអូស្រ្តាលីដែរ ។

អាចដែរ ។ បើនាងដឹងគ្រប់យ៉ាងពីអ្នកនៅស្រុកគេប៉ុណ្ណឹងហើយ មានអីទៅពិបាកនិងដឹងត្រឹមលេខទូរស័ព្ទនោះ ។ គិតដល់ត្រឹមហ្នឹង អ្នកកាន់តែឆ្ងល់ណាស់ទៅទៀតថានាងដឹងគ្រប់យ៉ាងពីអ្នកដែលទៅនៅស្រុកគេឆ្ងាយហើយតាមរបៀបណាដែរ ។

កំព្យូទ័រអ្នករលត់ស្រើនយូរណាស់មកហើយក្នុងពេលដែលអារម្មណ៍អ្នករាយមាយមិនចំពោះទិសដៅ ។ អ្នកមិនដឹងធ្វើយ៉ាងណា ក៏ទាញគំរបស្រ្គីនចិទ ដាក់វាទៅលើតុក្បែរក្បាលដំណេកហើយ សម្ងំគេងតែម្តងទៅ ។

ចំរៀង Faded Love របស់ LeAnn Rimes ដែលបន្លឺចេញពីម៉ាស៊ីនចំរៀងអាយផតណាណូរបស់អ្នកធ្វើអោយអ្នកអួលអាក់ពេកណាស់ ។

"Faded Love"

By
LeAnn Rimes

As I look at the letters that you wrote to me
It's you that I am thinking of

As I read the lines that to me were so dear
I remember our faded love

I miss you darlin' more and more every day
As heaven would miss the stars above

With every heartbeat I still think of you
And remember our faded love.

As I think of the past, all the pleasures we had
As I watch the mating of the dove

It was in the springtime that you said goodbye
And I remember our faded love

I miss you darlin' more and more every day
As heaven would miss the stars above

With every heartbeat I still think of you
And remember our faded love.
And remember our faded love.

ស្តាប់បណ្តើរអ្នកគិតបណ្តើរ ។ អ្នកនឹកដល់គ្រាម្តាយបង្ខំអោយអ្នកបំភ្លេចឆដា ។ អ្នកគិតដល់ទឹកភ្នែករហាមជោគផែនថ្ពាល់រលោងទាំងគូរបស់នាងពេលនាងដឹងការពិតពីចិត្តរបស់អ្នក នឹងមាតាអ្នក ។ ហើយទឹកភ្នែកអ្នកក៏ហូរចុះមកឯងៗ ។

លើកនេះ ពេលនេះ អ្នកមិនជូតវាទេ ។ អ្នកទុកអោយវាហូររហែងធ្លាក់ទោឯជើងសក់ក្បែរត្រចៀក ហើយស្រក់តទៅលើខ្នើយដែលមានស្រោមសស្អាត ។ អ្នកទុកអោយវាហូរក្រែងវាអាចជួយបេះដូងដែលប្រៀបពេញដោយវិប្បដិសារិយ៍ នឹងវិប្បយោគរាប់ឆ្នាំនោះអាចបានធូរស្រាលខ្លះ ។

ឱទ្រូងអើយ!
ឱស្នេហ៍អើយ!

រាត្រីនោះ ទម្រាំនរះគេងលក់ ម៉ោងជិតពីរឯណោះ ។

***

# រឿងស្នេហ៍

«បងមកលើកនេះខ្ញុំមានដំណឹងល្អមួយជម្រាបបង»

ឆដាប្រាប់នរិនដោយបីតិសោមនស្ស ។ ភ័ក្រនាងកាន់តែស្រស់ជាមួយស្នាមញញឹមដ៏ប៉ប្រឹម ។

អ្នកទាំងពីរកំពុងដើរមើលចំការរបស់ឆដានារីរសៀលថ្ងៃអាទិត្យនោះ ។ នរិនមកលេងវិទូកាលពីម្សិលមិញ ហើយស្ទុះស្ទាមករកបណ្ដូលចិត្តភ្លាមមិនអោយយូរឡើយ ។

«ដំណឹងអី៎ ដា»

នរិនសួរ ។ ចិត្តអ្នកហាក់អរជាមួយមិត្តអ្នកដែរ ។

«មានគេមកដណ្ដឹងបងឆពុំហើយ ។ ចាស់ទុំព្រមព្រៀងគ្នាអស់ហើយ ។ បងឆពុំក៏មិនប្រកែកដែរ ។ បងសាកទាយមើលថាអ្នកណាគេគូដណ្ដឹងបងពុំ ។»

មាណពអរព្រួច ។ ផ្ការបស់អ្នក មិនមានអ្នកដណ្ដើមកាច់ទេ ។

«បងទាយ៉េម៉េចត្រូវទៅ ។ មិនមែនហោរផង ។»

«បងសាកថាមើល៍ តើគូគាត់អ្នកជិត ឬអ្នកឆ្ងាយ?»

«ចាស់ទុំព្រមព្រៀងឆាប់យ៉ាងនេះ ច្បាស់ជាអ្នកជួញជិតហើយ ។ អ្នកជួញឆ្ងាយត្រូវពិនិត្យ តាមដានមើលយូរណាស់»

«ខុសហើយ ។»

នារីតបហើយលោតហួសទៅមុខមុននរិន ហើយបែរមករកអ្នកទាំងដើរថយក្រោយ ។ សក់នាងដែលចងក្របួចទៅក្រោយផាត់ផាយប្រឡែងលេងដងកនឹងខ្នងរបស់នាង ។

«ទាយទៀតមើល៍»

«ប្រយ័ត្នដួលណា ។ ធំហើយដួលចាប់មិនឈ្នះទេ ។ តែយំបងមិនចេះលួងទេ មិនដែលមានប្អូនឬក្មួយផង ។»

«ទាយទៀតមើល៍»

នារីមិនស្ដាប់គិតតែពីរលោតហើយសើចស្វាញ ។ នាងខ្និកខ្នក់គួរអោយខ្នាញ់ ថ្ពាល់ស្ដាំដែលខ្ចួចកាន់តែស្រស់ ។

«អ្នកភ្នំពេញគេមកដណ្ដឹងបងពុំ មែនទេ?»

«អត់ទេ ។ ឆ្ងាយជាងហ្នឹងទៅទៀត»

«បងឈប់ទាយហើយ ។ មិនប្រាប់បង បងទៅសួរអ៊ុំក៏បាន ។»

«ចឹងប្រាប់ក៏បាន ។»

នារីដើរទន្ទឹមមិត្តនាងវិញ ។

«ឆ្នាំទៅមិញ មានអ្នកអាមេរិកម្នាក់ដែលមានឪពុកម្ដាយជាអ្នកស្រុកអ្នកភូមិជាមួយគ្នាហ្នឹងដែរ គាត់មកលេងហើយប្រទះបងឯផ្សារ ។ គាត់ពេញចិត្តបង ហើយលួចស្រឡាញ់ ។ គាត់សួរញាតិសួរមិត្តអោយជួបស៊ើបសួរពូជពង្សគ្រួសាររបស់ខ្ញុំ ហើយកាន់តែពេញចិត្ត ។ មិនអួតទេណា ព្រោះនេះមិនបានពាក់កណ្ដាលការពិតផង ។»

ហើយនាងញញឹមខ្ជឹបយ៉ាងរប៉ិលរប៉ូច មុនបន្តទៀតថា៖

«ហើយពេលវិលទៅអាមេរិកវិញគាត់ជំរាបប៉ាម៉ាក់គាត់ ។ ថ្មីៗនេះគាត់មកម្ដងទៀតជាមួយប៉ាម៉ាក់គាត់ហើយអោយចាស់ទុំចូលស្ដីដណ្ដឹង ។ ចាស់ៗជួបជុំគ្នាសួរនាំទៅគឺសុទ្ធតែញាតិតែមិត្តពីសម័យមុនសង្គ្រាមទេ ក៏ព្រមព្រៀងគ្នាទៅ ។»

«បងអរណាស់ ។»

នរះតបដោយសុទ្ធចិត្ត ។

ពេលដើរដល់ម្លប់ដូងក្រោយចំការ អ្នកពីរនាក់អង្គុយចុះហើយជជែកគ្នាលេង ។ ជំនោរល្វៀកៗផាត់ចុងដូងអោយរេរាំហាក់ជួយសាទរឆដាដែរ ។

«អិញ្ចឹងថ្ងៃណោះអូនហេងណាស់ ។ បងមានដំណឹងល្អមួយទៀតមកប្រាប់អូនហ្នំ ។»

«ដំណឹងអីបង ។»

នារីងាកខ្វាច់មកមើលមុខនាយ ។ កែវភ្នែកនាងខ្មៅថ្លាយង់ដូចនិលឆ្អៃ ។

«សាកទាយមើល៍»

មាណពវៀនតាមមិត្តអ្នក ។

«ម៉ាក់បងប្រគល់ក្រុមហ៊ុនអោយបងជាអ្នកគ្រប់គ្រងពេញសិទ្ធហើយមែនទេ?»

«មិនមែនទេ ។ បើមែន វាគង់មិនជាដំណឹងល្អសំរាប់បងទេ ។ អូនដឹងទេ គ្រប់គ្រងក្រុមហ៊ុនរវល់ហើយស្មុគស្មាញណាស់ ។»

«ចឹង អីទៅ?»

នរិនបែរមើលចំគូអ្នក ។

«បងមានអីជូនអូន ។»

ថាហើយអ្នកលូកទៅក្នុងហោប៉ៅយកប្រអប់កាដូខ្ចប់យ៉ាងស្អាតមួយចេញមក ។ អ្នកហុចវាអោយទៅនារី ។

«ស្អីគេហ្នឹងបង ។»

ឆដាសួរហើយក្រឡេកមើលផង ។ ធូន់ល្មមដែរ ។

«បើកមើលទៅដឹងហើយ ។»

ឆដាបើកមើលភ្លាម ។ បេះដូងនារីលោតឌុកឌាក់ ។ ពេលឃើញប្រអប់ខាងក្នុង ៖

«ទូរស័ព្ទ!»

នាងឧទានដោយត្រេកអរ ។ ហើយបើកប្រអប់ទៀត ។ ខាងក្នុងគឺទូរស័ព្ទណូគៀ ៨២៦០ មួយគ្រឿងថ្មីថែសពណ៌ក្រហមស្រស់ ។ នារីឃើញភ្លាមស្រឡាញ់ភ្លែតតែម្ដង ។ នាងយកវាមកផ្ទប់នឹងដើមទ្រូងនាង ។

«បងដាក់ស៊ីមរួចហើយ ។ អូនអាចហៅមកលេខបងបាន ចាំបងអោយអូនមើលលេខរបស់អូន ។»

នារីធ្វើតាមបង្គាប់ ។ នាងចុចហៅ ។ ទូរស័ព្ទនរិនរោទ៍ ។ អ្នកងើបឡើងហូតវាពីហោប៉ៅមក ហើយបង្ហាញធីតាអោយមើលលេខនាង ។

«អ៊ូ លេខពិសេសទៀត ។ អរគុណបង ។ តែហេតុអីបានអោយកាដូរអូន?»

នាងសួរបណ្ដើរមើលទូរស័ព្ទនាងបណ្ដើរ ។ នរិនចុចបិទទូរស័ព្ទអ្នក ។

«ថ្ងៃនេះជាថ្ងៃខួបមួយឆ្នាំគត់ដែលតាំងពីយើងស្គាល់គ្នាដំបូងតាំងពីទៅបូកគោ ។ ហើយជាខួប ៦ ខែដែលបងបានសារភាពពីចិត្តស្រឡាញ់បងចំពោះអូន ។ បងចង់អោយកាន់តែងាយទាក់ទងគ្នា ឃើញអូនហាក់មិនមានគំរោងនឹងទិញទូរស័ព្ទប្រើសោះ បងទ្រាំនឹកអូនមិនប្រាប់មុនគេងមិនបានក៏ទិញវាជូនអូនទៅ ។»

«អូនចង់ទិញដែរ តែបងដឹងស្រាប់ហើយ ប្រាក់ខែអូនត្រូវជួយសុធា នឹងវិសុទ្ធ ។ គ្នាមិនមានអីច្រើនទេ ។ រស់នៅភ្នំពេញទោះនៅវត្តក៏ដោយទាមទារការចំណាយច្រើនណាស់សំរាប់អ្នកខេត្តដូចពួកយើង ។»

«ហ្នឹងហើយមិនអោយបងជួយនោះ ។»

មាណពហាក់បន្ទោស តែទំនងនិយាយលេងជាង ។

«ពុកម៉ែថាមិនល្អទេ ។ លោកថាធ្វើអីញ្ចឹងគឺខ្សែលើ លើបងហើយ ។ ហើយណាមួយមិនសមភ្នែកញាតិផង បើគេដឹងទៅ ។ គេអាចថាយើងជាបញ្ចើភ្នែក ។ ពួកលោកអ្នកចំការមែន តែលោកមានមោទនះភាពនឹងជីវភាពលោកណាស់ ។»

«បងដឹងតើ ។ យ៉ាងហ្នឹងហើយទើបបងកាន់តែគោរពលោក ។ តែកុំភ្លេចណាបើមានអីចង់អោយបងជួយ កុំវអែងចិត្តអោយសោះ ។ »

ទាំងពីរក្រោកហើយដើរត្រសងកាន់ដៃគ្នាទៅតាមរងម្រេច ។

«និយាយចឹង បងជំរាបម៉ាក់បងអោយដឹងពីរឿងយើងឬនៅ?»

នារីសួរ ។ នាងហាក់បារម្ភ ។

«នៅទេ ។ លោករវល់ណាស់ ។ បងចាំឱកាសល្អនឹងជំរាបលោកហើយ ។ ឆាប់ៗនេះឯង ។»

នរិនពោលហើយឈានជើងដើរលេងៗហួសទៅ ។ នារីទៅតាមដែរ ។

«អូនបារម្ភក្រែងតែលោកជំទាស់ទំនាក់ទំនងយើងទេ ។ គ្រួសារអូនក្រណាស់ ។»

«មើលទៅលោកមិនគិតចឹងទេ ។ កុំគិតច្រើន ។ បើលោកមិនព្រម បងនឹងអង្វរលោក អោយអស់ពីសមត្ថភាពបង ។»

«គិតដល់រឿងនេះ អូនភើតដង្ហើមរាល់គ្រា ។ បើបែកបង អូនមុខជាលំបាកកាត់ចិត្តស្លាប់ហើយ ។»

«ស្ដាប់ទៅមិនដូចនារីរឹងប៉ឹងជាបង្អែករបស់ប្អូនប្រុសពីរនាក់ដែលបងស្គាល់សោះ ។»

នរិនចំអន់លេង ។

«រឿងផ្សេងគ្នាណាបង ។ ដៃករឹងគង់ទន់បានពេលភ្លើងលត់ដល់ណាបង ។»

***

«នរិន ល្ងាចនេះមិនចាំបាច់ចាំបាយម៉ាក់ទេ ។ កូនញ៉ាំបាយមុនម៉ាក់ទៅ ។ ម៉ាក់ប្រហែលជាយប់បន្តិចទើបមកផ្ទះវិញ ។»

លោក ជំទាវប្រាប់នរិនឲតុអាហារ មុននឹងចេញទៅធ្វើការថ្ងៃនោះ ។

«បាទ ម៉ាក់»

នរិនឆ្លើយទទួលហើយក្រេបកាហ្វេខ្មៅរបស់អ្នក ។ ភ្នែកអ្នកសម្លឹងត្រសងៗកាសែតខាំបូឌាដេលីដែលសណ្ដកខ្លួនក្បែរនោះ ។ រាល់ព្រឹកមានគេយកវាមកបោះអោយ ហើយបើមិនម៉ែដោះដឹងចិត្ត ក៏តីដែរ ដែលតែងដាក់វាក្បែរកៅអីអ្នកញ៉ាំកាហ្វេជាប្រចាំ ។

អ្នកមិនដេញដោលមាតាទេថ្វីបើធ្វើការជាមួយលោកក្នុងក្រុមហ៊ុនតែមួយអ្នកដឹងថាមាតាអ្នកមានការទំនាក់ទំនងការងារខាងក្រៅច្រើនជាងអ្នកដែលលោកបណ្ដោយអោយរៀនហាត់ការចាត់ចែងទូទៅរបស់ក្រុមហ៊ុនហើយ ។

អាហារព្រឹកហើយអ្នកទាំងពីរចូលរថយន្តរបស់គេរៀងខ្លួនហើយរថលូនក្បាលចេញទៅ ។

ណាប់បើកជូនលោកជំទាវ ។ នរិន បើកខ្លួនឯង ។ អ្នកមកដល់ក្រុមហ៊ុនហើយចូលទៅប៊ុយរ៉ូរបស់ខ្លួន ។ មិនឃើញមានវត្តមានរបស់ម្តាយអ្នកក្នុងប៊ុយរ៉ូលោកដែលនៅទល់មុខប៊ុយរ៉ូអ្នកទេ ។ អ្នកមិនសូវញសាញច្រើនក៏ចាប់ផ្តើមបើកកុំព្យូទ័រហើយរៀបចំធ្វើការទៅ ។

***

«ថ្ងៃនេះយើងទៅកំពត ណាប់ ។»

លោកស្រីបង្គាប់ស្ហ៊្វរលោកបន្ទាប់ពីរថយន្តចេញពីផ្ទះថ្ងៃនោះ ។

«ប្រញាប់បន្តិច ព្រោះយើងត្រូវវិលល្ងាច ។»

លោកជំទាវពោល មុខលោកស្មើរ ហើយមើលទៅក្រៅបង្អួចដោយអារម្មណ៍ហាក់កំពុងគិតអ្វីមួយលំបាក ។

«បាទលោកស្រី ។»

ណាប់ឆ្លើយដោយខ្លី ហើយមិនសួរវែងឆ្ងាយ ។ ភារៈរបស់អ្នកគឺបើកតែរថយន្តអោយមានសុត្ថិភាពជាការស្រេច ។ ចេញផុតផ្លូវ វេងស្រេង ហួសរង្វង់មូលចោមចៅអ្នកជាន់រថយន្តអោយគ្រហ៊ឹមងិលឡើង ។ ឡិចស៊ីស SUV ដ៏ទំនើបជ្រែកខ្យល់តាមផ្លូវជាតិលេខបីដ៏រលកតម្រង់ទៅក្រុងកំពត ។

មកដល់អង្គតាសោមម៉ោងប្រហែលប្រាំបួន ។ លោកស្រីផលបង្គាប់អ្នកអោយហួសទៅដោយមិនឈប់ស្រស់ស្រូបអីទេ ។ សំណាងហើយដែលអ្នកបានបាយពីព្រឹកធ្ងន់ពោះ កុំអីក្នុរពោះមិនស្មើរទេ ។

មកដល់កំពតម៉ោងជិតដប់មួយ ។

លោកជំទាវបង្គាប់ណាប់អោយហួសតាមផ្លូវជាតិលេខ ៣៣ ទៅក្រុងកែបបន្ត ទៀត ។ មកដល់ កំពង់ត្រាច លោកអោយអ្នកឃ្លាំមើលផ្លូវលំចាក់បេតុងមួយខាងឆ្វេងដៃ ជាផ្លូវឯកជន ។ ពេលណាប់ឃើញហើយ លោកអោយបត់តាមផ្លូវនោះប្រហែលពីរគីឡូក៏មកទើរត្រង់វិឡាតឿមួយម៉ូដទំនើប មានដំបូលពីរជាន់ក្រហមច្រាល សង់លើទីវាលស្រឡះមួយដែលមានស្មៅខៀវខ្ចីកាត់ត្រឹមរាបដល់ក្រាបដូចកំរាលព្រំ ។ ឆ្ងាយបន្តិចពីផ្ទះគឺចំការម្រេចល្ងឹងល្ងើយរត់ដង្ហែរជាជួរត្រង់ប្រេញយ៉ាងមានរបៀបទៅជាប់នឹងជើងភ្នំឯនាយឆ្ងាយ ។

ណាប់ចតរថយន្តហើយស្ទុះស្ទារទៅបើកទ្វារជូនចៅហ្វាយអ្នក ។ ពេលអ្នកទាំងពីរដើរតម្រង់ទៅរកភូមិគ្រឹះដ៏ប្រណិតនោះ យុវជនម្នាក់បើកទ្វារចេញពីផ្ទះមក ។

គេមានរាងខ្ពស់ស្រឡះ សក់វែងគ្របត្រចៀក មាឌតូចល្មមតែសាច់ហាប់ណែន ។ គេមានអាយុប្រហែលនរិនដែរតែមានសម្បុរខ្មៅស្រគាំជាងឆ្ងាយដោយប្រហែលជាត្រូវថ្ងៃញឹកញាប់ ។ គេចេញមកជំរាបសួរលោកជំទាវសម្តែងការគួរសម ។

«ជ្រាស់ជាវិទូហើយ ។»

លោកជំទាវសំពះតប ។

«បាទ ។ សូមអ្នកមីងអញ្ជើញចូលមកខាងក្នុងមក ។»

ទាំងពីរនាក់ដើរចូលផ្ទះទៅ ។ ណាប់មិនចូលទេ អ្នកដើរមើលជុំវិញផ្ទះ នឹងចំការដ៏ធំនេះ ហើយនឹកក្នុងចិត្តថាបើសិនជាអ្នកមានចំការមួយដូចហ្នឹង ប្រហែលជាមិនដូរនឹងនិព្វានពេលចែកឋានទេមើលទៅ ។ គិតហើយអ្នកញញឹមតែម្នាក់ឯង ។

«មីងទំនេរ ឆ្លៀតបានមកលេង ចំពេលលោកផល្គុន នឹងអ្នកបងល័ក្ខមិននៅ ។ លោកយ៉ាងម៉េចហើយ?»

លោកស្រីសួរវិទូ ក្រោយពេលទទួលទឹកពីអ្នកហើយ ។

វិទូអង្គុយចុះឯសាឡុងបេងម្ខាងទៀត ទល់មុខលោក ។

«ម៉ាក់លែងអីហើយ ។ លោកទើបទូរស័ព្ទមកយប់មិញនេះឯង ។ លោកទៅសាំងហ្គាពួរហ្នឹងប្រចុចញ៉ូចដែរហ្នឹង ព្រោះលោកស្រាប់តែសុខៗចុកក្នុងទ្រូងរហូតស្វាយមុខស្វាយមាត់មួយឈឺបទៅ ។ ពេទ្យនៅនេះថាមិនអីទេ តែប៉ាក្រែងមានអីមិនស្រួលក៏នាំម៉ាក់ទៅជួបគ្រូពេទ្យប្រចាំខ្លួនគាត់ភ្លាមៗទៅ ។ គាត់ផ្តាំអោយសុំទោសអ្នកមីងផង ដែលមិនបាននៅទទួល ។ ប៉ាលោកថានឹងឆ្លៀតចូលលេងអ្នកមីងពេលមកពីសាំងហ្គាពួរវិញ ។»

«លោកមកវិញថ្ងៃណាដែរ?»

«អាស្រ័យលើសុខភាពម៉ាក់ទេ ។ តែប្រហែលមិនដល់មួយអាទិត្យទេ លើកលែងតែលោកចង់នៅដើរលេងទីនោះអោយយូរបន្តិច ។ តែប្រហែលមិនចឹងទេ ។ លោកមិនចូលចិត្តដើរហើរអីទេ ។ ចឹងហើយទើបងាកមកធ្វើចំការច្បារទីអីវិញ ។»

«កន្សែវចូលសាច់ការយើងវិញ ។»

លោកជំទាវគ្រហែមជំរះកបន្តិច ។ លោកក្រេបទឹកមួយក្អឹកហើយបន្តះ

«ក្មួយប្រាប់មីងមើលហេតុអីបានជានរិនខស្បាហ៍មកទីនេះម្ល៉េះ ។ កុំលាក់មីងណា ។ មីងមិនមែនមិនដឹងអីសោះទេ ។ មីងដឹងពីប៉ានឹងម៉ាក់ក្មួយខ្លះមកដែរហើយ តែថ្ងៃនេះចង់ឮពីក្មួយដែលជាមិត្តរបស់នរិន នឹងជា ក្មេងៗដូចគ្នាដោយផ្ទាល់ ។»

លោកក្រេបទឹកមួយក្អឹកទៀត ។ វិទូអេះអុញ ។ លោកជំទាវបន្តថា ៖

«ក្មួយយល់យ៉ាងណាដែរ ។ បំណាច់មកដល់ទីនេះហើយ មីងចង់មកជួបគ្រួសារគេនោះដោយផ្ទាល់ផង ។ ក្មួយមិនបាច់បារម្ភទេ ។ មីងមិនចោលមុខមីងនឹងក្មួយក៏ដូចជាប៉ាម៉ាក់ក្មួយទេ ។ មីងគ្រាន់តែចង់ទៅជួបសួរនាំលោកប្រយោជន៍អោយបានឃើញពីជីវភាពគ្រួសារនោះ ក៏ដូចជាចរិកឫកពាគេដោយផ្ទាល់ទេ ។»

ទាល់តំរេះ វិទូរក៏រៀបរាប់ហូរហែរគ្រប់យ៉ាងដែលអ្នកបានដឹង ។ លោកជំទាវស្តាប់ដោយយកចិត្តទុកដាក់ ។ មុខលោកជូនញញឹម ជូនស្មើរធេង ។

***

# រៀងរៀន

«មួយឆ្នាំជាងហើយ តាំងពីកូនចប់បរិញ្ញា ។ កូនជួយម៉ាក់ឯក្រុមហ៊ុនបានចំណាប់ណាស់ ។ ម៉ាក់ធូរច្រើនមែនទែន ។»

លោកជំទាវផលនិយាយជាមួយបុត្រលោកយប់មួយបន្ទាប់ពីនាយមកពីញ៉ាំអីខាងក្រៅជាមួយមិត្តអ្នកប៉ុន្មាននាក់ ។ ពេលនរិនមកផ្ទះឃើញម្ដាយអ្នកនៅអង្គុយមើលទូរទស្សន៍ក្នុងបន្ទប់ទទួលភ្ញៀវនៅឡើយអ្នកក៏មកអង្គុយក្បែរលោក ។

«តែកូនកុំភ្លេចដោយរវល់តែជក់និងការងារភ្លេចបណ្ដាំប៉ាកូនណាកូន ។»

លោកបន្ត ។

នរិនស្ដាប់លោកដោយយកចិត្តទុកដាក់ ។ អ្នកយល់ថាប្រហែលនេះជាឱកាសល្អហើយ ដែលអ្នកជំរាបលោកពីរឿងអ្នកនឹងឆដា ។

«ប្រហែលជាកូនគិតថាកូនមិនរៀនទៀតក៏កូនមិនអត់ការធ្វើដែរ ។»

លោកបន្តហើយបិទសំឡេងទូរទស្សន៍ដោយទុកអោយតែរូបភាពលោតលេងតែឯងលើកញ្ចក់ម៉ាស៊ីន ។

«តែមនុស្សដែលមានលទ្ធភាព សមត្ថភាព នឹងឱកាសដូចកូន គួររៀនទៀត រៀនអោយច្រើនទៀត ដើម្បីប៉ាកូន ដើម្បីកូនខ្លួនឯង  ដើម្បីគ្រួសារយើង ក៏ដូចជាដើម្បីជាតិយើងដែរ ។ ប៉ាកូនចង់អោយកូនជាបណ្ឌិត ធ្វើការស្រាវជ្រាវ ហើយរកឱកាសផ្សព្វផ្សាយចំណេះដឹងថ្មីៗ មានប្រយោជន៍ដល់មនុស្សជាតិផងគ្នា ។ ពេលកូនស្លាប់បង់ទៅចំណេះដឹងដែលកូនផ្សាយទៅ នឹងរស់ជាអមតះជាមួយឈ្មោះកូន ក៏ដូចជាគ្រួសារ នឹងជាតិសាសន៍យើងដែរ ។ មិនមានខ្មែរច្រើនអ្នកទេក្នុងបច្ចុប្បន្នកាល ដែលជ្រើសដើរតាមផ្លូវ នេះ ។ ភាគច្រើនរវក់នឹងទ្រព្យលោកីយ៍ហើយរស់បង្ហិនពេលវេលាចាំស្លាប់ប៉ុណ្ណោះ ។ ម៉ាក់យល់ស្របតាមបណ្ដាំប៉ាកូនទាំងស្រុង ។ ម៉ាក់ក៏ចង់ឃើញកូននាំចំណេះដឹង នឹងប្រយោជន៍ជូនមនុស្សជាតិដែរ ។»

«កូនមិនភ្លេចបណ្ដាំលោកប៉ាទេ ។ កូននឹងរៀន ហើយសំរេចបំណងនេះអោយបាន ។»

«ហើយកូនចាំពេលណាទៀត ។»

លោកចោទឡើង ។

«ទាន់ខ្លួននៅក្មេងណាកូន ។»

លោកតាស៊ូតឿនរំលឹក ។

«ម៉ាក់កូនមានរឿងមួយចង់ជម្រាបម៉ាក់ ។»

ហើយអ្នកក៏ជំរាបលោកត្រួសៗពីរឿងអ្នកនឹងឆដា ក៏ដូចជាបំណងរបស់អ្នក ។

លោកជំទាវស្តាប់ដោយស្ងៀមស្ងាត់ មិនមាត់កអ្វីទាំងអស់ ។ លុះអ្នកនិយាយចប់ហើយ បរិយាកាសក៏ស្ងាត់ជ្រងំទៅតាមនោះដែរ ។ នាឡិកាប៉ោលយោលទ្រនិចរហូតឮដល់អ្នកទាំងពីរដោយសារបរិយាកាសដែលស្ងប់ស្ងាត់ ។ មួយសន្ទុះក្រោយមកលោកជំទាវផលទំលុះភាពស្ងប់ស្ងាត់នោះដោយវាចាថា ៖

«ម៉ាក់អាចបូរាណបន្តិចក៏ថាបាន តែម៉ាក់យល់ថាកូនរៀនសិនហើយសឹមគិតពីរឿងស្នេហា ។ ម៉ាក់មិនហាមកូនទេ តែត្រូវគិតពីអ្នកដែលកូនស្រឡាញ់នោះ នឹងអ្នកដែលកូនត្រូវជួបរាប់រយ រាប់ពាន់នាក់ទៀតពេលកូនទៅរៀននៅស្រុកគេ ។ កូនទៅបាត់ទៅ ហើយកូនអោយគេចាំ មិនល្អសម្រាប់ចិត្តគេទេ ។ គិតឡើងវិញណាកូន ។ កូនត្រូវដឹងថាអ្នករងចាំរស់ជាមួយនឹងពេលវេលាដែលរំកិលខ្លួនយឺតយ៉ាវជាងអ្នកណាៗទាំងអស់ ។ គេនិងទៅជាយ៉ាងម៉េចវិញបើកូនទៅកន្លែងថ្មី ជួបមនុស្សថ្មី ក្នុងសង្គមថ្មី កូនច្បាស់ចិត្តទេថាកូននឹងមិនប្តូរចិត្ត ? កូនម៉េចនឹងដឹងដឹងបានពីអនាគតថាមានអីខ្លះនឹងកើតឡើង? ។ ម៉ាក់ដឹង ប្រហែលកូនកំពុងគិតថា កូនស្គាល់ចិត្តខ្លួនឯងច្បាស់ណាស់ ថាកូននឹងមិនប្រែចិត្ត ។ តាមដែលម៉ាក់ ស្គាល់កូន ដោយចិញ្ចឹម អប់រំកូនដោយផ្ទាល់ដៃតាំងពីតូចក្រចកឆ្មារមក ម៉ាក់គិតថាកូនអាចមិនដូរចិត្តកូនដែរ ។ តែកូនអើយ ចិត្តមនុស្សណា គឺក្រោមសំពាធបរិយាកាស នឹងពេលវេលាទេ ។»

នរិនអ្នកស្តាប់ដោយស្ងាត់ស្ងៀម ។

ម្តាយអ្នកនិយាយមានហើយសមហេតុផលណាស់ ។ អ្នកបានសន្យាថាជាមួយប៉ាអ្នកថាអ្នកនឹងសម្រេចបំណងលោកអោយបាន ។ ប៉ុន្មានឆ្នាំក្រោយពេលលោកចែកឋានទៅ ពេលវេលា នឹងបរិយាកាសបាននាំអ្នកអោយជួបឆដាជំពាក់ចិត្តលើនាង ហើយមិនប៉ុន្មានផង អ្នកហាក់ចង់បន្ថយអធិភាពរបស់បណ្តាំមរណះរបស់អ្នកមានគុណរបស់អ្នកទៅហើយ ។

តែអ្នកប្រាកដចិត្តខ្លួនណាស់ថាអ្នកមិនលេងសើចជាមួយឆដាទេ ។ អ្នកមិនដែលមានអារម្មណ៍ល្អជាមួយអ្នកណាដូចពេលនៅជាមួយឆដាទេ ។ អ្នកតែងប្រយ័ត្នចិត្តណាស់មិនអោយធ្លោយទៅលង់ស្រឡាញ់អ្នកណាងាយៗទេ ព្រោះអ្នកដឹងថាអ្នកមានផ្លូវវែងឆ្ងាយត្រូវដើរ នឹងកតព្វកិច្ចធំៗច្រើនទៀតដែលត្រូវបំពេញចំពោះគ្រួសារ ក៏ដូចជាខ្លួនគេផ្ទាល់ចំពោះប្រទេសនឹងមនុស្សជាតិ ។ តែអ្វីដែលកើតឡើងរវាងអ្នកនឹងឆដា គឺហួសការទប់ចិត្ត ។ ជាព្រហ្មលិខិតទេដឹង ។ ឬជាគូព្រេង ។ ប្រហែលក៏ជាគូកម្មទេដឹង ។ ខិស្វមកុំអោយយ៉ាងនោះអី ។

«ម៉ាក់កូនអាចសុំពេលមួយឆ្នាំទៀតសឹមទៅរៀនបានទេ ម៉ាក់?»

អ្នកមើលមុខម្តាយអ្នកដោយទទួចអង្វរ ។ លោកជំទាវយកតេឡេមកបិទទូរទស្សន៍ហើយងើបឡើង ។

«ការអ្វីធ្វើអោយហើយ ។ កុំទុកថ្ងៃនេះ ថ្ងៃនោះអោយវាបង្កើតកេរ្តិ៍ណា នរិន ។»

សំឡេងសំឡេងលោកមាំណាស់ ។

នរិនអោនមុខចុះ មិនហ៊ានមើលចំមុខម្តាយអ្នក ។

«បានហើយទៅគេងចុះ ។»

លោកដេញ ។ ហើយលោកដើរទៅបន្ទប់លោកបាត់ទៅ ។ នរិននៅអង្គុយអោនមុខជ្រប់ដងែល ។

***

ពាក្យចាស់ដែលថា កុលាបតែងមានបន្លា ស្នេហាតែងមានឧបសគ្គ មិនខុសមែន ។ ប្រហែលជាអញ្ចឹងទេដឹងទើបចាស់ៗជំនាន់បូរាណមិនអោយកូនៗលោកប្រសេចប្រសាចមានស្នេហាស្នេហ៍ហឹតតាមអំពើរចិត្តគេ ។ ជាប្រពៃណីទៅហើយ ពួកលោកជាអ្នកកំណត់ពេលណាស្នេហាគួរកើតមានឡើងហើយគួរកើតឡើងចំពោះអ្នកណា ។ កាលនោះមិនមានទេស្នេហាមុនអាពាហ៍ពិពាហ៍ ។ បើមានគឺជាអាពាហ៍ពិពាហ៍ ជាគ្រួសារតែម្តង ។

ប៉ុន្តែតាំងពីពេលដែលយុវជនកាន់តែច្រើនគ្នាទៅមានសិទ្ធបំពានលើការប្រព្រឹត្តជាទំនៀមនេះ ប្រែមកជ្រើសយកការស្រឡាញ់គ្នាតាមចិត្តខ្លួន កម្រណាស់ដែលស្នេហាមិនមានឧបសគ្គ នឹងវិប្បដិសារិយ៍ ។ មើលចុះក្នុងស្រុកយើង តាំងពីស្នេហារបស់ ទុំនឹងទាវ វិធាវី នឹងប៊ុនធឿន ហើយស្រុកគេដូចជាស្នេហារបស់ ជូលៀត នឹងរ៉ូម៉េអូ ជាឧទាហរណ៍ស្រាប់ ស្នេហាមិនបានធ្វើអោយជីវិតយុវជនទាំងនោះមានភាពល្អប្រសើឡើងអោយយូរអង្វែងទេ ។ សុភមង្គល នឹងភាពត្រេកត្រអាល បានមកពីស្នេហាទាំងនោះឆាបឆេះចោលរស្មីបំភ្លឺដូចភ្លើងចំបើងមួយព្រឹបហើយក៏រលត់ទៅវិញក្នុងពេលដ៏ខ្លី បន្សល់នៅផេះដែលហុយចូលច្រមុះហើយប្រឡាក់ដៃ ពេលត្រូវទឹកក៏រលាយបង់អស់ បំផ្លាញរូបភាពដើមរបស់ចំបើងដែលបើមិនត្រូវភ្លើងដុតបំផ្លាញទេអាចថិតថេរបានអង្វែងយូរទៀត ។

នរិនអ្នកដល់ដំណាក់កាលនេះហើយ ។ ម្តាយអ្នកចង់អោយអ្នកនៅជាចំបើងមិនទាន់អោយឆេះភ្លើងនៅឡើយ ព្រោះលោកបារម្ភក្រែងភ្លើងឆេះចំបើងអ្នកអោយទៅជាអសារបង់ ។

តែអ្នកមិនចង់ដូច្នេះទេ ។ អ្នកចង់ធ្វើជាចំបើងដែលមានភ្លើងឆេះ ហើយអ្នកអោយភ្លើងឆេះយឺតៗ ។ អ្នកគិតថាអ្នកអាចមានលទ្ធភាពនឹងគ្រប់គ្រងមិនអោយភ្លើងឆេះចំបើងអ្នកអោយឆាប់ពេកទេ ។ អ្នកគិតអោយវាឆេះយឺតៗហើយភ្លឺយូរបំផុតតាមអាចធ្វើទៅបាន ។

ឱ ចំបើងអើយ អ្នកអាចនឹងធ្វើដូច្នេះបានដែរទេ ។

***

# សៀមរាប

«កូនថាកូនចង់ទៅរកមិត្តភ័ក្តិដែលខានជួបគ្នាយូរ បើមិនមកជាមួយម៉ាក់ទេ ។ គេជាអ្នកណាដែរ? ម៉ាក់ស្គាល់គេទេ?»

លោកជំទាវសួរបុត្រលោកដែលអង្គុយទន្ទឹមលោកក្នុងរថយន្ត ក្រោយពេលគេស្រស់ស្រូបអាហារពេលព្រឹកឯសណ្ឋាគារ ភ្នំពេញហើយ ។ រថយន្តទើបរត់ផុតស្ពានជ្រោយចង្វារបន្តិចទេ ។

«ម៉ាក់ស្គាល់ ។ តែកូនសូមចិត្តម៉ាក់កុំសួរពីរឿងនេះទៀតបានទេ ។»

មាណពតបដោយមុខស្មើរ ។

«កូនពិបាកនឹងរៀបរាប់ណាស់ ។»

«សុំទោសផងអញ្ចឹង ។ សង្ឃឹមថាម៉ាក់មិនបានធ្វើអោយកូនមិនសប្បាយចិត្ត ឬមានរឿងអីមិនល្អកើតឡើងចំពោះមិត្តកូនទៅចុះ ។»

«មិនចឹងទេម៉ាក់ ។ មិនមានរឿងអីមិនល្អទេ ។»

ហើយគេក៏ស្ងាត់ទៅ ។ ហួសវត្តព្រែកលៀបបន្តិចលោកជំទាវសួរបុត្រលោកដោយបង្វែសាច់រឿងថា ៖

«ម៉េចហើយ កូនសម្រេចចិត្តយ៉ាងណាអំពីអនាគត? កូនចង់នៅធ្វើការនៅអូស្ត្រាលីហ្នឹងរហូត ឬចង់មកនៅស្រុកយើងវិញ?»

«ម៉ាក់មានបំណងម្តេចដែរ?»

នរះ សួរម្តាយរបស់អ្នកវិញ ។ ភ្នែកអ្នកសំលឹងមើលទេសភាពសងខាងផ្លូវ ។ ណាប់បើករថយន្តដោយស្ងៀមស្ងាត់ធ្វើហាក់មិនឮការសន្ទនារបស់ពីរនាក់ម្តាយកូន ។

«ស្រុកយើងកំពុងអភិវឌ្ឍន៍ មនុស្សមានចំណេះដឹង នឹងមិនក្បត់ឧត្តមគតិដូចកូនមានមិនច្រើនទេ ។ នៅស្រុកគេកូនគ្រាន់តែជាគ្រសមួយគ្រាប់ក្នុងចំណោមគ្រសមួយគំនរប៉ុណ្ណោះ ។ នៅទីនេះកូនជាពេជ្រមួយគ្រាប់សំរាប់ជាតិយើង ។ ថ្វីបើម៉ាក់អោយកូនទៅរៀនស្រុកគេ ហើយដាក់ពាក្យយកសញ្ជាតិមែន ម៉ាក់មិនដែលគិតថានឹងអោយកូនទៅនៅទីនោះរហូតទេ ។ ម៉ាក់គ្រាន់តែចង់បង្ហា ក្រែងស្រុកប្រែប្រួលយ៉ាងណាយ៉ាងណីទៀត ពូជខ្មែរ ឈាមខ្មែរ ដែលចេះដឹង នឹងស្រឡាញ់ស្រុកទេស នឹងមិនបាត់បង់ ។ ចុះកូនវិញ ចង់យ៉ាងណាដែរ?»

«ខ្ញុំចាប់ផ្តើមគិតពីរឿងហ្នឹងបណ្តើរៗហើយ តែមិនទាន់គិតសំរេចថាយ៉ាងណាទេ ។ ខ្ញុំស្រឡាញ់សុខសន្តិភាព សេរីភាពពេញលេញ ការចេះគោរព អោយតម្លៃគ្នា នឹងភាពជឿនលឿនរបស់ស្រុកគេ តែខ្ញុំដូចជាក្អែកក្នុងហ្វូងរំពេរ ឬត្រីដែលឡើងគោកអិញ្ចឹងនៅទីនោះ ។»

«ស្រេចចិត្តកូនទេ ។ កូនគិតតាមសម្រួលចុះ ។»

ទាំងពីរនាក់ស្ងាត់មាត់ ។

ហួសបាក់ខែងទៅផ្លូវរាងស្មើយរថយន្តនឹងម៉ូតូបន្តិច ។ ណាប់បើករថអោយលឿនជាងមុនបន្តិច ។

លោកជំទាវប្រាស់ខ្លួនផ្អែកទៅលើកៅអីរថ ហើយសម្ងំធ្មេចភ្នែកយកកម្លាំង ។ នរិនយក អាយផតណាណូ របស់នាយមក ដោតជាមួយនឹង អៀរផត របស់វាហើយញាត់ចូលត្រចៀកស្តាប់ចំរៀងរបស់អ្នក ។ មកដល់ផ្លូវលេខ ៦១ បែកទៅផ្លូវជាតិលេខ ៥ វិញ ណាប់បត់រថយន្តមកស្តាំ តាមផ្លូវទៅកំពង់ចាម ផ្លូវលេខ ៦A ។

តាមផ្លូវមានគេលក់ផ្លែឈូកហូរហែរចងជាបាច់មានតូចមានធំហើយតំរៀបគ្នាយ៉ាងល្អ ។ សងខាងផ្លូវគឺវាលស្រែទំនាបល្វឹងល្វើយដាច់កន្ទុយភ្នែក ។ ខ្លះទើបច្រូតហើយថ្មី ខ្លះដែលទុមឃឹត កំពុងអោនក្បួរ ទន់ខ្លួនរង់ចាំកសិករដែលមមាញឹកប្រមូលផល ។

មកដល់បាធាយ នរិនងាកទៅឆ្វេងដៃផ្លូវឃើញភ្នំបាធាយ ឬបាថយបើតាមរឿងព្រេងខ្មែរ ។ អ្នកឆ្ងល់ណាស់ អ្នកទៅមកៗផ្លូវនេះប៉ុន្មានសិបដងហើយ ម៉េចក៏មិនដែលឃើញគេចូលលេងភ្នំនេះដូចភ្នំនានាទៀត ។ បើមិនមកជាមួយម៉ាក់អ្នកទេ អ្នកប្រហែលជាចូលទៅមើលម្តងអោយអស់ចិត្តហើយ ។

មកដល់ស្គន់ពេលផ្លូវ ៦A បែកជាផ្លូវលេខ ៦ ទៅសៀមរាប នឹង ៧ ទៅកំពង់ចាម ណាប់សុំពេលចូលបន្ទប់ទឹកបន្តិចនៅហាងសាំងកាល់តិចមួយ ។ អ្នកលក់ផ្លែឈើ ស្រូវស្រតម្រង់ឡាន ក្រែងអ្នកដំណើរនេះទិញអីខ្លះយកទទួលទានតាមផ្លូវ ។ នរិនចុចបង្អួចចុះហើយមើលទំនិញទាំងនេះ ។ អ្នកញញឹមខ្ចីប ពេលនារីក្មេងម្នាក់ក្នុងវ័យប្រហែល ១៥ ឆ្នាំពាក់អាវដៃវែងពណ៌ផ្កាឈូកដិត មានពងជីងចក់ចំរុះពណ៌លម្អបន្ថែម លើកអាពីងបំពងមួយពីថាសរបស់ស្រីវ័យកណ្តាលម្នាក់មកបង្ហាញអ្នក ។

«ជួយទិញខ្លះទៅពូ»

នាងទទូច ។

«ទើបចៀនថ្មីៗទេ ស្រួយហើយឆ្ងាញ់ណាស់ មែនណាពូ ។»

នរិនងាកទៅម្តាយដែលលោកសម្លឹងមកដែរ ។

អ្នកនឹកកាលពីនៅតូចកាលដែលម្តាយនាំអ្នកមកតំបន់នេះហើយបង្គាប់អោយអ្នកសាកញ៉ាំពីងពាងយក្សនេះជាលើកដំបូង ។

អ្នកនឹកដល់មិត្តភក្តិអូស្រាលីរបស់អ្នកដែលមិនថាតូចឬធំទេ គឺសុទ្ធតែខ្លាចពីងពាងណាស់ ។ បើពួកគេមកឃើញអាពីងទីនេះ មិននឹងយ៉ាងណាទេហ្ន៎ ។

«ម៉ាក់សាកទេ»

«បើកូនញ៉ាំ ម៉ាក់ញ៉ាំដែរ ។»

ម៉ាក់អ្នកតបទាំងញញឹម ។ លោកមិនចូលចិត្តអាពីងទេ ហើយលោកកាន់តែមិនចូលចិត្តម្ហូបតាមផ្លូវណាស់ទៅទៀត ព្រោះពោះលោកមិនពូកែទេ ។ លោកនិយាយយ៉ាងនេះ ព្រោះលោកជឿថា នរិន និងមិនហ៊ានញ៉ាំទេ ។ ណាប់ដើរមកដល់ល្មម ។

«ពូ ចង់អាពីងទេ?»

នរិនសួរសួហ្វ័រអ្នក ។

«មិនណាស់ណាទេ កូយ ។»

ណាប់ឆ្លើយហើយចូលទៅអង្គុយកាន់ចង្កូតដូចសព្វដង ។ នរិនងាកទៅអ្នកលក់ហើយប្រាប់នាងថា៖

«អោយខ្ញុំមួយកំប៉ុងមក ។»

ម្តាយនឹងកូនរូវសរាន់ច្រកអោយអ្នក ។ អ្នកហុចលុយប្រាំដុល្លាអោយអ្នកលក់ហើយប្រាប់ថា៖

«មិនបាច់អាប់ទេ មីង ។ មិនងាយមានអ្នកណាលក់អាពីងដាច់អោយមកខ្ញុំទេ ។ ចាត់ទុកថាមីងបានទទួលរង្វាន់តូចមួយពីការលក់ដូរដ៏ចំណាប់របស់មីងនឹងកូនមីងចុះ ។»

ពីរម្នាក់ម្ដាយកូនហាក់មិនអស់ចិត្ត ឬមិនទុកចិត្ត យកលុយមកញី ហើយលើកឡើងបញ្ចាំងមើល លុះឃើញថាដូចជាសុទ្ធល្អហើយ ក៏ពោលទាំងញញឹមថា៖

«អរគុណលោកក្មួយណាស់ ។ សូមអោយលោកក្មួយនឹងគ្រួសារបានរិតតែចំរើនថែមទៀត ។»

តពីនោះគេចេញដំណើរមកទៀត ។ ក្នុងរថអ្នកកាច់ជើងអាពីងមួយមកមើល ហើយខាំវាញេញញេ នៅធ្មេញមុខទាំងពីរ ។ រសជាតិនៅដូចមុនដដែល ស្កាត់ៗប្រៃៗ មិនជាចំណូលចិត្តរបស់អ្នកទេ ។ លោកជំទាវញញឹមខ្ចឹបឃើញអកប្បកិរិយារបស់នាយ ។

«កាលម៉ាក់អោយកូនញាំវាដំបូង ក៏កូនធ្វើអិញ្ចឹងដែរ ។ ម៉េចដែរឆ្ងាញ់ជាងមុនទេ?»

«អត់ទេម៉ាក់ ។ ណោះ ម៉ាក់ពិសាមួយទៅ ។»

អ្នកហុចអាពីងអោយម្ដាយទាំងញញឹម ។

«ម៉ាក់យកទាំងអស់ហើយណា៎!»

«ខ្ញុំអរវិញទេ ។»

លោកយកទាំងថង់ហើយ ហុចទៅណាប់ ។

«ណាប់ ជួយញាំអោយខ្ញុំផង ។»

ណាប់ញឹមៗ ហើយទទួលយក ។ អ្នកបើកថង់ល្ងកមួយដាក់មាត់ផ្លុប ទំពារឃ្មមៗយ៉ាងឆ្ងាញ់ពិសារ ។ ភ្នែកអ្នកមើលផ្លូវត្រង់ទៅមុខដោយប្រុងប្រយ័ត្ន ។ ពីរនាក់ម៉ែកូនក្រញែងខ្លួន ។

មកដល់កំពង់ធំ គេទៅឈប់ញាំបាយនៅភោជនីយដ្ឋាន «រន្ធ អាម៉ុក» ដែលល្បីជាងគេនៅទីរួមខេត្តនេះ ។ ហាងបាយមួយនេះនៅកៀកនឹងរូបចម្លាក់ដំរីជាន់ខ្លាដែលជានិមិត្តរូបរបស់ខេត្តនេះ ។ គេហៅម្ហូបល្បីប្រចាំហាង គឺអាម៉ុកត្រីរស់ចំហុយត្រយ ញ ក្នុងកន្ទោងដែលធ្វើពីស្លឹក ញ ដែរ ។ ទីនេះល្បីណាស់ ហើយអ្នកណាក៏និយមចូលចិត្តអាម៉ុកទីនេះដែរ ។ គេហៅម្ហូបពីរបីមុខទៀត ហើយជជែកគ្នាលេងរង់ចាំអាហាររបស់គេ ។ មួយសន្ទុះ អ្នករត់តុលើកម្ហូបមកត្រៀបត្រា ។ អាម៉ុកជះក្លិនឈ្ងុយគួរឆ្ងាញ់ ។ មិនរេរ៉ែ គេនាំគ្នាបរិភោគជុំគ្នាទាំងបីនាក់ដោយស្ងាត់ស្ងៀម ។

បាយហើយគេចេញដំណើរទៅទៀត ដោយឈប់តែបន្តិចទេ នៅកន្លែងសំរាកអ្នកដំណើរព្រៃប្រោះ ឯស្រុកកំពង់ស្វាយ ។

នរិនថតរូបទេសភាពមួយចំនួនតាមទម្លាប់អ្នក ។ ស្ទឹងព្រៃប្រោះមិនមានទឹកច្រើនទេក្នុងខែមករា ។ ទឹកហូរសឹងមើលមិនដឹង ។

ទេសភាពគួរជាទីមនោរម្យណាស់ តែអនិច្ចាត្រង់សំរាម ដបទឹកសុទ្ធ ថង់ប្លាស្ទិក ក៏ដូចជាប្រអប់ស្នោដាក់អាហារដែលសុទ្ធតែជាសំរាមពិបាករលាយតាមធម្មជាតិ បើមិនចាត់ចែងខ្ចប់វេច នឹងយកមកឆ្នៃប្រើវិញអោយត្រឹមត្រូវទេ ។

មកស្រុករាល់លើកនរិនទើសចិត្តតែរឿងសម្រាមនេះមួយទេ ។ អ្នកស្ដាយដែលខ្មែរភាគច្រើនមិនយល់ពីផលប៉ះពាល់បរិស្ថានដ៏ធ្ងន់ធ្ងរបស់ប្លាស្ទិក នឹងសំរាមដទៃទៀត ។ ខ្លះមានទម្លាប់ចោលតែពាសអោយតែរួចពីដៃ មិនថាតាមផ្លូវ តាមហាងតូចធំ ឬទីណាទេ ។ ថាអ្នកមិនមានការអប់រំចុះគ្នាមិនដឹង អ្នកមានការអប់រំ នឹងទ្រព្យធូធារខ្លះក៏ធ្វើដូចគ្នា ។

អ្នកឆ្ងល់ថាអ្នកទាំងនោះចោលសម្រាមដូចគ្នាអិញ្ចឹងដែរទេ នៅផ្ទះរបស់គេ ។ បើមិនទេ មានហេតុផលអ្វីដែលគេគិតថា ស្រុកខ្មែរទាំងមូលមិនមែនជាផ្ទះរបស់គេ? ។ គិតដល់ត្រឹមហ្នឹងនរិនដកដង្ហើមធំឃ្ងរ ។ អ្នកអស់អារម្មណ៍នឹងថតរូបតទៅទៀត ក៏ដើរមករកឡានវិញហើយរៀបចំបន្តដំណើរទៅទៀត ។

គេបង្ខំដំណើរបន្តិច ព្រោះលោកជំទាវមានប្រជុំម៉ោងបីរសៀល ។

ទាំងអស់គ្នាមកដល់សៀមរាប ម៉ោងប្រហែលមួយរសៀល ។ គេទៅ ឆិកអ៊ីន នៅប្រែនហូថែល តាមការកក់ទុកជាមុន ។

នរិននៅបន្ទប់មួយ ម្តាយអ្នកនៅបន្ទប់មួយផ្សេងទៀត ។ ណាប់ សុំខ្លួនទៅផ្ទះស្នាក់នៅផ្ទះសំណាក់មួយក្បែរហាងសាំងកាល់តិចមិនឆ្ងាយពីប្រែនហូថែលប៉ុន្មានទេ គឺចុះតែពីផ្លូវជាតិលេខ ៦ មិនដល់ហាសិបម៉ែត្រផង ។

បន្ទាប់ពីជួយជញ្ជូនកវ៉ាន់រួចរាល់ហើយ គ្រាដែលម្តាយអ្នកកំពុងងូតទឹករៀបចំខ្លួនទៅប្រជុំ នរិនបង្គាប់អោយណាប់ទៅសំរាកចុះ ទុកអោយគេជាអ្នកបើករថយន្តជូនម្តាយវិញថ្ងៃហ្នឹងព្រោះគាត់បើកម៉ូយថ្ងៃហើយ ។ អ្នកអោយ ណាប់ ៥០ ដុល្លា ដើម្បីគ្រាន់ចាយវាយ ហើយសុំខ្លួនជូនណាប់ទៅដាក់នៅផ្ទះសំណាក់ តែណាប់ថាគាត់ជិះម៉ូតូឌុបទៅបានហើយ ។

«ពូកុំដាក់ទូរស័ព្ទឆ្ងាយដៃ ឬបណ្តោយអស់អស់ថ្មណា ក្រែងម៉ាក់មានការបន្ទាន់ត្រូវហៅពូ ។»

មាណពផ្តាំពេលគាត់ដើរចេញពីប្រែនហូថែលទៅ ។ ណាប់ឆ្លើយទទួលហើយបន្តដំណើរទៀតបាត់ទៅ ។

នរិនមកងូតទឹកប្តូរខោអាវហើយ អ្នកក៏មើលទូរទស្សន៍ចាំម្តាយហៅប្រើ ។ ដល់ម៉ោងពីរកន្លះអ្នកជូនម្តាយទៅ សុខារីសត ជួបប្រជុំជាមួយដៃគូជំនួញរបស់លោក ។ លោកដេញអ្នកអោយបើកឡានទៅមើលអង្គរលេងៗទៅ ចាំម៉ោងប្រាំពីរល្ងាចចាំមកទទួលលោកទៅទទួលទានអាហារជុំគ្នា ។

នរិនស្តាប់លោកហើយបើករថយន្តចេញទៅ ។

អ្នកតំរង់ទៅលេងអង្គរ ។ បើកជិតមកដល់មន្ទីរពេទ្យគន្ធបុប្ផា អ្នកចោលភ្នែកទៅ បានយល់ព្រះកែសព្រះមហារាជព្រះបាទជ័យវរ្ម័នទី ៧ ដែលឋិតលើទីតាំងខ្ពស់ក្នុងបរិវេណពេទ្យកុមារនេះហើយ អ្នកក៏នឹកដល់បំណងអ្នកដែលចង់ជួយកុមារក្រីក្រតាមរយៈមន្ទីរពេទ្យនេះ ។ អ្នកតែងមានចិត្តកតញ្ញូចំពោះ វេជ្ជបណ្ឌិត ប៊ីត រីចន័រ ណាស់ដែលខំលះបង់យ៉ាងច្រើនអនេកដើម្បីជួយកុមារខ្មែរ ដែលពិបាកនឹងរកទីពឹងវេជ្ជសាស្រ្តដែលត្រឹមត្រូវហើយមានតម្លៃសមរម្យតាមជីវភាពរបស់មាតាបិតា នឹងគ្រួសារគេ ។

អ្នកចតរថយន្តហើយដើរចូលទៅក្នុងពេទ្យ ។ អ្នកប្រាប់អ្នកយាមថាអ្នកចង់មកបរិច្ចាកថវិកាខ្លះ នឹងបរិច្ចាកឈាមដែរដើម្បីជួយមន្ទីរពេទ្យ ។ អ្នកយាមបង្ហាញផ្លូវហើយ អ្នកដើរតម្រង់តាមទិសចង្អុលទៅ ។

លះរួចរាល់ហើយ អ្នកចេញមកហើយបើករថយន្តបន្តទៀតទៅលេងអង្គរតូច ។ ម៉ោងទើបតែបួនរសៀលទេ ។

មកដល់បរិវេណអង្គរ ហួសកន្លែងឆែកសំបុត្របន្តិច អ្នកបើករថយន្តកាត់វុក្ខវិថីដែលមានដើមគគីធំៗឈរអមសងខាងផ្លូវ បក់ស្លឹករវិចហាក់ស្វាគមន៍អ្នក ។ សំឡេងរៃយំអឺងកងហាក់ជាតន្រ្តីប្រគំកំដរអ្នកដំណើរដែលមកដល់បូរាណដ្ឋានដែលជាដួងព្រលឹងមហាច័ក្រមួយកាលពីប៉ុន្មានសតវត្សកន្លងទៅ ។

មកដល់ទីនេះដែរ អ្នកក៏នឹកដល់ដំណើរមកក្រុងអង្គររបស់វិធាវីក្នុងរឿងផ្កាស្រពោនរបស់អ្នកនិពន្ធនូហាច ។ នាងកំពុងមានទុក្ខធ្ងន់ណាស់ពេលនោះ ព្រោះម្តាយនាំងបានបំបែកនាងពីគូនាងដែលចិត្តនាងស្ម័គ្រមេត្រី ។ អ្នកនឹកឃើញកាលអ្នក អានរឿងនេះ អ្នកខឹងនឹងយាយនួនម្តាយនាងណាស់ដែលតាមចិត្តមហិច្ឆតាលោកមិនអាណិតចិត្តបុត្រីខ្ទើនទន់ភ្លន់ នឹងតាមបង្គាប់ ទោះបន្តិចណាសោះ ។ ពេលនេះអ្នកក៏មកដល់ទឹកដីដ៏សក្តិសិទ្ធិទាំងទ្រងដក់ជាប់វិបត្តិស្រដៀងគ្នានេះដែរ បើខុសគ្នាគឺត្រង់តែរបួសចិត្តអ្នកជារបួសចាស់ ដែលរកខិកាសនឹងជាសះម៉ិនបានទេ ។

ពេលវេលាកន្លងទៅជិតមួយសតវត្សហើយតាំងពីជំនាន់ផ្កាស្រពោន ហើយមិនដឹងប៉ុន្មានសតវត្សទេតាំងពីជំនាន់ទុំទាវ តែរឿងស្នេហ៍យុវវ័យទទួលគ្រោះព្រោះមាតា នឹងគ្រួសារជ្រៀតជ្រែកនៅតែមិនជឿនលឿនទៅណាសោះក្នុងសង្គមខ្មែរ ។

អ្នកគិតទៅស្ថានភាពអ្នកល្អជាងវិធាវីបន្តិចត្រង់អ្នកមិនបណ្តោយអោយរបួសបេះដូងរបស់អ្នកញាំញីអ្នកដល់ថ្នាក់ធ្លាក់ខ្លួនរីងរៃដោយសារវាឡើយ ។ តែអាការះពិតរបស់អ្នកបើនិយាយអោយត្រង់ទៅមិនជាល្អជាងវិធាវីកាលនៅរស់ណាស៊ំណាទេ ។ ពេលណាអ្នកនៅតែឯង អ្នកត្រូវវិប្បដិសារីយ៍អ្នក មកលងបន្លាចអ្នក ហើយអារម្មណ៍ពិរុទ្ធដែលអ្នកគេចវេសទំនួលខុសត្រូវរបស់អ្នកតែងចាក់ដោតដំបៅចិត្តអ្នកអោយពីតផ្សារជាថ្មីមិនខានម្តងណាឡើយដូចពេលនេះ

ជាដើម ។ អ្នកនឹកដល់ចំរៀងមួយបទទៀតរបស់ LeAnn Rimes គឺបទ Insensitive ។ ហើយបទ Where Do Broken Hearts Go? របស់ Whitney Houston ក៏កាន់តែត្រូវនឹងបរិយាកាសណាស់ទៅទៀត ។

LEANN RIMES

"Insensitive"

[Originally wrote and performed by Jann Arden]

How do you cool your lips
After a summer's kiss
How do you rid the sweat
After the body bliss
How do you turn your eyes
From the romantic glare
How do you block the sound of a voice
You'd know anywhere

[Chorus]
Oh I really should have known
By the time you drove me home
By the vagueness in your eyes
Your casual good-byes
By the chill in your embrace
The expression on your face
That told me you might have some advice to give
On how to be insensitive

How do you numb your skin
After the warmest touch
How do you slow your blood
After the body rush
How do you free your soul
After you've found a friend
How do you teach your heart it's time
To fall in love again

Oh you probably won't remember me
It's probably ancient history
I'm one of the chosen few
Who went ahead and fell for you
I'm out of vogue, I'm out of touch
I fell too fast, I feel too much
I thought that you might have some advice to give
On how to be insensitive

[Chorus]

WHITNEY HOUSTON

"Where Do Broken Hearts Go"

I know it's been some time
But there's something on my mind
You see, I haven't been the same
Since that cold November day...
We said we needed space
But all we found was an empty place
And the only thing I learned
Is that I need you desperately...

So here I am
And can you please tell me... oh

[Chorus:]
Where do broken hearts go
Can they find their way home
Back to the open arms
Of a love that's waiting there
And if somebody loves you
Won't they always love you
I look in your eyes
And I know that you still care, for me

I've been around enough to know
That dreams don't turn to gold
And that there is no easy way
No you just can't run away...
And what we have is so much more
Than we ever had before
And no matter how I try
You're always on my mind

[Chorus]

And now that I am here with you
I'll never let you go
I look into your eyes
And now I know, now I know...

[Chorus]

មកដល់មុខអង្គរតូច អ្នកគ្រាន់តែក្រឡេកមើលកេតនភ័ណ្ឌជាតិដ៏ប្រណិតពីចម្ងាយ យល់កំពូលប្រាសាទទាំងប្រាំខ្ពស់ត្រដែត អួតខ្លួនយ៉ាងមានមោទនភាព នឹងសម្រស់ឆើតឆាយ ។ អ្នកញញឹមពេញចិត្តនឹងសម្រស់ដ៏ត្រកាលនេះ ហើយស្ងើចសរសើរសំណាងខ្លួនបានកើតមកជាខេមរៈបុត្រ ក្នុងពូជពង្សមហាច័ក្រប្រចាំតំបន់ ។ អ្នកសង្ឃឹមថាកម្ពុជានឹងយល់យុគ្គសម័យដ៏រុងរឿងជាថ្មីទៀតមិនខានឡើយ ។

ហើយអ្នកបើករថយន្តបន្តហួសទៅអង្គរធំ ទៅតាមផ្លូវលំតូចល្មមមួយសំរាប់តែរថពីរចៀសគ្នាទៅមកដោយមិនលំបាក ។ ដើមឈើរធំៗខ្ពស់ៗ ហើយត្រង់ស្លូទៅលើ ឈរច្រូងច្រាងចោលម្លប់ត្រឈឹងត្រឈៃ ចាំស្វាគមន៍អ្នកជាហូរហែរ ។

នរិនចុចកញ្ចក់បង្អួចចុះទុកអោយអាកាសបរិសុទ្ធផាត់បន្លែងលែងនិងមុខអ្នក ។ អ្នកស្រូបវាបំពេញសួត ហើយអារម្មណ៍ហាក់ស្រស់ស្រាយបន្តិច ។

សំឡេងវៃយំរងំឆ្លើយឆ្លងស្តាប់ទៅហាក់ជាតូរ្យតន្ត្រីស្ទូគាំហានលោមបំពេរចិត្តអ្នកអោយបានស្បើយទុក្ខទៅមួយគ្រាមួយខណៈដែរ ។

មកដល់ទីលានជល់ដំរីអ្នកចតរថយន្តហើយដើរលេងៗមើលចំលាក់នៅទីនោះដែលអ្នកចូលចិត្តលើសទីណាៗទាំងអស់ ។ ចំលាក់ដំរីថ្មមានភាពរស់រវើក ។ ទីនេះហើយដែលមហារាជព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់តែងគង់ទតពិធីបុណ្យជាតិនានា ជាពិសេសទំពព្រះអង្គវិលពីចំបាំងវិញដោយនាំយកជ័យជំនះមកថ្វាយទ្រង់ នឹងជាតិ ។ អ្នកមានអារម្មណ៍រសាត់អណ្តែតទៅរកអតីតកាលដែលធ្វើអោយអ្នកស្រាលខ្លួនស្ទើកដើរសឹងមិនជាប់ដី ។

អ្នកដើរហួសប្រសាទភិមានអាកាសដែលសាងសង់ឡើងក្នុងអំឡុងចុងសតវត្សទី ១០ មានរាងស្រដៀងទៅនឹងពីរ៉ាមីត ។

តពីនោះ អ្នកដើរលេងៗតមកទៀតតម្រង់មកទស្សនាប្រាសាទ បាយ័ន ។ នរិនពេញចិត្តនឹងប្រសាទដ៏ចំណាស់នេះជាពិសេស ដោយសារចំលាក់ដែលរៀបរាប់ពីគ្រប់សកម្មភាពនឹងជីវភាពរបស់មនុស្សខ្មែរពីអតីតកាល ។ មកកៀកនឹងប្រាង្គប្រាសាទអ្នកយល់ព្រះចតុរ័ភក្រលើកំពូលប្រាង្គទាំងឡាយញញឹមទាំងមានព្រះនេត្របិទជិត ។ ហើយអ្នកក៏ឆ្ងល់ពីសេចក្តីដែលនាំអោយព្រះអង្គទ្រង់ញញឹមដូចនេះ ។

ប្រហែលព្រះអង្គទ្រង់យល់អ្វីម៉្យាងដែលអ្នកផងមើលរំលងហើយ ។ ឬប្រហែលព្រះអង្គទ្រង់យល់ពីជំរៅចិត្តអ្នកហើយកំពុងតែលួងថាមិនថ្វីទេ ពេលវេលាគង់ដោះស្រាយវិបត្តិគ្រប់យ៉ាងបាន ។

នរិនដកដង្ហើមធំ ។ ១៣ ឆ្នាំហើយ ពេលវេលាហាក់មិនបានជួយធ្វើអ្វីអោយធូរស្រាលសូម្បីបន្តិចក៏ទេដែរ ។ មកដល់ផ្លូវចូលទៅបរិវេណប្រាសាទបាយ័ន នរិនឈរគន់សម្រស់សិលាដ្ឋានដ៏ប្រណិតនេះដោយចិត្តស្ញប់ស្ញែងយ៉ាងក្រៃលែង ។ កំពូលប្រាង្គរាប់សិបឈរច្រូងច្រាងក្រោមមេឃពណ៌ខៀវដែលមានពពកដោយអន្លើរ ។ នរិនភ្លឹកមួយសន្ទុះ ។

អ្នកចង់ចូលទៅលេងប្រាសាទដ៏ប្រណិតនេះ ។ តែពេលអ្នកហៀបនឹងដើរចូលទៅក្នុងបរិវេណប្រាសាទទៅហើយ អ្នកនឹកដល់ព្រះអង្គធំដែលរិធារីមកបួងសួងសុំអោយព្រះអង្គអោយជួយ ។ អ្នកដើរទៅបំណងថ្វាយបង្គំព្រះអង្គធំវិញ ។

ពេលអ្នកទៅដល់ អ្នកយល់គូស្នេហ៍ក្មេងៗមួយគូកំពុងតែបត់ជើងថ្វាយបង្គំព្រះអង្គ ។ ពួកគេវ័យមិនលើស ២០ ឆ្នាំទេ ។ យុវជននោះមាឌល្អិតដែរទេ គេស្លៀកខោខូវបយជើងកំប៉ុងពណ៌ខ្មៅ ហើយពាក់អាវសដៃខ្លី ។ គូស្នេហ៍របស់យុវជននេះស្លៀកខោដែរត្រឹមជង្គង់ ពាក់អាវយឺតរឹបណែនរាង ពណ៌ខ្មៅ ។ ធូបឆេះហុយៗនៅក្នុងដៃរបស់គេទាំងពីរដែលកំពុងលើកប្រណម្យស្ទើរចិញ្ចើម ។ ភ្នែកគេបិទជិត មាត់អធិដ្ឋាន ។

នរិនឈរនៅជិតនោះបែរមុខទៅទិសផ្សេងមើលទៅទេសចរជាតិនិងអន្តរជាតិដែលខ្លះកំពុងដើរមើលចម្លាក់ខ្លះទៀតថតរូបជាអនុស្សាវរិយ៍ ។ ខ្លះកំពុងរៀបរបៀបឈរអោយអ្នកថតលៃយ៉ាងម៉េចឃើញច្រមុះរបស់គេទល់នឹងច្រមុះចំលាក់ដែរ ។ ជួនតិចជួនខ្លាំងនរិនឮគូស្នេហ៍ក្មេងៗទាំងពីរពឹងព្រះអង្គធំតាមសំនៀងបែបអ្នកក្រុងសៀមរាបថាៈ

«ខ្ញុំម្ចាស់សូមសច្ចាចំពោះព្រះអង្គថាខ្ញុំម្ចាស់ស្មោះត្រង់ជាមួយគូខ្ញុំម្ចាស់ដែលនៅចំពោះព្រះភ័ក្ត្រព្រះអង្គនេះជាដរាប់មិនមានចេតនាគេចកែរទេ ។ សូមព្រះអង្គផ្តល់ពរជ័យ នឹងធ្វើជាសាក្សីចំពោះមេត្រីភាពរវាងយើងខ្ញុំទាំងពីរផង ។»

បុរសក្មេងនោះពោលទាំងងាកទៅញញឹមដាក់មិត្តរបស់គេ ។

«ដូចគ្នាដែរ ខ្ញុំម្ចាស់សូមអោយពួកយើងបានជួបប្រសប់រួមរស់ជាមួយគ្នាជាអង្វែងតទៅ» ។

នារីសច្ចារិញម្តង រួចហើយគេដោតធូបហើយថ្វាយបង្គំបីដង មុនបណ្តើរគ្នាត្រសងឡើងម៉ូតូ ហុងដាឌ្រីម ១២៥ សេសេមួយគ្រឿងពណ៌ខ្មៅដែលចតក្បែរនោះ ។

ពេលគេទៅផុត នរិនចូលម្តង ។ អ្នកទទួលធូបដែលដុតហើយជាស្រេចពីដូនជីម្នាក់ចាស់ណាស់ទៅហើយ ស្បែកលោកជ្រីវជ្រួញអស់ហើយ ។ អ្នកមកបត់ជើងមុខព្រះអង្គធំហើយពោលរងំៗលួមឮតែឯងថា៖

«សូម៉បារមីព្រះអង្គ តាមរក្សាគូស្នេហ៍ នឹងស្នេហារបស់គេទាំងពីរនាក់អំបាញមិញអោយបានសំរេចដល់ត្រើយដូចបំណងគេផង ។ សូមព្រះអង្គប្រទានពរដល់មាតាខ្ញុំម្ចាស់អោយមានសុខភាពល្អ នឹងមានជោគជ័យក្នុងរបររកស៊ីរបស់លោកផង ។ សូមបារមីទ្រង់តាមការពារអឌិតគូកំណាន់ចិត្តរបស់ខ្ញុំម្ចាស់នឹងគ្រួសារនាងអោយបានសុខចំរើនដូចគ្នា ។»

នរិនពោលទាំងទឹកភ្នែកដាមពេញរង្វង់ភ្នែកទាំងគូ ។ ទ្រូងនឹងច្រមុះអ្នកតឹងណែនហើយ ហើយអ្នកស៊ីតតខ្យល់កុំអោយទឹកសំបោរហូរមក ។

អ្នកអួលដើមកពេកណាស់ ។ អ្នកព្រិចភ្នែកបន្តិចទឹកភ្នែកក៏ស្រាប់តែហូរមកកាត់ថ្ពាល់អ្នក ។ អ្នកអោនមុខទាបទៅបង្ការក្រែងមានគេឃើញទឹកភ្នែករបស់អ្នក ។

«ហើយសូមព្រះអង្គបន្តប្រទានពរអោយកម្ពុជាបានយល់តែសន្តិភាពអង្វែងទៅទៀតកុំបីអាក់ខានឡើយ ។» ហើយអ្នកដោតធូបទាំងប្រាំសរសៃនោះហើយ ក្រាបថ្វាយបង្គំបីដងមុនងើបឡើង ។ អ្នកយកម្រាមដៃផាត់ទឹកភ្នែកពីមុខអ្នកយ៉ាងលឿនហើយដកកាបូបយកលុយ ៥ ដុល្លាជូនដូនជីដែលបំរើព្រះអង្គធំនឹងភ្ញៀវដែលចូលមកថ្វាយបង្គំព្រះនាទីនោះ ។ ដូនជីចំណាស់ទទួលយកហើយជូនពរយ៉ាងក្បោះក្បាយ ។

«អោយជីដូនមើលបាតដៃលោកចៅបន្តិចបានទេ?»

មាណពលាដៃអ្នកអោយដូនចំណាស់មើល ។ ដូនជីរូបនោះទាញមកមើលជិតភ្នែករបស់គាត់បន្តិចហើយពិនិត្យមើលដោយផ្ចិតផ្ចង់ ។ បន្តិចមកដូនចាស់ងើបមុខឡើង ភ្នែកល្អក់ទាំងគូរបស់គាត់ មើលមុខនាយចំ ។

«សង្ឃឹមថាព្រះអង្គនឹងបើកចិត្តដែលចៅបិទនោះ អោយទទួលគូគ្រងថ្មីដែលនៅបង្កើយនឹងចៅ ដើម្បីអោយចិត្តរបួសក្នុយបានជាសះវិញផង ។»

នរិនទាញដៃអ្នកមកវិញទាំងភ្ញាក់ព្រើត ។

អ្នកញញឹមបន្លប់មិនស្តីហើយជំរាបលាដូននោះដើរចេញទៅ ។ អ្នកដើរទៅអង្គុយលើថ្មមួយដុំ ហើយទាញយកទូរស័ព្ទ របស់អ្នកមកមើល ។

អ្នកឆែកហ្វេសប៊ុករបស់អ្នកមើល លុះអស់ចិត្តហើយ ក៏គិតចង់សរសេរអ៊ីម៉ែលមួយអោយទៅឆដា ។ តែសរសេរម៉េលតាមទូរស័ព្ទមិនស្រួលទេ ណាមួយអ្នកមានពាក្យច្រើនដែលមិនដឹងថានឹងត្រូវរ៉ាយរ៉ាយប់យ៉ាងណាផង ។

សំរេចសំរួចអ្នកក៏ដាក់ទូរស័ព្ទចុះវិញ ហើយដើរបករទៅរករថយន្តអ្នកវិញ ។

អ្នកបើករថលេងៗតាមវង់តូចកាត់ប្រាសាទធំដូចជា ព្រះខ័ន នាគព័ន្ធ តាសោម មេបុណ្យខាងកើត ប្រែរូប ស្រះស្រង់ បន្ទាយក្តី នឹងក្រវ៉ាន់ មុនវិលវង់មកដល់ផ្លូវទៅអង្គរតូចវិញ ទើបអ្នកបត់ឆ្វេង បកទៅសៀមរាបតែម្តងទៅ ។

***

# ឆដា

ថ្ងៃនេះឆដាដើរមើលហាងរបស់នាងដូចធម្មតា ។ ពេលព្រឹកបន្ទាប់ពីទំលាក់កូនៗរបស់នាងឯសាលា ហូមអប្ហ៍អ៊ីងគ្លីស ឯបឹងកេងកងមកនាងមកហាងរបស់នាងដែលនៅជិតនោះដូចធម្មតា ។

ម៉ោងពីរទើបនាងត្រូវទៅមើលហាងមួយទៀតឯទួលគោកដូចរាល់ថ្ងៃដែរ ។ មកដល់ហាងឯបឹងកេងកងភ្លាម នាងចោលភ្នែកទៅតុដែលនាំងជួបនរិនកាលពីម្សិលមិញ ។ នាងរាងអន់ចិត្តបន្តិចដែរដែលមិនឃើញវត្តមានអ្នកដែលនាងគិតថានឹងមកចាំ ។

«ដាច់ទេ ណារ៉ា ព្រឹកនេះ ។»

នាងសួរទៅបុគ្គលិករបស់នាង ។

«មួយប្រាវទេបង ។»

ណារ៉ាតប ។

«ឯណា មុំ?»

នារីសួរព្រោះមិនឃើញបុគ្គលិកម្នាក់ទៀត ។

«ខ្ញុំនៅនេះបង ។»

មុំឆ្លើយ ។ នាងទើបចេញមកពីសំអាតបន្ទប់ទឹក ។

«បងមិនឃើញស្មានថាអូនកើតអីតើ ។»

«ខ្ញុំមិនអីទេ បង ។»

«មុំជួយយកតែក្តៅមួយដូចសព្វដង នឹង ក្រស៍សង់ មួយជាមួយប៊័រមួយប្រអប់ទៅអោយបងនៅលើផង ។»

ថាហើយនាងឡើងជណ្តើរឡើងទៅការិយាល័យនាងខាងលើបាត់ទៅ ។

នារីបើក អាយម៉ាក់ ២៧ អ៊ីញរបស់នាងហើយដាក់កាបូបចុះលើតុការិយាល័យដ៏ធំទូលាយរបស់នាង ។ នាងអង្គុយចុះហើយចុចលើ ម៉េល ដើម្បីអោយដឹងថានរិនមានផ្ញើម៉េលអ្វីមកឬទេ ។

មានអ៊ីនបក់ស៍ ១៤ តែមិនមានមួយណាជារបស់នរិនទេ ។ នាងដកដង្ហើមធំឃ្លូ ហើយផ្អែកខ្នងទៅនឹងកៅអី ។ ភ្នែកនាងមើលពិដាន ។ នរិនពិបាកយល់ណាស់ ។ ពេលជួបនាង អ្នកហាក់អរយ៉ាំងជាក់ស្តែង តែពេលបែកវិញគឺដូចគ្មានអ្វីកើតឡើងអិញ្ចឹង ។

កំពុងភ្លឹក មុំគោះទ្វារ យកតែ នឹងនំមកអោយ ។ ឆដាពោលអរគុណបុគ្គលិកនាង ហើយមុំចេញទៅវិញដោយស្ងាត់ស្ងៀម ។ ក្រេបតែនាងបណ្តើរ នាងឆ្លើយ អ៊ីម៉ែលរបស់នាងបណ្តើរ ហើយបន្តធ្វើការនាងដូចសព្វដង ។ ភ្លេចៗខ្លួន ម៉ោងជិត ១២ ទូរស័ព្ទលើតុរបស់នាងរោទ៍ឡើង ។

«ហែលឡូ? កាហ្វេឌីឡៃត៍បឹងកេងកង នាងខ្ញុំឆដានិយាយ ។»

នាងរាក់ទាក់ទៅកាន់ម្ខាងខ្សែ ។

«ឆដា, បងណា៎ ។»

ម្ខាងទៀតនិយាយ ។

«អូ បង ។ មានការអីដែរបង ។»

«បងធ្វើការតែមួយព្រឹកទេ ។ ថ្ងៃនេះបងចង់ទៅញ៉ាំបាយជុំអូន ។ នៅ ហាងខ្មែរសុរិនជិតកន្លែងអូនហ្នឹង ល្អទេអូន?»

«ល្អតើបង ។»

ឆដាតប ។ នាងមើលម៉ោងលើជញ្ជាំងបន្ទប់របស់នាង ។

«ម៉ោងដប់ពីរយ៉ាងម៉េចដែរ បង?»

«ម៉ោង ១២ ជួបគ្នា» ។

នារីរៀបចំកវ៉ាន់លើតុនាងអោយមានសណ្តាប់ធ្នាប់ហើយទាញកាបូបមកស្ពាយលើស្មាហើយចាក់សោរបន្ទប់ចេញទៅ ។

ពេលនាងមកដល់ រកកន្លែងចតឡានបានហើយនាងដើរចូលក្នុងហាង ហើយឡើងជណ្តើរទៅជាន់ខាងលើទៅរកតុដែលនាងនឹងស្វាមីតែងមកជាប្រចាំ ។ ពេលទៅដល់នាងយល់ស្វាមីនាងកំពុងចាំរួចជាស្រេច ។

«បងហៅរួចហើយ ។ ម្ហូបដែលអូនចូលចិត្តពីរមុខ នឹងម្ហូបដែលបងចូលចិត្តមួយមុខ ។»

អាន់ដ្រេ និយាយពេលអ្នកឃើញភរិយានាយអង្គុយរួចស្រេចបួលហើយ ។

ភាសាខ្មែររបស់នាយច្បាស់ដូចខ្មែរម្ចាស់ស្រុកសឹងបេះបិទ ។ បើគេស្តាប់នាយនិយាយដោយមិនមើលមុខម្ចាស់សំនៀង គ្មាននរណាដឹងថានាយជាជនជាតិរុស្ស៊ីទេ ។ អាចដែរព្រោះមាតាបិតានាយមករស់នៅស្រុកខ្មែរតាំងពីពាក់កណ្តាលទសវត្ស ៨០ ពេលនាយអាយុទើបបាន ៩ ឆ្នាំប៉ុណ្ណោះ ។

មាតាបិតាលោកស្រឡាញ់ស្រុកខ្មែរណាស់ ចឹងហើយទើបចប់ភារៈកិច្ចទូត ចំពេលដែលអាយុលោកត្រូវចូលនិវត្តន៍ផង លោកក៏ជួលផ្ទះឯម្ចាស់ហើយនាំគ្នាមកទិញផ្ទះនៅទួលគោក រស់នៅតាំងពីពេលនោះមក ។ អាន់ដ្រេរៀនសាលាខ្មែរ ហើយមានមិត្តភក្តិភាគច្រើនសុទ្ធតែខ្មែរ ព្រោះមិនមានជនជាតិរុស្ស៊ីច្រើនទេ រស់នៅស្រុកខ្មែរទេ ។ ពេលអ្នករៀនចប់ខាងស្ថាបត្យកម្មនៅស្រុកខ្មែរ អ្នកទៅរៀនតយកជំនាញនេះកម្រិតអនុបណ្ឌិតនៅសាំងព្រ៉ាក្កបន្តទៀត ។ ចប់ហើយអ្នកមកស្រុកខ្មែរវិញហើយមាតាបិតាអ្នកជួយអ្នកអោយបើកក្រុមហ៊ុនស្ថាបត្យកម្មមួយជាមួយមិត្តចាស់របស់លោកម្នាក់ដែលជាជនជាតិខ្មែរ ព្រោះលោកគិតថាពេលស្រុកខ្មែរអភិវឌ្ឍន៍ទៅ ខាងផ្នែកនេះនឹងមានទីផ្សារធំណាស់ ។

«សុំទោសលោក លោកស្រី ។ លោកស្រីចង់ពិសារភេសជ្ជៈអីដែរ?»

អ្នករត់តុចូលមកសួរនាំ ។

«ខ្ញុំសុំទឹកសុទ្ធមួយដបមក ។»

ឆដាងើបមុខនិយាយ ។

«ដបតូចឬធំដែរ បាទ ។»

«ដបធំ ។ អរគុណ ។»

ហើយអ្នករត់តុថយចេញទៅ

«ម៉េចបងធ្វើការតែមួយព្រឹកអញ្ចឹង?»

ឆដាសួរស្វាមីនាង ។ ទឹកមុខគេហាក់រីករាយយ៉ាងចំលែក ។

«ក្រុមហ៊ុនទើបដេញថ្លៃបានសាងសង់ ខនដូ ៦០ ជាន់មួយទៀតនៅក្បែរទួតអូស្ត្រាលី ។ ជាគំរោងធំមួយទៀតសំរាប់ក្រុមហ៊ុនយើង ។ ចឹងហើយទើបបងអោយបុគ្គលិកសំរាកមួយរសៀលព្រោះពួកគេមមាញឹកណាស់ប៉ុន្មានខែនេះ ទំរាំបានផលដូចព្រឹកមិញ ។»

«អបអរសាទរបង ។»

ឆដានិយាយ ដោយសម្លឹងមុខដ៏សង្ហារបស់ស្វាមីនាង ។ អាន់ដ្រេញញឹមតប ។ ហើយគេក៏សំណេះសំណាលពីនេះពីនោះខណៈរង់ចាំអាហារមកដល់ ។ មាត់ជជែកមែន ក្នុងចិត្តធីតា នឹកគ្រប់សព្វពីអឌិតជាមួយស្វាមីនាង ។

គិតឡើងវិញ ឆដាគិតថានាងមានសំណាងណាស់ដែលមានគេជាគូ ។ គេជាជនបរទេសមែន តែគេមានការយល់ពីប្រពៃណីខ្មែរច្បាស់ណាស់ ។ លើសហ្នឹងទៀត គេមានការគោរពសិទ្ធនិងអោយតម្លៃនារីយ៉ាងគួរអោយសរសើរ ។ រស់នៅជាមួយគ្នា ១០ ឆ្នាំហើយ នាងដឹងថាគេជាមនុស្សស្រឡាញ់គ្រួសារណាស់ ហើយមិនថាការងាររវល់យ៉ាងណាទេ គេមិនដែលភ្លេចចំណាយពេលជាមួយកូននឹងភរិយាទេ ។ បើគេមិនល្អចំពោះនាងនឹងគ្រួសារយ៉ាងនេះទេ នាងប្រហែលជាគ្មានថ្ងៃនេះទេ ។

ហើយអារម្មណ៍ឆដាក៏នឹកឡើងវិញពីរឿងដើមខ្លះៗ ដែលហុចផលអោយមានជាថ្ងៃនេះ ។

ឆដាស្គាល់អាន់ដ្រេដំបូងពីរឆ្នាំបន្ទាប់ពីនិរិនទៅរៀនហើយចោលនាងជាមួយនឹងបេះដូងដែលខ្ទេចខ្ទាំ ។កាលណោះនាងឈឺចាប់ ហើយខ្មាសគេខ្លាំងណាស់ ។ បើកុំតែនាងគិតដល់ពុកម៉ែ នឹងប្អូនៗទាំងពីរដែលគ្នាពឹងលើនាង កុំអីនាងអាចគិតដល់ធ្វើផ្តេសផ្តាស់ផង ។ រាល់រាត្រី ធីតាចាំបានពីទឹកភ្នែកដែលហូររហែងរាល់ពេលដែលធីតាមើលរូបថត ក៏ដូចជាចាប់កាន់ទូរស័ព្ទដែលនិរិនជូននាងមិនប៉ុន្មានខែមុនបែកគ្នាទៅ ។

ទំរាំកាត់ចិត្តបាន យូរណាស់ ។ ពីរឆ្នាំគឺដូចពីរទសវត្ស ។ គ្រប់ទី គ្រប់កន្លែងដែលនាងទៅ គឺសុទ្ធតែប្រឡាក់ប្រឡូសដោយអនុស្សាវរីយ៍របស់នាងជាមួយនិរិន ។ ជាអនុស្សាវរីយ៍ដែលល្អៗទេ គ្រាន់តែចុងបញ្ចប់គឺជូរចត់តែប៉ុណ្ណោះ ។ បើកុំតែបានជួបបុរសដែលជាស្វាមីបច្ចុប្បន្ន ប្រហែលជានាងគ្មានវេលានឹងងើបរួចពីរជម្ងឺចិត្តកាលណោះទេ ។

កាលនោះអាន់ដ្រេ គេទៅលេងកំពតជាមួយមាតាបិតាគេ ជាមួយមិត្តភ័ក្ររបស់លោកទាំងពីរជាទំទាវម្នាក់ដែលអាន់ដ្រេក្រោយមកអោយដឹងថាឈ្មោះផល ជាម្ចាស់ភាគហ៊ុនមួយចំណែកទៀតរបស់ក្រុមហ៊ុននាយ ។ ពួកលោករួសរាយណាស់មិនប្រកាន់ឬកទេ ។ កាលណោះពួកលោកមកស្នាក់នៅសណ្ឋាគារភ្នំខៀវដែលនាងធ្វើការ ។ អាន់ដ្រេហាក់ចាប់អារម្មណ៍នាងជាពិសេសតាំងពីជួបគ្នាដំបូង។ មិនដូចកម្លោះខ្មែរទូទៅទេ អាន់ដ្រេនិយាយត្រង់ៗណាស់ ។ ក្រោយស្នាក់នៅបានមួយថ្ងៃ លុះគេសួរនាំពីនាងដឹងថានាងមានចំការម្រេច ក៏សុំនាំគ្រួសារគេមកលេងចំការ នឹងផ្ទះនាង ។

តាំងពីនោះមក អ្នកក៏ចេញចូលផ្ទះនាងញឹកញាប់ហើយគេក៏ចាប់ផ្តើមរាប់អានគ្នាតាំងពីមិត្តធម្មតារហូតដល់អោយចាស់ទុំចូលស្តីតាមប្រពៃណី ។

ស្តាប់តាមយោបល់របស់មាតា បិតាផង ក៏ដូចជាបងប្អូននាងផង ធីតាទទួលយល់ព្រម ។ ណាមួយនាងក៏យល់ថាមានប្រយោជន៍អ្វីនឹងរស់នៅជាមួយអតីតកាលដែលមិនមានអនាគតនោះ ។ នាងដឹង ហើយយល់ពីចិត្តស្នេហ៍ស្មោះរបស់និរិនចំពោះនាង ។ នាងក៏ដឹងពីរកតញ្ញូកិច្ចរបស់អ្នកចំពោះគ្រួសារអ្នកដែរ ។ តែធីតាអន់ចិត្តត្រង់ថា និរិនហាក់កំសាកមិនហ៊ានអារកាត់ថាគួរអោយនាងចាំអ្នកឬអត់ ។ បើអ្នកអោយនាងចាំ នាងនឹងរង់ចាំ មិនថាយូរយ៉ាងណាទេ ។

តែអនិច្ចា មុនពេលនិរិនទៅរៀនអ្នកគ្រាន់តែមកប្រាប់នាងអោយដឹងពីទឹកចិត្តរបស់ម្តាយអ្នក ចំពោះទំនាក់ទំនងរបស់អ្នកទាំងពីរ ។ ហើយអ្នកកសុំទោសនាងដែលអ្នកមិនអាចចម្លងទូកស្នេហ៍គេទាំងពីរអោយដល់ត្រើយដូចការគ្រោងទុកបាន ។

នាងចាំសំណូមពរចុងក្រោយរបស់នរិន ពេលអ្នកសុំទិញចំការធុរ៉េនពីរហិតតាមិតតាមផ្លូវទៅទឹកឈ្មូរជាប់ជើងភ្នំអោយនាង ជាកាដូរចុងក្រោយមុនការបែកគ្នា ព្រោះគេធ្លាប់សន្យាថាបើសំណាងមានគេនឹងនាងបានរៀបការ គេនឹងទិញចំការនេះជួលគេអោយធ្វើ ហើយធ្វើផ្ទះវិសមកាលមួយគ្រាន់ពេលណាគេទាំងពីរមកលេងកំពតបានលំហែរនៅទីដ៏មនោរម្យដែលអ្នកហាក់ស្រឡាញ់ខ្លាំងបំផុត ។

តែអោយនាងទទួលម្តេចបានទៅ ។ ថ្វីបើនាងក្រ នាងស្រឡាញ់មនុស្ស មិនមែនរបស់ទេ ។ នាងមិនមែនស្រឡាញ់មនុស្សដើម្បីសម្លឹងអ្វីពីអ្នកដែលនាងស្រឡាញ់ជាថ្នូរនឹងរូបគេទេ ។ នាងសុ៊ីរស់នៅជាមួយមនុស្សដែលនាងស្រឡាញ់ក្នុងជីវភាពទីទាល់ តែមិនចង់រស់ក្នុងសម្បត្តិដែលប្តូរមកដោយការខកចិត្ត ហើយគ្មានមនុស្សនោះទេ ។

នឹកដល់ត្រឹមនេះ ធីតាព្រិចភ្នែក គ្រវីក្បាលបន្តិចចជំរុះរឿងចាស់ពីការគិតរបស់នាងហើយផ្តោតលើកាសន្ទនាជាមួយស្វាមីដោយរីករាយ ។ បន្តិចក្រោយមកគេលើកអាហារមក ។

ថ្ងៃនោះបន្ទាប់ពីបាយថ្ងៃហើយ អាន់ដ្រេ ប្រាប់ថាអោយគេអ្នកទៅទទួលកូនពេលចេញពីសាលាហើយល្ងាចនោះគេនឹងទៅបាយប៊ូហ្វេជុំគ្នានៅកាំបូឌីយ៉ាណា ។

ឆដាចេញពីបាយថ្ងៃត្រង់ហើយនាងទៅហាងនាងឯទួលគោកតែម្តង ។

***

# បំណងម្ដាយ

ថ្ងៃទីបួនបន្ទាប់ពីហើយការរស់នៅសៀមរាប ម្ដាយនរិន បបួលអ្នកទៅជិះទូកកំសាន្តឯទន្លេសាបមួយថ្ងៃ ទៅមើលជំរកបក្សី ទៅលេងកន្លែងចិញ្ចឹមក្រពើរឆចុងឃ្នាស ព្រៃកទាល់ ភូមិអណ្តែតទឹក នឹងកន្លែងផ្សេងៗទៀតជាច្រើន ដោយពន្យាពេលទៅភ្នំពេញវិញរហូតដល់ថ្ងៃបន្ទាប់ ។

នរិននឹកដល់ការដែលម្ដាយចង់ចំណាយពេលជាមួយអ្នក អ្នកក៏ព្រម ។ ណាមួយដំណើរទេសចរបែបហ្នឹង ជាដំណើរដែលអ្នកចូលចិត្តផង។

បន្ទាប់ពីអាហារពេលព្រឹកហើយ នៅម៉ោងជាងដប់បន្តិច ណាប់បររថនាំថៅហ្វាយរបស់ខ្លួនទាំងពីររូបទៅជើងតាមផ្លូវទៅភ្នំក្រោម ដែលនៅជាប់មាត់បឹងទន្លេសាប ។ ពីក្រុងសៀមរាបហួសផ្សាចាស់ទៅ ចំងាយផ្លូវគឺប្រហែលជា ១០ គីឡូម៉ែត្រប៉ុណ្ណោះ ជាផ្លូវកៅស៊ូតូច ល្មមរថចៀសគ្នាបានដោយមិនលំបាក រត់បត់បែនអែបខាងជាមួយស្ទឹងសៀមរាបដែលមានរុក្ខាគ្រប់ប្រភេទដុះដង្ហែរគ្របលើស្ទឹងដែលមើលទៅសឹងតែជាប្រឡាយក្នុងខែរាំងដូច្នេះ ។

ផ្ទះអ្នកស្រុកមានតូចមានធំ ខ្លះសង់ផ្ទាល់ដី ខ្លះខ្ពស់ផុតពីដី ទាំងអស់ឈរហូរហែរតាមផ្លូវមិនដាច់ ។ យូរៗម្ដងរថបរហួសស្ពានតូចធំដែលអ្នកស្រុកធ្វើសំរាប់ឆ្លងស្ទឹងពីត្រើយម្ខាងទៅត្រើយម្ខាងទៀត ។

មុនមកដល់ភ្នំក្រោម សងខាងផ្លូវគឺជាវាលទំនាបល្ហល្ហេវមើលដាច់កន្ទុយភ្នែក ។ បើជារដូវវស្សាវិញទីនេះមុខជាទឹកព្រៀបមិនខាន ។

មកដល់ភ្នំក្រោម ណាប់បើករថបន្តតាមផ្លូវដដែលទៅមុខទៀតប្រហែលមួយ ឬពីរគីឡូម៉ែត្រទាល់តែដល់ទីដែលផ្លូវរួមតូចហើយទើបរកកន្លែងចត ។ ម៉ោងដប់នឹងសែសិបនាទីល្មម ។ ព្រះអាទិត្យចាប់ផ្តើមចែងចាំងជះកម្តៅភាយៗហើយ ពេលគេបើកទ្វាររថចេញមកក្រៅ ។

ណាប់លើកធុងទឹកកកមួយតូមល្មមដែលមានដាក់ក្លាសេភេសជ្ជៈគ្រប់ប្រភេទរួមទាំង ទឹកសុទ្ធ ទឹកក្រូច ក៏ដូចជាប៊ៃយែ ផងដែរចេញពីកន្ទុយឡាន ។

ចាក់សោររថស្រលប្លុលហើយ ទាំងបីនាក់ដើរពីរថយន្ត ទៅរកទូកដែលណាប់មកចាត់ចែងជួលរួចជាស្រេចតាំងពីម្សិល ។ ពីនេះទៅផ្លូវលែងស្ទើរហើយព្រោះត្រូវទឹកលិចរាល់ឆ្នាំពេលខែទឹកឡើង ។ លោកជំទាវធ្វើដំណើរដោយប្រយ័ត្នប្រយ៉ែង ហើយនរិនរវៀសរវៃចាំជួយម្ដាយក្រែងលោកជំពប់ជើងដួល ។ ដើរបានបន្តិច កាត់ចំណតទូកដែលចតហូរហែរមានតូចមានធំ ខ្លះមានដំបូល នឹងខ្លះគ្មានទេ បុរសម្នាក់អាយុប្រហែលជា សាមសិបជាងពាក់មួកស្លឹកត្នោតដាចដោយអន្លើ នឹងពាក់អាវដៃវែងពណ៌ផ្ទៃមេឃ ជាមួយខោគគីដែលសាកពណ៌ណាស់ដែរទៅហើយទំនងជាត្រូវថ្ងៃញឹកញាប់ចេញមកទទួល ។

«ជំរាបលោកស្រី នេះ ចក់ ជាម្ចាស់ទូក នឹងជាអ្នកដែលនាំយើងកំសាន្តតាមបឹងថ្ងៃនេះ ។»

ណាប់ណែនាំ ។

«ចក់ នេះលោកស្រីនឹងបុត្ររបស់លោក ។»

ចក់លើកដៃសំពះស្វាគមន៍តាមរបៀប ហើយពីរនាក់ម្ដាយកូនសំពះទទួលវិញតាមរបៀបខ្មែរ ។

«អញ្ជើញមកខាងនេះលោកស្រី នឹងលោកក្មួយ ។»

ចក់ពោល ហើយដើរនាំមុខទៅ ទាំងដណ្ដើមយ៉ីកធុងទឹកកកពីដៃរបស់ណាប់ទៅយួរផង ។ បន្តិចក្រោយមកគេមកដល់ទូកឈើធំទូលាយមួយមានដំបូលនឹងមានតុមួយ កៅអីបួនសំរាប់អង្គុយមើលទេសភាព ។ ទាំងអស់គ្នាឡើងទូកហើយ ហើយចក់បញ្ឆេះម៉ាស៊ីនចេញទៅ ។

ណាប់ទៅអង្គុយក្បែរចក់ជជែកគ្នា ទុកអោយលោកជំទាវនឹងបុត្រជជែកគ្នាតាមសំរួល ។ ទូកយន្តជ្រែកទឹកថ្លាខ្យងបែកខ្ញាយ បង្ករជំារលកលរលេញពីក្រោយដេញគ្នាឈូឆរទៅផ្ទប់ច្រាំងនឹងគុម្ពោតឈើដែលដុះក្នុងទឹក ។

«យើងខានមកទីនេះប៉ុន្មានឆ្នាំហើយកូន?»

ជំទាវផលសួរបុត្ររបស់លោកដែលអង្គុយទន្ទឹមលោក ។ ភ្នែកអ្នកទាំងពីរមើលទៅមុខ ។

«ប្រហែលបួនឬប្រាំឆ្នាំហើយម៉ាក់ ។»

នរិនឆ្លើយបណ្ដើរទាញយកឌីជីតថលកាម៉េរ៉ាពីកាបូបស្ពាយរបស់អ្នកបណ្ដើរ ។

«ទីនេះប្លែកច្រើនណាស់ ។ មនុស្សរស់នៅតាមសងខាងផ្លូវក៏ច្រើនជាងមុនដែរ ។»

ហើយទាំងពីរក៏ជជែកពីនេះពីនោះដរាបមកដល់ភូមិអណ្ដែតទឹកទឹកចក់បន្ថយល្បឿនទូកហើយបើកតិចៗ ។

គេយល់ផ្ទះអ្នកស្រុក សាលារៀន វិហារកាតូលិក តូបចាប់ហួយ ប៉ុស្តិប៉ូលីស ក៏ដូចជាបែចិញ្ចឹមត្រីដែលផ្គុំគ្នាស្កេកស្កះរសាត់អណ្ដែតឃ្លីងឃ្លោងតាមរលកទឹកពេលមានទូកយន្តបើកកាត់ទៅមកម្ដងៗ ។

អ្នកលក់ដូរខ្លះអុំទូកតូចៗរបស់ខ្លួន តាមផ្ទះទឹកអ្នកស្រុកហើយពពាយនាយលក់កវ៉ាន់ឮកោកកាកមិនដាច់ ។ កុមារខ្លះអាយុមិនដល់ដប់ឆ្នាំផងអុំឬចែវទូកយ៉ាងចំណាប់ ប្រសាចទៅមក ។

ហួសភូមិបណ្ដែតទឹកនេះបន្តិច ចក់នាំអ្នកទាំងពីរមកមើលកន្លែងចិញ្ចឹមក្រពើរមួយយ៉ាងធំបង្ករដាក់ក្នុងបែរបណ្ដែតទឹក ។ នរិននឹងម្ដាយរបស់អ្នកចុះពីទូកហើយទៅមើលកន្លែងចិញ្ចឹមក្រពើនោះចំពេលគេអោយចំណីវាល្មម ។ នរិនឃើញក្មេងប្រុសជំទង់ម្នាក់យួរបាវមួយធ្ងន់គួរសមដើរតំរង់មកមាត់បែ ហើយបើកមាត់បាវចាក់ពស់រាប់សិបក្បាលសុទ្ធតែរស់រវើកចូលទៅ ។ ក្រពើររាប់សិបក្បាលមានតូចមានធំស្ទុះស្ទារជាន់គ្នាមកខាំពស់ហែកដណ្ដើមគ្នាស៊ីយ៉ាងឆ្ងាញ់មាត់ ។ លោកជំទាវគ្រញែងខ្លួនដោយញញើតញញើមនឹងពស់ ខណះនរិនគិតតែពីចុចម៉ាស៊ីនថតរបស់ខ្លួនផ្ចិតយកសកម្មភាពយ៉ាងជក់ចិត្ត ។

គេសំរាកនៅទីនោះបន្តិច ញ៉ាំកាហ្វេមួយកែវម្នាក់ហើយទើបចេញដំណើរទៅមើលជំរកបក្សីបន្តទៀត ។ គេឃើញមានភ្ញៀវទេសចរជាច្រើនដែលមកមើលបក្សីដ៏សំបូរណ៍បែបនៅលើផ្ទៃបឹងដ៏ធំល្វឹងល្វើយនេះ ។

លុះធ្វើដំណើរកំសាន្តគ្រប់គ្រាន់ហើយ គេនាំគ្នាបកមកទទួលទានបាយនៅភោជនីយដ្ឋានបណ្ដែតទឹកមួយធំគួរសមនៅម្ដុំចុងឃ្នាស ។ អតិថិជនភាគច្រើនដែលមកបរិភោគក្នុងហាងនេះ គឺជាភ្ញៀវបរទេស មានប្រុសមានស្រី ។

ហាងបណ្ដែតទឹកដ៏ទំនើបនេះមានផ្លាកបង្ហាញឈ្មោះដែលអានបានថា សុវណ្ណមច្ឆា ។

គេនាំគ្នាឡើងពីទូក ហើយឡើងជណ្ដើរខ្លីៗបីបួនកាំ មុនមកដល់ខាងក្នុងហាង ដែលមានតុសរុបប្រហែលជាដប់តុដែរ ។ នរិនជ្រើសរើសតុមួយអង្គុយជាមួយម្ដាយ ឯក្បែរបង្អួចឆ្ងាយពីគេឯង ។ ចក់នឹងណាប់អង្គុយនៅតុមួយទៀតនៅមាត់ផ្លូវចូល ។ មិនបង្អង់យូរ គេហៅអាហារភ្លាម ហើយទទួលទានយ៉ាងឆ្ងាញ់ពិសារ ។

បន្ទាប់ពីស្រស់ស្របអាហារហើយ ជំទាវផល មើលមុខបុត្ររបស់លោក ហើយពោលថា ៖

«នរិន ម៉ាក់មានរឿងមួយចង់ប្រាប់កូន ។ តែមុននឹងចូលរឿងនេះ ម៉ាក់ចង់ដឹងថាកូននៅប្រកាន់ខឹងនឹងម៉ាក់ទេដែលបង្ខំកូនអោយទៅរៀន ចោលមនុស្សដែលកូនស្រឡាញ់?»

«ម៉ាក់...»

នរិនសម្លឹងមុខម្ដាយ ហាក់ប្រឹងស្វែងយល់ថាលោកមានបំណងអ្វីទៀតហើយ ។

«រឿងកន្លងទៅយូរណាស់ហើយ ខ្ញុំមិនចង់រំលឹកវាទៀតទេ ។»

«រឿងកន្លងយូរមែន តែម៉ាក់ដឹងថាកូននៅមិនទាន់បំភ្លេចវាទោះបីតិចតួចក៏ទេដែរ ។»

«ម៉េចម៉ាក់មានប្រសាសន៍អ៊ីចឹង?»

នរិនសួរម្ដាយអ្នក ។ ដៃអ្នកស្រាក់គ្នាហើយយកមកទល់ចង្ការ ។

«ម៉ាក់ដឹង ។ ម៉ាក់ស្គាល់កូនរបស់ម៉ាក់ ។ តាំងពីថ្ងៃកូនទៅម៉ែលប៊ិន ចោលឆដា កូនប្រែជាមនុស្សផ្សេងស្ទើរទាំងស្រុង ។ ថ្វីបើកូនរៀនកាន់តែពូកែរ ហើយទទួលបានជោគជ័យរាល់ការងារដែលកូនធ្វើ កូនបាត់អស់ភាពរួសរាយដែលម៉ាក់ធ្លាប់យល់ ។ ពេលកូនមកលេងម៉ាក់ កូនខំប្រឹងញញឹមនឹងលេងសើចដើម្បីអោយម៉ាក់បានសប្បាយចិត្ត ។ តែម៉ាក់មើលដឹងថានៅពីក្រោយភាពស្រស់ស្រាយនេះគឺទុក្ខព្រួយដ៏ធំសង្កត់ទ្រូងកូន ។ ទុក្ខព្រួយតែមួយមិនដែលប្រែប្រួលទៅតាមពេលវេលា ។ ម៉ាក់សុំទោស ដែលត្រូវអូសកូនមកជាមួយម៉ាក់មកសៀមរាបនេះ បង្អាក់ឱកាសកូនទៅជួបឆដា ។»

ស្ដាប់មាតាមកដល់ត្រឹមនេះ នរិនភ្ញាក់ព្រើតដូចដើរជាន់ក្បាលពស់ដ៏ធំមួយ ។

«ម៉េចម៉ាកដឹង?»

«នរិន មានរឿងច្រើនដែលម៉ាក់ដឹងពីកូន តែកូនមិនដឹងពីម៉ាក់ទេ ។ ម៉ាក់ដឹងដោយរបៀបណានោះមិនសំខាន់ទេ ដែលសំខាន់នោះគឺចង់អោយកូនដឹងថា ម៉ាក់មិនចង់ឃើញកូនយ៉ាងនេះតទៅទៀតទេ ។ ថ្ងៃនេះម៉ាក់ចង់ប្រាប់កូនអោយដឹងគ្រប់យ៉ាងដែលម៉ាក់លាក់បាំងកូន អស់ពេល ១៣ ឆ្នាំមកហើយ ។ ម៉ាក់សង្ឃឹមថាក្រោយពីកូនបានដឹងរឿងរ៉ាវដែលម៉ាក់លាក់បាំងទាំងនេះអស់ហើយ កូនអាចនឹងបំភ្លេចអតីតកាល អភ័យអោយម៉ាក់ ហើយតម្រង់ជីវិតកូនទៅមុខទៀត ។»

នរិននៅស្ងៀម សម្ងំចាំស្ដាប់ម្ដាយ ។ ដៃអ្នកបង្វិលឈើចាក់ធ្មេញលេង ។

ជំទាវផល ដកដង្ហើមបំពេញសួត គ្រហែមជំរះបន្តិចហើយចាប់ផ្ដើមរៀបរាប់រឿងហេតុគ្រប់យ៉ាងដល់នរិនក្នុងសំឡេងដែលល្មមអ្នកទាំងពីរឮបានដោយមិនពិបាក ។ នរិនស្ដាប់ដោយស្ងៀមស្ងាត់ នឹងយកចិត្តទុកដាក់ ។

លុះលោកនិយាយចប់ហើយ អ្វីដែលអ្នកឮពីលោកធ្វើអោយចិត្តអ្នករិតតែខ្លោចផ្សា ។

អ្នកអោនមុខជ្រប់ ។ ទឹកភ្នែកអ្នកហូរច្រោក ហើយស្រក់រហែង ហូរតាមថ្ពាល់អ្នកមុនស្រក់ទៅក្រោមតាមប្រឡោះក្ដាហើយស្រក់តក់ៗទៅក្នុងអាងបឹងទន្លេសាបដ៏មហាសាល ។ ទឹកបឹងក៏កើនឡើងតាមដំណក់ទឹកភ្នែកទាំងនោះ តែមិនមាននរណាចាប់អារម្មណ៍ពីកំណើននេះ ក៏ដូចជាការសន្ទនាគ្នារបស់ពីរនាក់ម៉ែកូននេះទេ ។

ព្រះអើយ តើអ្នកត្រូវធ្វើដូចម្ដេច ហើយគិតយ៉ាងម៉េចវិញចំពោះបំណងល្អៗរបស់ម្ដាយទាំងអស់នោះ បំណងល្អដែលធ្វើអោយរកាំចិត្តអ្នកមួយជីវិត? ។

តើអ្នកគួរខឹង ឬបន្ទោស ឬអរគុណលោក ឬធ្វើយ៉ាងម៉េចវិញទៅ បើលោកធ្វើគ្រប់យ៉ាងដើម្បីអ្នក នឹងមនុស្សដែលអ្នកស្រឡាញ់ហើយតើ?

ឱ កម្មអើយ!

នរិនបន្ធូដង្ហើមធំ ។ ជំទាវផលស្ងៀមស្ងាត់មិនមាត់កចាំមើលប្រតិកម្មរបស់បុត្រលោក ។

***

# ម៉ែលប៊ិន

នរិនរិលពីភ្នំពេញហើយចូលធ្វើការនៅក្រុមហ៊ុនអ្នកឯម៉ែលប៊ិនបានមួយអាទិត្យហើយ ។ អារម្មណ៍អ្នកនៅមិនដាច់ស្រេចពីអ្វីដែលអ្នកបានឮពីម្តាយនៅឡើយទេ ។

ល្ងាចថ្ងៃសុក្រទី ១៤ នេះអ្នកអង្គុយនៅ សៅធ៍បេង្គ របស់ទន្លេយ៉ារ៉ា ក្នុងភោជនីយដ្ឋានបារមួយដែលមើលទៅឃើញស្ពានសំរាប់អ្នកថ្មើរជើងសណ្តុកខ្លួនកាត់ទទឹងទន្លេយ៉ារ៉ាដ៏តូចច្រឡឹង នឹង ស្ថានីយ៍រថភ្លើង ហ្លីនឌើស្ត្រីត របស់ម៉ែលប៊ិន ដែលត្រូវភ្លើងបំភ្លឺឡើងពណ៌លឿងឆ្អៅដូចធ្វើអំពីមាសសុទ្ធ ។

ចំរៀងរបស់ Adele ក្នុងបទ Someone Like You ដែលបន្លឺចេញពីក្នុងបារមកមានសភាពគំអូញគួរអោយអាណោចចិត្ត ។

ADELE

"Someone Like You"

I heard that you're settled down
That you found a girl and you're married now.
I heard that your dreams came true.
Guess she gave you things I didn't give to you.

Old friend, why are you so shy?
Ain't like you to hold back or hide from the light.

I hate to turn up out of the blue uninvited
But I couldn't stay away, I couldn't fight it.
I had hoped you'd see my face and that you'd be reminded
That for me it isn't over.

Never mind, I'll find someone like you
I wish nothing but the best for you too
Don't forget me, I beg
I remember you said,
"Sometimes it lasts in love but sometimes it hurts instead,
Sometimes it lasts in love but sometimes it hurts instead"

You know how the time flies
Only yesterday was the time of our lives
We were born and raised
In a summer haze

Bound by the surprise of our glory days

I hate to turn up out of the blue uninvited
But I couldn't stay away, I couldn't fight it.
I'd hoped you'd see my face and that you'd be reminded
That for me it isn't over.

Never mind, I'll find someone like you
I wish nothing but the best for you too
Don't forget me, I beg
I remember you said,
"Sometimes it lasts in love but sometimes it hurts instead."

Nothing compares
No worries or cares
Regrets and mistakes
They are memories made.
Who would have known how bittersweet this would taste?

Never mind, I'll find someone like you
I wish nothing but the best for you
Don't forget me, I beg
I remember you said,
"Sometimes it lasts in love but sometimes it hurts instead."

Never mind, I'll find someone like you
I wish nothing but the best for you too
Don't forget me, I beg
I remember you said,
"Sometimes it lasts in love but sometimes it hurts instead,
Sometimes it lasts in love but sometimes it hurts instead."

នៅខាងក្រៅបារ មេឃាខែកុម្ភៈជារដូវក្ដៅនៅធានីមែល ប៊ិនមានពណ៌ខៀវល្អ ស្រឡះ អមដោយស្បែពពកប៉ុន្មានស្បែរសាត់វាយប៉ាយយ៉ាងគ្មានសណ្ដាប់ធ្នាប់ពេញនភាឯនាយសន្លឹម ។

អ្នកអង្គុយក្រេបប៊ីយៀរបណ្ដើរមើលអ្នកដំណើរប្រុសស្រី មានចាស់មានក្មេង ដែលដើរកាត់ទៅមកបណ្ដើរ ។

គ្រប់គ្នាមើលទៅសុទ្ធតែមានអារម្មណ៍រីករាយ  នឹងស្រស់ថ្លាក្នុងសម្លៀកបំពាក់រដូវក្ដៅមានស្ទើងមានខ្លី ចម្រុះម៉ូដម៉ាកនឹងពណ៌គួរអោយពេចពិលរមិលគន់ ។

អារម្មណ៍របស់អ្នកអណ្ដែតទៅវែងឆ្ងាយ ។ ពាក្យម្ដាយរបស់អ្នកដែលអ្នកបានស្ដាប់នៅទន្លេសាបនៅឮរងំក្នុងត្រចៀកអ្នកហាក់មិនរលប់ទៅណាសោះ ។

«និន ម៉ាក់គិតថាដល់ពេលដែលអោយដឹងអោយអស់ពីអ្វីដែលម៉ាក់លាក់បាំងកូនអស់រយៈកាលដប់បីឆ្នាំកន្លងមកនេះហើយ ។ ម៉ាក់គិតថាពេលវេលាអាចធ្វើអោយកូនបំភ្លេចអតីតកាលហើយរស់នៅទទួលបច្ចុប្បន្នភាពត្រៀមចាំអនាគត ។ ម៉ាក់គិតខុស ។ ម៉ាក់ពិតជាស្មានចិត្តកូនមិនដល់មែន ។ ដប់បីឆ្នាំមកនេះម៉ាក់យល់តែភាពសោកសង្រេងក្នុងចិត្តកូន ទោះបីកូនខំលាក់បាំងម៉ាក់យ៉ាងណាក៏ដោយ ។ យល់កូនយ៉ាងនេះ ទ្រូងម៉ាក់ក៏ខ្លោចផ្សារទៅតាមនោះដែរ ។ កូនអើយ ចិត្តម្ដាយគឺយ៉ាងនេះហើយ ។ ម្ដាយគ្រប់រូបតែងចង់អោយកូនខ្លួនបានល្អ បានប្រសើរ ហើយអ្វីដែលម៉ាក់ធ្វើចំពោះកូនកាលពី

អតីតកាលក៏ក្នុងបំណងដូច្នោះដែរ ។ ម៉ាក់សុំទោសដែលបំបែកកូនមិនអោយជួបមនុស្សដែលកូនស្រឡាញ់ ជាសេចក្តីស្រឡាញ់ដោយភក្តីភាព ។

ប៉ុន្មានឆ្នាំក្រោយកូនទៅរៀន កូនមិនដែលមកលេងស្រុកខ្មែរទេ ។ កូនច្បាស់ជាខឹងនឹងម៉ាក់ ហើយក្នុងពេលនោះឯងដែលម៉ាក់គិតឡើងវិញពីកំហុសម៉ាក់ ។ ម៉ាក់ដឹងថាកូនច្បាស់ជាបារម្ភពីឆដា នឹងអនាគតនាងណាស់ ។ ជួសមុខអោយកូនក្នុងបំណងរកអនាគតល្អមួយអោយឆដា ម៉ាក់មានបំណង នឹងក្រោយមកបានណែនាំកូនប្រុសរបស់មិត្តម៉ាក់ម្នាក់ឈ្មោះអាន់ដ្រេអោយទៅស្គាល់ឆដា ។ គេនឹងឪពុកម្តាយគេជាជនជាតិរុស្សីទេ តែគ្រួសារគេសំរេចចិត្តមករស់នៅស្រុកខ្មែរជាអចិន្ត្រៃយ៍ហើយ គឺក្រោយភារះទូតរបស់គេចប់ ។ គ្រួសារនេះស្រឡាញ់ស្រុកខ្មែរ មនុស្សខ្មែរ នឹងវប្បធម៌ខ្មែរណាស់ ។ ពេលគេឃើញឆដា គេពេញចិត្តនាង នឹងជីវភាពគ្រួសារនាងភ្លាម ។ ម៉ាក់ក៏ទទួលស្គាល់ថា ឆដា ទន់ភ្លន់នឹងដឹងខុសត្រូវគួរអោយស្រឡាញ់ណាស់ ។ ក្រោយពេលពួកគេស្គាល់គ្នាបានមួយរយះ អាន់ដ្រេក៏អោយមាតាបិតាគេចូលស្តីតាមប្រពៃណី ។

ម៉ាក់បានទៅជួបមាតាបិតាឆដាដោយឡែក មុនការចូលស្តីនេះ ។ ម៉ាក់បានប្រាប់អោយពួកលោកដឹងថាម៉ាក់ជានរណា ហើយមានបំនងយ៉ាងណាជាមួយពួកគាត់ ក៏ដូចជាជាមួយឆដា ។ ម៉ាក់បានសូមទោសគាត់ ដែលបំបែកកូនមិនអោយរៀបការជាមួយឆដា ហើយពន្យល់គាត់អោយយល់ពីបំណងរបស់ប៉ាកូន ក៏ដូចបំណងរបស់ម៉ាក់ដែរ ។ ម៉ាក់ប្រាប់ពួកលោកថា ម៉ាក់ចង់អោយកូនផ្តោតអារម្មណ៍លើការរៀនសូត្រនឹងស្រាវជ្រាវអោយបានយូរអង្វែង ដែលអាចមិនដឹងថាពេលណាកូនអាចនឹងរៀបការបានទេ ។ ម៉ាក់ថាឆដានៅក្មេង កូនក៏នៅក្មេងដែរ ហើយម៉ាក់ក្រែងកូនកែរ ប្រែចិត្តយ៉ាងណាយ៉ាងណីថ្ងៃក្រោយទៅ បើអោយឆដារងចាំកូន នាំអោយខកការ នឹងខូចចិត្តក៏ដូចជាអនាគតដែរ ។ លោកស្តាប់ហើយក៏ទៅពន្យល់ប្រាប់ឆដាតាមដំណើរ ។ ពេលអាន់ដ្រេចូលស្តី ឆដាក៏ព្រមព្រៀងហើយអាពាហ៍ពិពាហ៍មួយក៏បានរៀបចំឡើង បីឆ្នាំក្រោយកូនទៅរៀនឯមែលប៊ន ។ ក្រោយរៀបការពួកគេមករស់នៅឯភ្នំពេញនៅម្តុំ ណាធ័ប្រ៊ុធ ។

ម៉ាក់មិនបានប្រាប់កូនអោយដឹងទេ ព្រោះម៉ាក់ចង់អោយកូនស្ងប់ចិត្តតទៅទៀត ។ ម៉ាក់ក្រែងដំណឹងនោះ ធ្វើអោយរបួសចិត្តកូនកម្រើកឡើងវិញ ។ កាលនោះកូនទើបតែចប់ម៉ាស្ទើរ ហើយត យក ភីអេចឌីបានមួយឆ្នាំជាងទេ ។ ក្រោយអាពាហ៍ពិពាហ៍ប្រហែលជិតមួយឆ្នាំ ពេលម៉ាក់ទៅលេងម្តាយឪពុករបស់ឆដា ឆដាក៏មកលេងអ្នកមានគុណរបស់នាងដែរជាមួយស្វាមីនាង ។ នាងបានជួបម៉ាក់នៅទីនោះ ហើយគ្រប់យ៉ាងក៏បានលាតត្រដាង ។ ម៉ាក់សុំទោសនាង ហើយនាងក៏អភ័យតាមចរិកល្អរបស់នាង ។ តាំងពីពេលនោះមក រាល់ពេលបុណ្យទានជាតិម្តងៗ ឆដាតែងនាំស្វាមីនាងមកលេងម៉ាក់មិនដែលខានទេ ហើយតែងសួរនាំពីដំណឹងកូនមិនដាច់ឡើយ ។

ក្រោយមកបានម៉ាក់ដឹងថា ឆដារក្សាទូរស័ព្ទដែលកូនទិញអោយនាងទុកជានិច្ច ។ តាំងពីកូនទៅរៀន នាងចាំមើលដំណឹងកូន ហើយកាន់ទូរស័ព្ទតាមខ្លួនមិនឃ្លាតទេ ។ តែលុះគ្មានដំណឹងពីកូន នាងសច្ចាថានឹងមិនប្រើទូរស័ព្ទដៃទៀតទេ ។ យ៉ាងហ្នឹងហើយទើបពេលកូនសុំលេខនាង នាងអោយ អ៊ីម៉ែលរបស់នាងមកកូនវិញ ។

«បង នរិន!»

សំឡេងស្រយស្រេះមួយបន្លឺឡើង ពន្ទាក់អារម្មណ៍របស់នរិនពីសម្តីម្តាយ ។

នរិនងាកទៅប្រភពសំឡេង ក៏យល់ បញ្ញាវី ក្នុងឈុតរ៉ូបផ្កា ខ្លីលើជង្គង់បន្តិច ។ រ៉ូបស្ដើងរិតរាងធីតាណែន បង្ហាញចង្កេះតូច ដើមទ្រូងពើងណែន នឹងត្រគៀកមូលក្លំ ។

ធីតាទំលាក់សក់ប្រាសស្មារបស់នាង អោយវាតាផាយផាត់បន្លែង បង្ហាញ ត្រចៀកទាំងគូដែលលម្អដោយក្រវិលពេជ្រមួយគូដេញរស្មី ចាំងពន្លឺផ្លេកៗជាមួយនឹងឆព័ណ្ណរង្សីនាគ្រាសាយ័ណ្ហ ។ ថ្ពាល់សក្រពុំរលោងទាំងគូ ត្រូវនាងផាត់ពណ៌ក្រហមព្រឿងៗគួរអោយទាក់ភ្នែក ។

នារីដើរតម្រង់មកមាណពទាំងញញឹមពព្រាយ បបូរមាត់ពណ៌ស៊ីជម្ពូ ស៊ីគ្នាជាមួយនឹងពណ៌រ៉ូបក៏ដូចជាសម្បុរសំបករបស់នាង ។

ពេលដើរមកដល់តុដែលនរិនកំពុងអង្គុយ នារីពោលសុំទោសពីការយឺតយ៉ាវរបស់នាង មុនទាញកៅអីមួយទម្លាក់ខ្លួនអង្គុយចុះដែរ ។

«សុំទោស អោយបងចាំបន្តិចហើយ ។»

ធីតាញញឹមយ៉ាងស្រស់ល្អងចិត្តមិត្តនាង ។

«ពិបាករកកន្លែងចតបន្តិចស្មើរណោះ ។»

នាងបន្ត ។

«មិនអីទេ វី»

នរិនតប ក្រោយនាងអង្គុយស្រលបួលហើយ ។

«ម៉េចដែររវល់ទេនៅធនាគារថ្ងៃនេះ?» អ្នកសួរបន្ត ។

«រវល់គួរសម បង ។ ដូចដឹងស្រាប់ហើយអោយតែថ្ងៃសុក្រគឺសឹងតែមិនមានពេលពត់ខ្លួនផង ។»

ធីតាឆ្លើយ ហើយងាកទៅនិយាយជាមួយអ្នករត់តុដែលមកឈរក្បែរនោះ ។

«Can I have a moment, please?» អ្នករត់តុដែលជាយុវជនដែលមានឈាមជ័រជាអ្នកអឺរ៉ុបក្នុងវ័យប្រមាណ ២០ ឆ្នាំជាង ញញឹម ងក់ក្បាលបន្តិចហើយដើរចេញទៅ ។

«បងយល់ឃើញយ៉ាងម៉េចដែរ? យើងគួរហៅអាហារល្ងាចមកញុំាតែម្តងទៅ ឬគ្រាន់តែញុំាប៊ីយៀលេងសិន»

ពោលបណ្តើរ នារីបើកមេនុ្យមើលបណ្តើរ ។

«ហៅប៊ីយៀ ញុំាលេងសិនទៅ ។ ល្ងាចនេះបងប៉ាវវីទៅភោជនីយដ្ឋានម្ហូបខ្មែរនៅដុកឃ័លែនម្តង ។ យ៉ាងម៉េចដែរ?»

«ទើបមកពីស្រុកខ្មែរ បងនៅចង់ម្ហូបខ្មែរទៀតឬ?»

បញ្ចារីសួរទាំងញញឹម ហើយងើបពីកៅអីដើរទៅបារ ហៅ ហិនីគែនមួយដបអោយខ្លួនឯង ។ នរិនញឹមៗមិនស្តី ។

ទាំងពីរនាក់ញុំាបណ្តើរ ជជែកគ្នាលេងយ៉ាងស្និទ្ធស្នាលបណ្តើរ ។

លុះហើយគេនាំគ្នាដើរលេងតាមមាត់ទន្លេយ៉ារ៉ា ឆ្ពោះទៅស្ពានថ្មុ ផ្លូវស្វេនស្តុន ។ ពេលមកដល់ជណ្តើរឡើងទៅផ្លូវនេះ គេឡើងជណ្តើរហើយដើរតម្រង់ទៅ អាន់សិនធើ ។ គេមានបំណងដើរលំហ្វែងសួន ឃ្វីនវីគតូរីយ៉ា ។ គេឆ្លងផ្លូវហើយដើរទន្ទឹមគ្នាសារសងយ៉ាងសប្បាយរីករាយ ។

ម៉ោងជាងប្រាំពីរហើយតែមេឃនៅភ្លឺថែស ។ ក្នុងរដូវក្តៅ ម៉ោងប្រាំបួនឯណោះទើបមេឃចាប់ផ្តើមងងិត ។

ពេលមកដល់ពាក់កណ្តាលសួន មានបង់អង្គុយលេងមួយនរិនចង្អុលទៅបង់នោះហើយនាំគ្នាទៅអង្គុយលេង ។

«យើងស្គាល់គ្នាប៉ុន្មានឆ្នាំហើយ អូន?»

នរិនសួរសំឡេងស្ទើរទៅកាន់នារីជាមិត្តរបស់អ្នកដែលអង្គុយក្បែរកាយអ្នក ។ ពាក្យ អូន ខាងចុងប្រយោគខ្សោយស្ទើរតែស្តាប់មិនឮ ។ អ្នកពោលបែបហឹ ខណៈដែលភ្នែកអ្នកមើលទៅក្មេងប៉ុន្មាននាក់ដែលកំពុងអោយបេះនំប៉័ងអោយជាចំណីទៅទាមួយហ្វូងក្នុងកូនបឹងតូចមួយកណ្តាលសួន ។

នារីបើកភ្នែកធំៗមើលទៅមិត្តនាង ។ នាងចង់ស្ទើរអោយបុរសនិយាយសំណួរទាំងស្រុងសារឡើងវិញ តែដូរចិត្តមកវិញ ។ នាងឆ្លើយទាំងភ្នែកនៅសម្លឹងមុខនាយមិនដាក់នៅឡើយ ៖

«ជាងប្រាំឆ្នាំហើយ ។ គឺតាំងពីខ្ញុំមករៀនមែលប៊ិនដំបូង ។»

នារីឆ្លើយដោយសំឡេងធម្មតាដែរ ។ នាងផ្អែកខ្នងទៅនឹងបង្អែកបង់ហើយភ្នែកសម្លឹងទៅវាលស្មៅខៀវខ្ចី កាត់ស្មើរត្រឹមធេង រត់ពឹតពើងតាមសណ្ឋានដី ។

«សំណាងណាស់ខ្ញុំមករៀនទីនេះ...»

នាងបន្ត ។

«...ហើយបានស្គាល់បង ដែលជាជំនួយគ្រប់សព្វ តាំងពីការរស់នៅ កម្សាន្ត នឹងហូបចុក រហូតដល់ការរៀនសូត្រទៀតផង ។»

នរិនញញឹមសម្លឹងមិត្តនាយ ។ នាងញញឹមតបហើយបន្ត ៖

«...មិនមានបង ខ្ញុំច្បាស់ជាអផ្សុក យំនឹកផ្ទះស្លាប់ហើយ ហើយរៀនសូត្រទៀតសោតក៏ប្រហែលមិនបានសំរេចដោយជោគជ័យយ៉ាងដូចកើតហើយនោះទេ ។»

ហើយទាំងគូរក៏ស្ងាត់មួយខណះទៅ ។ វិពេរមួយហ្វូងទើបនឹងហើរមកចុះនៅមិនឆ្ងាយពីរអ្នកទាំងពីរប៉ុន្មាន ។

«យល់ថាបងជាមនុស្សយ៉ាងណាដែរ?»

នរិនសួរយុរនាចក្នុងសំឡេងដដែល ។

នារីហាក់ចាប់ភ្លឹកម៉ាមាណពកំពុងចោលតម្រុយអ្វីមួយ ។ នាងងាកមកមើលចំភ្នែកនាយ ហើយតបថា ៖

«បងជាមនុស្សល្អណាស់ ។ ជាសុភាពបុរសដែលមានគុណសម្បត្តិពិបាកនឹងរកបានណាស់ក្នុងពេលបច្ចុប្បន្ននេះ ។»

នរិនបែរមុខមើលទៅចំភ្នែកនារីដែរ ។

«បងមានអីជូនអូនថ្ងៃវ៉ាឡិនថាញនេះ ។»

ថាហើយដៃអ្នកលូកទៅក្នុងហោប៉ៅខោ ហើយអ្នកទាញយកប្រអប់តូចមួយចេញមក ។

ធីតាបើកភ្នែកធំៗ ។ បេះដូងក្នុងទ្រូងនាងលោតញាប់ស្មើរធ្លាយទ្រូង ។

បុរសងើបឈរ បែមុខអ្នកចំមុខនារី រួចហើយធ្វើអ្វីម្យ៉ាងដែលសឹងតែធ្វើអោយនារីងងឹតមុខដួលដោយបិតិសោមនស្ស ។

នរិនលុតជង្គង់ម្ខាងចុះមុខនារី ដៃអ្នកបើកប្រអប់តូចពណ៌ខ្មៅនោះ បង្ហាញចិញ្ចៀនពេជ្រមួយវង់ដាំពេជ្រតែមួយគ្រាប់យ៉ាងធំចាំងរស្មីព្រិចៗ ។

ឆោមស្រស់ច្រហរមាត់ធ្លុង បេះដូងនាងលោតកាន់តែញាប់ស្មើរលោតចេញមកក្រៅចំរឹងទ្រូង ។ ភ្នែកនាងឡើងស្រវាំង ត្រចៀកឡើងហ៊ឹង ។ បំពង់កនាងស្ងួតថែស ។ នាងលេបទឹកមាត់ផ្សើមបំពង់កដោយលំបាក ។

នាងមានអារម្មណ៍ដូចរកកលនឹងគ្រនវ៉ី

«បងល្អល្មមអោយអូនព្រមធ្វើជាភរិយាបងទេ?»

នរិនពោល ភ្នែកអ្នកងើយមើលចំភ្នែកឆោមយង់។

ធីតានៅស្ងាត់ដោយស្រឡាំងកាំងនៅឡើយ ។

«ព្រមរៀបការជាមួយបងទេ?»

នរិនបន្ត ។

«ព្រមធ្វើជាភរិយាបងទេ?»

អ្នកបញ្ជាក់អោយច្បាស់ពីបំណងអ្នក ។

មាណវីនៅបើកភ្នែកធំៗ ហាក់មិនព្រមជឿភ្នែក នឹងត្រចៀកខ្លួនឯងដែលបានឃើញនឹងឮអ្វីដែលទើបនឹងបានឮអំបាញមិញនៅឡើយ ។

តាំងពីនាងស្គាល់គេនាគ្រាដំបូង នាងពេញចិត្តនឹងរូបរាង ក៏ដូចជាចារិក ឬកពាររបស់នរិន ទាំងគ្រប់ ។ កាលដែលបានស្គាល់គ្នាកាន់តែច្បាស់ ជាមួយនឹងពេលវេលាដែលកន្លងទៅកាន់តែយូរ នាងកាន់តែចូលចិត្ត គោរព នឹងកាន់តែពេញចិត្តបុរសម្នាក់នេះខ្លាំងឡើង។ អារម្មណ៍ទាំងនេះជាមួយនឹងការស្និទ្ធស្នាល ការយកចិត្តទុកដាក់នានារបស់យុវបុរស យូរទៅក៏ពួនផ្ដុំកើតជាក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅចំពោះមាណព ។

នាងមិនដែលមានអារម្មណ៍បែបនេះចំពោះអ្នកណាទេ ។ មាតាបិតានាងប្រយ័ត្នប្រយ៉ែងណាស់ លោកតែងរំលឹកនាងញយៗមិនអោយធ្លោយចិត្តដោយងាយព្រោះនាំអោយរំខានសុភមង្គលផ្ទាល់ខ្លួន គំដូចជាគ្រួសារ ។ ជាបុត្រីល្អតាមបង្គាប់ នឹងដំបូន្មាន នារីដឹង ហើយតែប្រយ័ត្នប្រយ៉ែងចិត្តខ្លួនជានិច្ច ។

តែលើកនេះប្រយ័ត្នយ៉ាងណា ក៏ចិត្តធ្លោយលួចស្រឡាញ់តែគេទៅហើយ ។ អ្វីដែលនាងអាចធ្វើបាន ក្នុងភាពខ្លួនជានារីខ្មែរ គឺនាងមិនហ៊ាន នឹងមិនដែលបញ្ចេញអោយនាយដឹងពីអារម្មណ៍ពិតរបស់នាងឡើយ មិនថានាងរស់នៅស្រុកគេដែលសេរីគ្រប់យ៉ាងហើយក៏ដោយទេ ។

ណាមួយនរះហាក់មិនដែលស្ដែងមនោសញ្ចេតនាអីសោះមកលើនាងទេមិនថានៅមែលប៊ននេះ ឬនៅស្រុកខ្មែរទេ ។

ប៉ុន្មានឆ្នាំក្រោយនេះពេលទៅលេងស្រុកខ្មែររាល់ឆ្នាំនាងតែងទៅជាមួយនរិនជានិច្ច ។ គេចេញចូលផ្ទះនាងដូចជាញាតិដ៏ជិតស្និទ្ធម្នាក់ ។ ចំពោះមុខប៉ាម៉ាក់នាង ក៏ដូច្នោះដែរ នរិនមិនដែលធ្វើអ្វីអោយលើសលោះហួសពីភាពជាបងប្រុសម្នាក់ទេ។

កន្លងមក ជានារីរស់ជាមួយអារម្មណ៍មេត្រីលួចលាក់បែបនេះលំបាកណាស់ ។ ជួនកាលនាងលួចតូចចិត្តដែលលួចស្រឡាញ់គេតែម្នាក់ឯង ។ ការតូចចិត្តនេះនាំអោយនាងគេងយំជាច្រើនដងច្រើនគ្រា ។

តែពេលនេះ...

នាងមិននឹកស្មានថា នរះក៏មានអារម្មណ៍ដូចគ្នាដែរទេ ។

ដោយពិតទៅ បុរសនេះពូកែរលាក់អារម្មណ៍មេត្រីរបស់គេណាស់ ។ កន្លងមក គេតែងធ្វើខ្លួនដូចជាបងប្រុសដ៏ល្អម្នាក់របស់នាងអញ្ចឹង ។ តាំងពីគេទទួលពាក្យផ្ដាំផ្ញើរបស់មាតាបិតានាងអោយជួយមើលការខុសត្រូវនាងពេលនាងមកនៅរៀនមែលប៊ន គេមើលថែនាងដូចប្អូនស្រីម្នាក់មែន ។ នាងមានភាពកក់ក្ដៅណាស់ពេលនៅជាមួយគេ ឬបានទៅណាមកណាជាមួយគេម្ដងៗ ។

ទោះបីនាងមកស្នាក់នៅជាមួយសាច់ញាតិខាងមាតានាង នៅម៉ុ ណ្ធបបលផាក ក៏ដោយ ក៏នារីមិនដែលមានសេចក្ដីក្សាន្តចិត្តដូចពេលបានមកលេង នឹងនៅក្បែរនរិនដែលជួលអាផាតមិនមួយនៅឯ ស៊ីធី នៅផ្លូវ ស្វនតុនស្រ្ទីតមិនឆ្ងាយប៉ុន្មានពី ឆាយណាថោន ណាស់ ។

នរិនគឺជាអ្នកក្រៅតែម្នាក់គត់ដែលផ្ដល់ភាពកក់ក្ដៅដូចនៅជាមួយគ្រួសារ ឬសាច់ឈាមបង្កើត ។

មិនឃើញនាងឆ្លើយ នរិនសួរម្ដងទៀត ។

«បងលុតជង្គង់យូរហើយណា ។ ម៉េចដែរ ព្រមរៀបការជាមួយបងទេ? បងនឹងអោយម៉ាក់ចូលស្ដីតាមប្រពៃណី?»

នារីញញឹមយ៉ាងស្រស់ដាក់មិត្តនាង ។

«ចាស ព្រម បង ។ ព្រម»

ហើយនារីយកដៃទាំងទ្វេររបស់នាងទាញបុរសអោយងើបឡើង ។ នាយងើបឡើងហើយឈរយ៉ាងកៀកបង្កើយចំចំពោះមុខនាង ។ ក្លិនគេប្រហើរចូលនាសារនារី ។ ទប់ចិត្តមិនបាននាងក្រសោបកាយនាយយ៉ាងតឹងដៃ ។

នរិនអោបនាងវិញដែរ ។ បេះដូងគេទាំងពីរលោតជាចង្វាក់តែមួយ ។

ទាំងពីរនាក់ក្រសោបគ្នា ហើយបិទភ្នែកដោយមានសេចក្ដីសុខ ។ ជំនោរសាយ័ណ្ហផាត់ល្ហើយល្ហៀកបំបោសអង្អែលគូរស្នេហ៍ទាំងទ្វេរ ។ មានអ្នករត់ហាត់ប្រាណប៉ុន្មាននាក់រត់កាត់ទៅមក ឃើញហើយក៏ញញឹមធ្វើមិនដឹងហើយរត់ហួសទៅ ។

មួយសន្ទុះក្រោយមក នរិនឱ្យបដាក់ត្រចៀកគូសង្ខាររបស់ខ្លួនថា៖

«បងមិនទាន់ពាក់ចិញ្ចៀនអោយអូនទេណា ។»

នាយលាដៃលែងនាងដោយស្រណោះ ហើយទាញដៃនារីខាងឆ្វេងមកស៊កចិញ្ចៀនចូលម្រាមដៃដ៏ស្រឡូនរបស់មាណវី ។ រួចហើយនាយលើកដៃនាងយកមកថើបថ្នមៗដោយចិត្តពេញមេត្រី ។ នារីញញឹមដោយពេញចិត្ត ។ ភ័ក្រ្តនាងក្រហមទុំដូចផ្លែនភាគ្រាសាយ័ណ្ហ ។ ហើយគេក្រសោបគ្នាជាថ្មីដោយហរទ័យពេញពោរដោយសុភមង្គល ។

ឯនាយឆ្ងាយ ព្រះសូរិយាបន្ទាបខ្លួនទាបណាស់ហើយ ។ មិនយូរទៀតព្រះសូរ្យដួងនេះនឹងលិចទៅ ហើយនាំទាំងស្នេហ៍ដ៏ចំណាស់មួយទៅកប់ចោលជើងមេឃផង ។

ថ្ងៃស្អែកព្រះសូរ្យដួងនេះនឹងរះជាថ្មី មកបំភ្លឺស្នេហ៍ថ្មីមួយអោយភ្លឺថ្លាជានិរន្តន៍រៀងទៅ ៕

ចប់ដោយបរិបូរណ៍

សូមអរគុណលោកអ្នកដែលបានអានសៀវភៅនេះ ។
សូមអោយជីវិតលោកអ្នកមិនប្រាសពីសុភមង្គលឡើយ ។

ហូតស្រេយ
ធានីមែលប៊ិន អូស្ត្រាលី
២០១៣

ស.សូត្រ